# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣១ លេខ ១០ ខែតុលា

ព.ស. ២៥០២ គ.ស. ១៩៥៩

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា — បញ្ជីរឿង — ទំព័រ


- វិបាកណកថា លោក ស៊ុន-កើន រៀបរៀង . . . . ១០៨១
- ប្រវត្តិព្រះសុមេធាធិបតី លោក យួរ-អ៊ុន រៀបរៀង . . . . ១០៩៥
- សុរពជាតក (តមក) លោក ថង-វង់ ចម្លងពីសាស្ត្រាស្លឹករឹត . . ១០៩៩


ផ្នែកអក្សរសាស្ត្រ


- រឿងហង្សយន្ត (តមក) លោក គឹម-ភន ចម្លងពីសាស្ត្រាស្លឹករឹត . . ១១០៧
- ព្រោះហេតុអ្វីបានជាសត្វលោកគ្រាប់ពាក្យមនុស្សតែមួយម៉ាត់ ៗ ជាពាក្យឥតន័យ ព្រះមហា ម៉ែន-រៀម រៀបរៀង . . . . ១១២១
- រឿងព្រេងនិងរឿងបុរាណប្រទេសជប៉ុន (តមក) លោក ភិយ-ប៊ុក រៀបរៀង . ១១២៨
- រឿងស្រីគ្រប់លក្ខណ៍ (តមក) យុក-វដីរ រៀបរៀង លោក ផេង-ជ្រីវ ពិនិត្យ . ១១៦១
- ការស្រាវជ្រាវរកប្រភពនៃបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ លោកបាប-ពិន រៀបរៀង ១១៨១
- រឿងមរណមាតា (តមក) លោក ប៊ី-សុវណ្ណ ចម្លងពីសាស្ត្រាស្លឹករឹត . . ១១៨៦
- រឿងសាមកុក (តមក) ឧកញ៉ា ឆ្វ-កន ប្រែ . . . . . ១១៧៣


ផ្នែកកំណត់ទីនិងប្រវត្តិការណ៍


- ពត៌មានផ្សេង ៗ របស់ក្រសួងធម្មការ . . . . . . ១២០២
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . ១២០៥



មួយឆ្នាំ មាន ១២ សៀវភៅ ដំឡៃផ្សារ ២៣០រ០០

# KAMBUJASURIYA

Revue religieuse et litteraire
éditée par l'Institut Bouddhique

## sommaire

### Partie religieuse :


— Éditorial par M. SIN HEAN . . . . . . . . . . 1081
— Pravattisumedhatheri par M. YOU-OUN . . . . . . . 1084
— Surabajataka (suite) relevé du manuscrit sur feuilles de latanier par M. THANG-VONG . . . . . . 1099


### Partie littéraire :


— Histoire de Hang-Yon (suite) relevée du manuscrit sur feuilles de latanier par M. IM-PHON . . . . . . . . 1107
— Pourquoi le perroquet parle-t-il mot à mot par M. MEN-RIEM . . . . . . . . . . . . 1121
— Contes et Légendes du Japon (suite) traduits par M. RAY-BUC. 1128
— La femme vertueuse par Yok Vochir revue et corrigée par M. PHENG-CHRIV . . . . . . . . . . . 1141
— L'origine de la quinzaine des morts par M. CHAP-PIN . . . . . . . . . . . . . 1151
— Légende de Marana Mâtâ (suite) relevée du manuscrit sur feuilles de latanier par M. BY-SOVANN . . . . . . . . 1156
— Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN. 1177


### Notes et Chroniques :


— Nouvelles diverses du Ministrère des Cultes . . . . . . . 1202
— Dictionnai e Sanskrit-khmer (suite) par Preah Moha-PANG-KHAT . . . . . . . . . . . . 1204



Prix d'abonnement annuel (comprenant 12 numéros): 2?0$00 .

ផ្នែកសាសនា

# វិបារណកថា

លោក ស៊ុន-ហ៊ាន រៀបរៀង

ព្រះសម្ពុទ្ធជាបរមគ្រូ ទ្រង់ជាអគ្គបុរសដ៏ឆ្នើមក្នុងលោក, ព្រះអង្គទ្រង់មានព្រះរាជហឫទ័យ ប្រកបដោយព្រះមហាករុណាទិគុណយ៉ាងធំមហិមាចំពោះសត្វលោក គឺព្រះអង្គទ្រង់ស្តេចយាងទៅស្វះស្វែងរកមោក្ខធម៌ចំពោះព្រះអង្គ ឥតគិតដល់ការនឿយហត់ព្រះកាយពលសោះ, លុះបានត្រាស់ដឹងមោក្ខធម៌ហើយ ព្រះអង្គទ្រង់យកនូវព្រះធម៌ដ៏សុខុមនោះ មកទេសនាពន្យល់ណែនាំសត្វលោកឲ្យប្រតិបត្តិតាម ដើម្បីឲ្យបានប្រាសចាកទុក្ខភ័យគ្រប់យ៉ាង ហើយនឹងបាននូវសេចក្តីសុខ ដែលសត្វលោកតែងតែត្រូវការគ្រប់គ្នា ។

ព្រះសម្ពុទ្ធជាម្ចាស់ ទ្រង់ជាឧទាហរណ៍ដ៏ឧត្តមមួយនៃបុគ្គលអ្នកឃើញដល់សង្គមធំ ព្រះអង្គទ្រង់មិនជាប់ជំពាក់នៅក្នុងសង្គមតូចណាៗទេ ហើយទ្រង់មិនប្រកាន់ជាតិភាសាវណ្ណៈវង្សត្រកូល និងលក្ខណៈរូបដែលមានរាងតូចដទៃៗ ជាគ្រឿងបែងចែករវាងមនុស្សទេ គឺព្រះអង្គទ្រង់ប្រកាន់ថា មនុស្សទាំងឡាយក្នុងលោកដូចគ្នាទាំងអស់ សុទ្ធតែចង់បានសុខ ស្អប់ខ្ពើមទុក្ខគ្រប់ៗគ្នា បានជាព្រះអង្គទ្រង់បញ្ញត្តនូវប្រៀនប្រដៅទុក

ទាំងប៉ុន្មានប្រយោជន៍ដើម្បីសង្គមធំ មិនបានបញ្ញត្តទុក ចំពោះមនុស្សជាតិណា ភាសាណា ពួកណាទេ, ពិសេសបំផុត នរណាៗ ក៏អាចប្រតិបត្តិតាមបាន ហើយអាចទទួលផលបាន តាមសមគួរដល់ការប្រតិបត្តិដូចគ្នាទាំងអស់ ។

ប្រជាពលរដ្ឋខ្មែរទាំងមូល សុទ្ធសឹងជាអ្នកកាន់ព្រះពុទ្ធសាសនាតាំងពីបុរាណកាលមក, បានជាប្រជាពលរដ្ឋខ្មែរពេញចិត្តចំពោះព្រះពុទ្ធសាសនា ទទួលយកទុកជាសរណៈដ៏ឧត្តមនោះ ព្រោះថា សាសនាអាចផ្តល់នូវសុភមង្គល សុខសន្តិភាព វឌ្ឍនភាពគ្រប់យ៉ាង ដោយប្រើផ្លូវជាកណ្តាល គឺព្រះពុទ្ធសាសនាប្រៀនប្រដៅឲ្យមានអធ្យាស្រ័យបេះអត់ធុន ឲ្យធ្វើសេចក្តីល្អ មិនចំពោះតែជនរួមជាតិរបស់ខ្លួនប៉ុណ្ណោះទេ ត្រូវធ្វើចំពោះសត្វលោកទាំងអស់ក្នុងសាកលលោក ព្រោះគេក៏ត្រូវការរស់នៅ ត្រូវការសិទ្ធិសេរីភាពដូចជាយើងដែរ ។ ន័យដ៏សំខាន់បំផុត, ព្រះពុទ្ធសាសនា បានប្រៀនប្រដៅឲ្យមានចិត្តពេញពោរទៅដោយមេត្តាករុណាចំពោះសត្វលោកទូទៅ ។

ដោយប្រទេសកម្ពុជាសព្វថ្ងៃ ដែលមានព្រះករុណាជាម្ចាស់ជីវិតតាំងពីព្រះអង្គ នៃសម្តេចព្រះឧបយុវរាជជាព្រះបិតាឯករាជ្យជាតិ ទ្រង់ជាព្រះអគ្គមគ្គុទ្ទេសក៍ដ៏ឧត្តមរបស់ជាតិខ្មែរ ទ្រង់បានយល់នូវសារប្រយោជន៍

ជាតម្លៃនៃព្រះពុទ្ធសាសនា មាន-ហេតុផលគ្រប់គ្រាន់ ល្មមនឹងដឹកនាំប្រទេសរបស់ព្រះអង្គទៅកាន់សេចក្ដីសុខក្សេមក្សាន្តបាន ដូចន័យខាងលើនេះហើយ ទើបទ្រង់ដឹកនាំប្រជាពលរដ្ឋខ្មែរទាំងមូលឲ្យប្រកាន់យកនូវនយោបាយអព្យាក្រឹត្យ ជានយោបាយក្រៅប្រទេស សម្រាប់ប្រទេសខ្មែរ គឺប្រព្រឹត្តអនុលោមទៅតាមព្រះពុទ្ធសាសនា ដែលបានយកផ្លូវកណ្ដាល, ផ្លូវមជ្ឈិមជាគោល ដើម្បីសន្តិភាពនៃលោក ។

នៅទីអវសាន, ប្រជាពលរដ្ឋខ្មែរខ្ញុំសុទ្ធសឹងជាពុទ្ធសាសនិកជន ធ្លាប់គោរពតាមព្រះពុទ្ធោវាទ ដែលប្រៀនប្រដៅឲ្យចូលចិត្តចំពោះការពិតនិងការសុខស្ងប់, ឲ្យលះបង់ធម៌អាក្រក់ ដោយកិច្ចកាន់យកនូវធម៌ល្អ, ឲ្យយកចិត្តខន្តីមកដំនួសការឃោរឃៅ និងឲ្យយកគុណទៅសងព្យាបាទ រៀងរាបដរាបមក ក៏បានទទួលឥដ្ឋមនុញ្ញផលពីការកុសលរបស់ខ្លួនដ៏សមរម្យ ពោលគឺបានស្ថិតនៅក្រោមការដឹកនាំដ៏ប្រពៃនៃព្រះរាជបល្ល័ង្កសព្វថ្ងៃនេះ និងសម្ដេចព្រះឧបយុវរាជ បានចៀសផុតពីភ្លើងសង្គ្រាម ស្ថិតនៅក្នុងសុខសន្តិភាពនិងសំបូរណភាពដ៏បរិបូណ៌ ។

# ប្រវត្តិព្រះសុមេធាថេរី

ឃុនសុវត្ថិវេទី យ្យួរ-អ៊ុន ប្រែពីបាលី

ដែលមានក្នុងថេរីគាថា ត្រង់មហានិបាត នៃសុត្តន្តបិដក

ព្រះរាជកញ្ញា ព្រះនាម សុមេធា ជារាជធីតានៃព្រះបាទកោញ្ចរាជ សោយរាជ្យក្នុងនគរ មន្តាវតី ព្រះនាងមានសទ្ធាជ្រះថ្លា ជឿស៊ប់ក្នុងព្រះពុទ្ធសាសនា ដោយការបានស្តាប់ធម៌នៃព្រះពុទ្ធជាម្ចាស់ ។ អាស្រ័យហេតុដែលព្រះនាងបានស្តាប់ធម៌ជាញឹកញយ ព្រះនាងក៏មានការចេះចាំព្រះពុទ្ធវចនៈច្រើន ជាស្ត្រីពហុស្សុត បានថ្វាយខ្លួនជាឧបាសិកា រក្សាឧបោសថសីល មានកិរិយាមារយាទត្រឹមត្រូវតាមគន្លងពុទ្ធឱវាទ ។ ណាស្ត្រីទាំងឡាយ ដែលមិនប្រសប់ខាងសំដែងធម៌ ព្រះនាងសុមេធាួយរូបដែរ ដែលរាប់ថាជាធម្មកថិកា មានប្រាជ្ញាឈ្លាសវៃ ចេះសំដែងធម៌វិចិត្រ ពីរោះអស្ចារ្យ ។

ក្នុងថ្ងៃមួយ ព្រះអង្គម្ចាស់ក្សត្រី សុមេធា ទ្រង់បានជ្រាបពត៌មានថា ព្រះរាជមាតាបិតា ទ្រង់នឹងព្រះរាជានុញ្ញាតព្រមថ្វាយព្រះនាង ទៅជាអគ្គមហេសីនៃព្រះរាជាកម្ពោះ ១ អង្គ ទ្រង់ព្រះនាម អនិកវត្ត សោយរាជ្យនៅនគរ វារណាវតី ដែលស្តេចនឹងយាងមកដណ្តឹង ក្នុងពេលឆាប់ ៗ ។ ព្រះនាងកាលបានជ្រាបដំណឹងនេះហើយ ក៏បានយាងចូលទៅគាល់ព្រះរាជមាតាបិតា ហើយក្រាបទូលអំពីសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធ-

សាសនា និងសេចក្ដីយល់ឃើញតាមផ្លូវធម៌ របស់ព្រះនាង ដូចមានសេចក្ដីតទៅនេះ ៖

បពិត្រព្រះមាតាបិតា ខ្ញុំម្ចាស់នេះ ជាអ្នកត្រេកអរពេញចិត្ត ក្នុងព្រះឱវាទនេះហើយ ដោយខ្ញុំម្ចាស់យល់ថា ការកើតជាមនុស្សក្ដី ជាទេវតាក្ដី សឹងតែមិនទៀង មិនឋិតថេរទេ នឹងបាច់ពោលទៅថ្វីដល់វត្ថុកាមនឹងកិលេសកាម ដែលជារបស់សោះសូន្យ មានការត្រេកអរតិច មានសេចក្ដីចង្អៀតចង្អល់ច្រើន ៗ ពួកជនពាលតែងល្អក់ចិត្ត ក្នុងកាមទាំងឡាយណា កាមទាំងឡាយនោះ ជារបស់ខ្លាចផ្សារ ពើតឈឺចាប់ មានពិសដូចអសិរពិស ៗ ពួកជនពាលដែលជក់ជាប់ញ៉ាមក្នុងកាម សឹងពេញណែនត្រៀបត្រា ក្នុងនរក រងទុក្ខលំបាកអស់កាលយូរអង្វែងឆ្នាំ តែងទៅរងទុក្ខសង្រេងសង្រែក្នុងកំណើតប្រេត អសុរកាយ តិរច្ឆានៗ ព្រោះពួកជនពាលទាំងនោះ ជាអ្នកល្ងង់ អាប់ឥតប្រាជ្ញា ធ្វើតែអំពើបាប មានគំនិតអាក្រក់ មិនសង្រួមរាំងកាយវាចាចិត្ត គ្មានចេតនាប៉ងនឹងធ្វើការកុសល បណ្ដោយចិត្តស្ទុះទៅក្នុងអំណាចតណ្ហា ឲ្យតណ្ហាប្រឹតដឹកនាំទៅក្នុងគំនរទុក្ខ គ្មានប្រាជ្ញាស្មារតីភ្លឺស្វាងក្នុងអរិយសច្ចៈទេ ៗ

បពិត្រព្រះមានគុណ មនុស្សអាទចំនួនច្រើននាក់ណាស់ ដែលមិនដឹងអរិយសច្ចធម៌ ត្រេកអរតែនឹងភព ពេញចិត្តតែនឹងការកើតជាទេវតា ៗ សូម្បីការកើតក្នុងភពជាទេវតា ក៏មិនទៀង ទុកជាភពមិនទៀង ពួកជន

ពាលក៏នៅតែមិនគក់ស្កុតនឹងកត ដែលត្រូវកើតញយ ៗ នោះឡើយ ៗ ពួកសត្វវិនិបាត មិនអាចនឹងបួសក្នុងពុទ្ធសាសនាបានទេ ព្រោះពួកសត្វនោះវិបត្តិភេទ ហើយវេទុក្ខគ្មានស្រាក មានតែមនុស្សជាតិទេ ទើបអាចបួសបាន ៗ ហេតុនោះ ការបានអត្តភាពជាមនុស្ស ដែលគ្មានវិកលរូបកាយ ទុកជាលាភធំរបស់សត្វ ៗ អាស្រ័យការណ៍នេះ សូមទ្រង់ទាំងពីរអង្គ ព្រះមេត្តាប្រោសព្រះរាជានុញ្ញាត ឲ្យខ្ញុំម្ចាស់បួសក្នុងព្រះពុទ្ធសាសនា ៗ ខ្ញុំម្ចាស់កាលបើបានបួសហើយ នឹងខំប្រឹងប្រព្រឹត្តធម៌ ដើម្បីលះបង់ជាតិនឹងមរណៈឲ្យអស់ ៗ ប្រយោជន៍អ្វី ដោយភពដែលជនពាលត្រេកត្រអាល ប្រយោជន៍អ្វី ដោយរូបកាយដែលជាពោសឥតខ្លឹមសារ ព្រោះព្រះសម្ពុទ្ធទ្រង់ត្រាស់ឡើងក្នុងលោកហើយ ខណៈវិបត្តិ ខ្ញុំម្ចាស់កន្លងផុតហើយ ខណៈសម្បត្តិខ្ញុំម្ចាស់បានហើយ ខ្ញុំម្ចាស់មិនហ៊ានប្រព្រឹត្តឲ្យសៅហ្មងសីល ឲ្យខូចព្រហ្មចរិយធម៌ទេ រហូតអស់មួយជីវិត ហេតុនេះ សូមទ្រង់ព្រះរាជានុញ្ញាតឲ្យខ្ញុំម្ចាស់បួស តាមសេចក្តីក្រាបបង្គំទូលសុំនេះ កុំខានឲ្យទាន ៗ

ព្រះនាងសុមេធា រាជធីតា លុះក្រាបបង្គំទូលលាទៅបួសយ៉ាងនេះហើយ ក៏ដួលចុះលើផែនដីនាផ្ទៃប្រាសាទ ៗ ឯព្រះរាជមាតាបិតាកាលទ្រង់បានជ្រាបហើយ ទាំងពីរអង្គមានព្រះរាជហឫទ័យជាទុក្ខព្រួយខ្លាំង ហាក់ដូចភ្នំធំសង្កត់លើព្រះអង្គ ទ្រង់ខំសម្រុះសម្រួលលួងលោម

ធីតា ទាំងព្រះនេត្រាពោរពេញដោយទឹកព្រះនេត្រថា ៖

ឱធីតាសំឡាញ់ឪពុកអើយ ចូរក្រោកអង្គុយឡើង ស្តាប់ឪពុកនិយាយ យើងជាឪពុកម្តាយនេះ ចាស់ៗហើយ មានសង្ឃឹមពឹងផ្អែកតែលើនាងទេ ឲ្យឪពុកលះបង់នាងម្តេចបាន ៗ នាងចង់បួស តើបួសមានប្រយោជន៍អ្វីដល់យើង ៗ នែកូនស្រីមាសសំឡាញ់ ឪពុកបានសម្រេចចិត្តថា នឹងថ្វាយនាងដល់ព្រះបាទអនិកវត្ត ជាស្តេចមានរូបល្អសោយរាជ្យនៅនគរពារាណសី នាងនឹងបានជាអគ្គមហេសី ធំលើសស្ត្រីទាំងឡាយ នៃព្រះបាទអនិកវត្តនោះ ហើយព្រះរាជអាណាចក្រនៃស្តេចនោះ ធំទូលាយ ជាប្រទេសមានភោគទ្រព្យច្រើន ដែលជាហេតុឲ្យនាងបានសេចក្តីសុខសាន្ត ឲ្យមានឥស្សរិយយស ជាធំក្រៃលែង នាងអាចនឹងប្រើប្រាស់ទ្រព្យសម្បត្តិទាំងនោះ តាមចិត្តប្រាថ្នា ៗ នែកូនស្រី ពុថា សីល ព្រហ្មចរិយធម៌ នឹងការកាន់ភេទជាអ្នកបួសនេះ គេធ្វើបានដោយកម្រណាស់ ចុះបើកូនឯងនៅវ័យក្មេងម្ល៉េះ ធ្វើម្តេចនឹងប្រព្រឹត្តព្រហ្មចរិយធម៌ តាមភេទជាអ្នកបួសបាន ៗ ឱកូនស្រីមាសឪពុក ព្រះបាទអនិកវត្ត នឹងស្តេចមកដណ្តឹងនាងក្នុងពេលឆាប់ ៗ ហើយ ឪពុកនឹងថ្វាយនាងទៅជាអគ្គមហេសីនៃស្តេចនោះ ចូរកូនស្រីកុំទទឹងទាស់ឡើយ ៗ

គ្រានោះ ព្រះអង្គម្ចាស់ក្សត្រីសុមេធា យកព្រះកូសាជូតទឹកព្រះ

នេត្រអំពីព្រះភក្ត្រ ហើយមានព្រះសវនីយ៍តបថា ៖

បពិត្រព្រះរាជមាតាបិតា ខ្ញុំម្ចាស់មិនត្រូវការទ្រព្យសម្បត្តិទាំងនោះទេ ព្រោះជារបស់គ្មានខ្លឹមសារ ខ្ញុំម្ចាស់ត្រូវការតែបព្វជ្ជាទេ ព្រោះជាភេទមានពេលទំនេរអាចប្រតិបត្តិធម៌បាន បើខ្ញុំម្ចាស់មិនបានបួសទេ ខ្ញុំម្ចាស់សុខស្លាប់ប្រសើរជាង ព្រោះហេតុនោះ សូមព្រះអង្គកុំទទួលយល់ព្រមតាមព្រះបាទអនិករត្តដែលទ្រង់ស្តេចមកដណ្តឹងនោះឡើយ ។ ខ្ញុំម្ចាស់យល់ច្បាស់ថា សរីរៈនេះ មិនស្អាត មានក្លិនអាក្រក់ គួរខ្ពើម រូបកាយនេះទុកដូចជាការុងស្បែក ដែលច្រកពេញណែនដោយសាកសព ឬដោយវត្ថុមិនស្អាត ដែលតែងហូរចេញមកតាមទ្វារទាំង ៩ និងតាមរន្ធរោម ។ មួយទៀត ខ្ញុំម្ចាស់យល់ថា សរីរកាយនេះ ជាគ្រោងឆ្អឹង ដែលសន្ធារ ឬកលាបដោយសាច់ ឈាមនិងស្បែក ជាលំនៅនៃហ្វូងដង្កូវ កាលបើជីវិតរលត់ផុតទៅ រូបកាយក៏ជាចំណី នៃពួកបក្សីបាន ។ ក្នុងពេលនោះ គេនឹងឲ្យសរីរកាយនេះ ដោយឥតយកថ្លៃ ឬសូកគេទទួលរក្សាទុក ក៏គ្មានអ្នកណាម្នាក់ត្រូវការទេ ។ រូបកាយនេះ បើគេពន្លាត់ធ្វើអាការៈខាងក្នុងឲ្យត្រឡប់មកខាងក្រៅវិញ គេនឹងឃើញច្បាស់ថាជារបស់គួរខ្ពើម សូម្បីមាតាបិតាបង្កើត ក៏ទ្រាំអត់នឹងក្លិនអសោចិ៍នោះពុំបាន ។ កាយនេះ បើគ្មានវិញ្ញាណហើយ មិនយូរទេ គេនឹងយកទៅដុតចោលឬកប់ចោលក្នុងព្រៃស្មសាន ជារបស់គ្មានប្រយោជន៍ មិន

ដល់ទីងងឹតសូស មាតាបិតាឬបុត្រធីតា ដែលកាន់ពាល់ខ្មោចនោះ សឹងប្រញាប់ផ្ងូតលាងដៃជើងខ្លួនប្រាណ ព្រោះមានសេចក្តីខ្ពើមរអើម ៗ ចំណាន់បើជនដទៃ ដែលមិនជាប់ជាសាច់សាលោហិតនឹងខ្មោចនោះ មិនដឹងជាខ្ពើមយ៉ាងណាទៅ ៗ ពួកជនពាលតែងស្រឡាញ់ងប់ចិត្ត ក្នុងរូបកាយដែលឥតខ្លឹមសារ នៅវាងក្នុងពោរពេញដោយទឹកមាត់ ទឹកសម្បោរ ទឹកនោម ទឹកខ្ទុក ទឹករងៃ លាមកចាស់ថ្មី សឹងតែឃើញជាក់ទីងខ្ទុក ៗ បពិត្រព្រះមាតាបិតា ពាក្យដែលខ្ញុំម្ចាស់ក្រាបទូលមកនេះ បានសេចក្តីថា ខន្ធ ធាតុ អាយតនៈ ជាឫសគល់នៃសេចក្តីទុក្ខ លំបាកវេទនា ៗ រូបកាយនេះ ជាគ្រោងឆ្អឹងសាកសព គួរឲ្យស្អប់ខ្ពើមយ៉ាងនេះទៅហើយ គើឲ្យខ្ញុំម្ចាស់ត្រូវការប្រាថ្នាឲ្យគេចូលដណ្តឹងខ្ញុំម្ចាស់ម្តេចបាន ៗ ការលំបាកឈឺចាប់ ដោយលំពែងស្រួច ៣០០ ធ្លាក់មកមុតរូបកាយ ពល់ថ្ងៃ ពប់ឆ្នាំ ដោយហេតុតែប្រព្រឹត្តធម៌ ជាគ្រឿងធ្វើឲ្យអស់ទុក្ខ ការលំបាកឈឺចាប់នោះប្រសើរ ៗ វិញ្ញូជន អ្នកបានប្រតិបត្តិតាមពុទ្ធោវាទ ហើយបាន់សេចក្តីលំបាកដោយហេតុណាមួយ ការលំបាកនោះ ជាហេតុឲ្យអស់ទុក្ខក្នុងសង្សារវដ្ត ៗ សង្សាររបស់ជនពាល ដែលលំបាករឿយ ៗ ជាសង្សារវែងឆ្ងាយ ៗ ពួកសត្វដែលអន្ទោលចុះអន្ទោលឡើង ពីទាបទៅខ្ពស់ ពីខ្ពស់ទៅទាប ពីមនុស្សទៅទេវតា ពីទេវតាមកសត្វតិរច្ឆាន ពីសត្វតិរច្ឆានទៅប្រេត អសុរកាយ នរក តែងនាំយក

តាំងទុកជាប់ជាមួយនៅផងជាដរាប ព្រោះក្នុងទីនោះ សេចក្ដីសុខសាន្ត គ្មានទេ ឯសេចក្ដីសុខដ៏ក្រៃលែង មានតែក្នុងឋានព្រះនិព្វាន ។ ជនណា កាន់ពុទ្ធសាសនា ខំព្យាយាមលះជាតិនិងមរណៈបាន ជននោះឈ្មោះថា បានដល់ព្រះនិព្វាន ។ បពិត្រព្រះមានគុណធ្ងន់ ខ្ញុំម្ចាស់សូមក្រាបបង្គំលា នឹងចេញទៅបួសក្នុងថ្ងៃនេះហើយ ប្រយោជន៍អ្វីដោយភោគសម្បត្តិ ដែល ជារបស់ទុកស្មោកហាក់ដែលគេត្រូវតែខ្ជាក់ចោល ។ ចិត្តខ្ញុំម្ចាស់ជិនណាយ គ្មានត្រូវការនឹងភោគសម្បត្តិនោះទេ សូមព្រះករុណាទ្រង់ជ្រាប ។

កាលព្រះនាងសុមេធា រាជកញ្ញា កំពុងពណ៌នាធម៌ ព្រមទាំង ទូលលាព្រះរាជមាតាបិតា ក៏ស្រាប់តែព្រះបាទអនិករត្ត ស្ដេចធ្វើព្រះរាជ-ដំណើរ ចូលមកដល់ប្រាសាទក្នុងព្រះបរមរាជវាំង របស់ព្រះបិតាព្រះនាង ដោយមានព្រះរាជបរិវារកំលោះ ៗ ដើរជាក្បួនហែហមទ្រង់ ព្រមទាំងកាន់ដង្វាយដ៏ប្រណីតវិចិត្រថ្លៃថ្នូ ជាគ្រឿងបណ្ណាការគ្រប់ដៃ ដើម្បីនឹងដណ្ដឹងព្រះនាងសុមេធា ។ ក្នុងពេលនោះ ព្រះនាងសុមេធា កំពុងកាន់ព្រះខាន់កោរកាត់ព្រះកេសា ដែលមានពណ៌ខ្មៅរលើប ស្លូតរទន់ រួចហើយបិទទ្វារប្រាសាទ គង់ពែនក្នុងចំរើនឈានសមាបត្តិ ពិចារណានូវអនិច្ចសញ្ញា ។ គាប់ជួនព្រះបាទអនិករត្ត ដែលព្រះអង្គស្អិតស្អាង ដោយគ្រឿងអលង្ការ វិចិត្រដោយមាសនឹងកែវមណី ស្ដេចចូលទៅជួបនឹងព្រះនាងសុមេធា នៅខាងក្នុងប្រាសាទ ដោយព្រះដំណើររួសរាន់

ទ្រង់មានព្រះរាជបន្ទូលអង្វរព្រះនាងថា៖

នៃនាងសុមេធា មានកក្រ្ដូរផង សូមនាងស្ដាប់បង បងបាននាំគ្រឿងបណ្ណាការដ៏មានដំឡៃ ចូលទៅដណ្ដឹងព្រះនាង ដល់ព្រះរាជ-មាតាបិតានៃព្រះនាងៈហើយ ។ ទ្រង់ត្រាស់បញ្ជាឲ្យបងចូលមកនិយាយនឹងព្រះនាងផ្ទាល់ខ្លួន ។ ឳប្អូនសំឡាញ់ពេញចិត្តបងអើយ រូបប្អូនមានពន្នីរស្មី មានលំអដូរផង ជាហេតុនាំឲ្យបងស្រឡាញ់ពេញចិត្តក្រៃលែង ដូចខ្យល់ជាទីត្រេកអរនៃអ្នកមានញើស ពុំនោះដូចទឹកជាទីត្រេកអរ នៃអ្នកស្រេកទឹក ។ បងមានចិត្តអោនងងប់ជ្រប់ស្ទុងក្នុងរូបប្អូន មិនអាចទឹងទាញចិត្តដែលលង់ស៊ប់នោះ ឲ្យត្រឡប់វិញបានទេ ដូចត្រីជាប់សន្ទូច ឬដូចដំរីចុះប្រេង មិនខ្លាចកង្វេរ ។ ហេតុនោះ សូមប្អូនជួយលត់សេចក្ដីក្រហល់ក្រហាយនៃបង ដូចគ្រូពេទ្យដាក់ថ្នាំឲ្យអ្នកជម្ងឺ ឬដូចគេឲ្យភោជនដល់អ្នកស្រេកឃ្លាន ពុំនោះសោតដូចគេយកទឹកលត់ភ្លើង ។ សូមនាងព្រមទទួលធ្វើជាភរិយាបង បងនឹងអភិសេកប្អូនជាអគ្គមហេសីធំលើសស្នំទាំង ៥០០ នាក់ ឲ្យមានស្រីជាបរិវាររាប់រយបំរើប្អូនឆ្វេងស្ដាំ ។ រាជអាណាចក្រ របស់បងធំណាស់ ហើយសម្បូរដោយភោគទ្រព្យនឹងឥស្សរិយយស ដែលជាហេតុឲ្យប្អូនបានសេចក្ដីសុខសម្រាន្ត ។ រាជ-សម្បត្តិ បងនឹងប្រគល់ផ្ដាច់ឲ្យប្អូន សូមនាងប្រើប្រាស់សម្បត្តិទាំងនោះតាមប្រាថ្នាចុះ ។ សូមប្អូនសង្គ្រោះស្រោចស្រង់ខ្លួនបងឲ្យរួចចាកទុក្ខ

ផង សង្គ្រោះព្រះរាជមាតាបិតាម្ចូន ឲ្យរួចផុតទុក្ខព្រួយ ដែលទ្រង់កំពុ
តែទ្រង់ព្រះវិយោគសោកខ្លាំងផង ។

គ្រានោះ ព្រះរាជធីតា សុមេធា ក្រាបបង្គំទូលតបថា បពិត្រ
បាទអធិករត្ត សូមទ្រង់ព្រះមេត្តាប្រោសអភ័យទោសខ្ញុំម្ចាស់ ។
ក្រាបបង្គំទូលទ្រង់ឲ្យបានជ្រាប ។ សូមមហាបពិត្រទ្រង់ជ្រាបថាខ្ញុំម្ចា
ពុំបានស្អប់ទ្រង់ទេ តែរូបខ្ញុំម្ចាស់ជាកាមរបស់ទ្រង់ ដែលទ្រង់ត្រូវការ
បានទៅរួមរសកម្រេក ហេតុនេះសូមទ្រង់ពិចារណាឲ្យឃើញគុណ
ទោសរបស់កាម ឲ្យបានសព្វគ្រប់សិន ។ ទ្រង់គង់បានទ្រង់ជ្រាប
គុណប្រយោជន៍របស់កាមហើយ ទើបទ្រង់ពេញព្រះរាជហឫទ័យស្វែ
កាម តែត្រង់ទោសរបស់កាមប្រហែលទ្រង់ពុំបានយកព្រះចិន្តាពិចារ
ឲ្យដិតដល់ទេ ហេតុនេះ សូមទ្រង់ព្រះសណ្ដាប់ ខ្ញុំម្ចាស់នឹងថ្វា
សេចក្ដីឲ្យទ្រង់បានជ្រាប ដូចតទៅនេះ ៖

ព្រះបាទរាជាធិរាជ ព្រះនាមមន្ធាតុ ទ្រង់ជាស្ដេចមហាចក្រ
ពត្រួតត្រាលើទ្វីបទាំងបួន ទ្រង់ប្រសើរផុតជាងពួកជនអ្នកបរិភោគកា-
ទ្រង់មិនឆ្អែតនឹងកាម ទ្រង់វិវដ្ដទៅ ទាំងមិនគ្រប់គ្រាន់សេចក្ដីប្រាថ្ន
ភ្លៀងបង្អុរចុះនូវកែវ ៧ ប្រការ គ្រប់ទិសទាំងដប់ ស្រោចស្រប់ឲ្យ
ជនណា រតនវត្ថុទាំងនោះក៏នៅតែមិនល្មម មិនឆ្អែតចិត្តនៃជននោះ
ជនតែងស្លាប់ទៅទាំងមិនឆ្អែតកាម ។ ពួកជនដែលចេះតែត្រេកត្រ

នឹងកាមយ៉ាងនេះ ព្រោះមិនបានយល់ច្បាស់ថាកាមជាសត្រូវឲ្យទោសដល់ខ្លួន កាមទុកដូចជាសស្ត្រាវុធ ទុកដូចជាឈើស្រួច ទុកដូចជាសត្វមានពិស ឬទុកដូចជាគប់ភ្លើង ថ្ងៃណាមួយក៏នឹងឲ្យទុក្ខដល់ខ្លួន ។ កាមនេះ ដែលឲ្យផលជាសុខ ក៏សេចក្ដីសុខនោះមានប្រមាណតិចតួច ហើយមិនទៀងទាត់ មិនឋិតថេរយឺនយូរទេ នឹងប្រែក្លាយឲ្យផលជាទុក្ខវិញ សេចក្ដីទុក្ខនោះមានអំណាចខ្លាំងក្លាណាស់ អាចដុតហឫទ័យសត្វឲ្យក្ដៅពេលកលគានតឹងជានិច្ច បណ្ដាលឲ្យទៅជាឈឺចាប់ស្លាប់ខ្លួនក៏មាន ដឹកនាំចិត្តឲ្យប្រព្រឹត្តកំហុស មានទោសជាទម្ងន់ក៏មាន ។ មួយទៀត ជនអ្នកបរិភោគកាម ទុកដូចគេបរិភោគផ្លែឈើពុល ទុកដូចសត្វពាំដុំសាច់ដែលសត្វឯទៀតត្រូវការដែរ ទុកដូចគេដេកយល់សប្តិបានកំណប់ ទុកដូចជាទ្រព្យរបស់គេមកប្រើប្រាស់ ទុកដូចជាពេគអ្វីមួយដែលកើតក្នុងខ្លួន ឬទុកដូចជាគេចុះទៅក្នុងរណ្ដៅពេញដោយរងើកភ្លើង ព្រោះជនអ្នកបរិភោគកាមត្រូវតែបានទទួលសេចក្ដីទុក្ខ សេចក្ដីវិនាសព្រោះកាមជាប្រាកដ ។ បពិត្រព្រះចមពល ហេតុនេះ សូមទ្រង់កុំត្រេកត្រអាលនឹងកាម សូមទ្រង់ស្ដេចវិលត្រឡប់ទៅព្រះរាជនិវេសន៍ព្រះអង្គវិញចុះ ព្រោះខ្ញុំម្ចាស់ពុំមានត្រូវការនឹងកាមទេ បុគ្គលត្រូវភ្លើងឆេះក្បាល ប្រញាប់លត់ភ្លើងនោះ យ៉ាងណា ខ្ញុំម្ចាស់ដែលមានជរាមរណៈតាមជាប់ជានិច្ច ក៏ត្រូវតែប្រញាប់ចេញបួសដើម្បីប្រឹងកំចាត់ជរាមរណៈនោះក៏យ៉ាងនោះឯង ។ ក្នុងរឿងនេះ អ្នក

ណាមួយនឹងមកជួយកំចាត់ជរាមរណៈជាជំនួសខ្ញុំម្ចាស់ ពុំបានឡើយ ។

បន្ទាប់ពីនោះមក ព្រះនាងសុមេធា បានទតទៅឃើញព្រះរាជមាតាបិតា ស្តេចយាងមកទ្រង់ព្រះកន្សែងសោកា ទៀបទ្វារប្រាសាទ ក៏បានក្រាបទូលសេចក្តីដូចតទៅនេះ ៖

សូមព្រះរាជមាតាបិតាទ្រង់ជ្រាប សង្សាររបស់បុគ្គល ដែលយំសោកស្តាយ ព្រោះហេតុស្លាប់ឬព្រាត់ប្រាសចាកសត្វនិងសង្ខារដែលស្រឡាញ់ពេញចិត្ត ជាសង្សារវែងឆ្ងាយណាស់ៗ សូមទ្រង់នឹកគ្នេរមើលនូវទឹកភ្នែក ទឹកដោះនិងឈាម ក្នុងកាលដែលទ្រង់អន្ទោលទៅមកក្នុងវដ្តសង្សារ ដែលមានដំណើរចំនួនស្មើមហាសមុទ្រទាំងបួន ៗ សូមទ្រង់នឹកមើលនូវគំនរឆ្អឹងរបស់ទ្រង់ ក្នុងកប្បមួយ ១ ដែលមានកំពស់និងទំហំស្មើនឹងភ្នំវេបុល្ល ។ សូមទ្រង់នឹកមើលនូវមាតាបិតារបស់ទ្រង់ ក្នុងសង្សារវដ្ត ដែលមានចំនួនច្រើនជាងដុំដី ដែលគេយកផែនដីទាំងជម្ពូទ្វីបមកលញ់ប៉ុន ១ គ្រាប់ក្រចៅ ៗ សូមទ្រង់នឹកមើលនូវការក្របានអត្តភាពជាមនុស្ស ដូចជាការក្រនៃអណ្តើកខ្វាក់ ដែលហែលក្នុងមហាសមុទ្រ ហើយនៅឆ្ងាយអំពីនឹមដែលអណ្តែតក្នុងមហាសមុទ្រដែរ អណ្តើកខ្វាក់នោះ មិនងាយហែលទៅប្រកក្បាលខ្លួនក្នុងប្រហោងនឹមនោះឡើយ ព្រោះហេតុខ្យល់និងរលកបក់បោកច្រានទៅកាន់ទិសផ្សេង ១ គ្នា ៗ សូមទ្រង់ពិចារណាឲ្យឃើញច្បាស់ថា រូបកាយនេះ មានទោសច្រើនប្រការ ជារបស់ឥតខ្លឹមសារ ដូចគ្នានឹងពពុះទឹក ជារបស់គ្មានទៀងទាត់ឋិតនៅយឺនយូរ

ទេ កើតមកគ្រាន់តែឲ្យបំរើនៃព្រះសាសនាប៉ុណ្ណោះ ។ សូមទ្រង់ទត មើល នូវសេចក្តីទុក្ខក្តៅខ្លោចផ្សា របស់សត្វដែលភ្លាត់ខ្លួនទៅកើត ក្នុងនរក ។ សូមទ្រង់ទតមើល នូវការនឿយព្រួយលំបាកក្នុងការចិញ្ចឹម ជីវិត រាល់ជាតិកំណើត ។ សូមទ្រង់ធ្វើដំណើរចិត្តទៅក្នុងអរិយសច្ចធម៌ តាមពុទ្ធោវាទវិញ ។ សូមទ្រង់ពិចារណាមើលចុះ កាលបើឱសថជាថ្នាំ ពូកែស័ក្តិសិទ្ធិមានហើយ ពេលដែលមានក្នុងខ្លួន មានប្រយោជន៍អ្វី ដែល ទីងទុកឲ្យមានតទៅទៀត ។ កាលបើអមតធម៌ គឺធម៌មិនស្លាប់ មាន ហើយ រូបកាយជារបស់ត្រូវស្លាប់ត្រូវរង់ទុក្ខក្តៅក្រហាយ មានប្រយោជន៍ អ្វីដល់ទ្រង់ ។ កាលបើនេក្ខម្មធម៌ ជាធម៌ឥតសត្រូវ មានហើយ កាម ជារបស់នាំឲ្យកើតសត្រូវ មានប្រយោជន៍អ្វីដល់ទ្រង់ ។ កាលបើព្រះ និព្វាន ជាធម្មជាតិគ្មានគ្រឿងជាក់ស្រែះ មានហើយ កាមជាចំណង ចងសត្វភ្ជាប់ទីងក្នុងភ្លើងទុក្ខ មានប្រយោជន៍អ្វីដល់ទ្រង់ ។ កាលបើព្រះ និព្វានជាគុណជាតមិនចេះចាស់មានហើយ កាមជារបស់ចាស់ត្រូវឈឺស្លាប់ មានប្រយោជន៍អ្វីដល់ទ្រង់ ។ មែនពិត ព្រះនិព្វានមិនចាស់ មិនស្លាប់ មិន សោក មិនមានសត្រូវ មិនបង្អៀតបង្អល់ មិនមានភ័យ មិនមានក្តៅ ពេលពលទេ ព្រះនិព្វាននោះ គ្មានលេតលោយទេ គេគប្បីបានរហូត មកដល់សព្វថ្ងៃនេះ ។ បុគ្គលណា មានសេចក្តីព្យាយាមដើរតាមអដ្ឋង្គិក- មគ្គ គឺប្រឹងដើរតាមផ្លូវប្រកបដោយអង្គ ៨ បុគ្គលនោះអាច ទៅដល់

ព្រះនិព្វានជាឋានបរមសុខបាន ។

ហេតុនេះ សូមទ្រង់កុំលះបង់ចោលនូវសេចក្ដីសុខដ៏ធំទូលាយ ទៅមទូលយកនូវសេចក្ដីសុខស្ដួចស្តើងក្នុងកាមឡើយ បំណាច់បានមកកើតជាអត្តមនុស្សជាតិ ។ សូមប្រយ័ត្នព្រះអង្គកុំឲ្យមានសេចក្ដីស្ដាយក្រោយដូចត្រីជាប់សន្ទូច ។ បើទ្រង់ប្រកបខ្លួនក្នុងកាម ទ្រង់នឹងសោយទុក្ខទោមនស្សក្រៃពេកប្រមាណមិនបាន ។ ព្រោះហេតុនោះ សូមទ្រង់លះកាត់កាមទាំងឡាយចេញ ។

ព្រះនាងសុមេធា កាលបានពណ៌នាធម៌ រំលឹកព្រះស្មារតីនៃព្រះរាជមាតាបិតា និងព្រះបាទអនិកត្ដយ៉ាងនេះហើយ ក៏បោះសក់ទាំងសំណុំដែលកាត់នៅព្រះហស្ត ចោលទៅលើផ្ទៃផែនដី ។ ព្រះមហាក្សត្រទាំង ៣ ព្រះអង្គ ទ្រង់បានធូរស្បើយចាកការគានតឹងក្នុងព្រះទ័យ លែងសោយសោកា ព្រោះបានស្ដាប់ធម៌ដែលព្រះនាងពណ៌នានោះ ។

ក្នុងខណៈនោះ ព្រះបាទអនិកត្ត ទ្រង់ប្រណម្យអញ្ជលីទូលអង្វរព្រះរាជមាតាបិតានៃព្រះនាងសុមេធាថា សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោសអនុញ្ញាតបើកនាងសុមេធា ឲ្យបួសតាមបំណងចុះ ។ ព្រះបាទកោញ្ចរាជនឹងព្រះរាជទេវី ទ្រង់បានទទួលយល់ព្រម ព្រះរាជានុញ្ញាតឲ្យព្រះរាជបុត្រីបួសតាមប្រាថ្នា ដោយមានព្រះបន្ទូលថា ឱធីតាសំឡាញ់ឪពុកឥឡូវនេះ ឪពុកបានធូរស្រាលក្នុងចិត្តហើយ បំណងឪពុកដែលចង់

ឲ្យកូនស្រីមានប្តីក្តី ចង់ឲ្យគ្រប់គ្រងរាជសម្បត្តិក្នុងនគរទាំង ២ ក្តី ក៏រសាយចេញពីចិត្តឪពុកអស់ហើយ ដោយការបានស្តាប់ធម៌របស់នាង ឪពុកបានភ្ញាក់ច្បាស់ក្នុងចិត្តថា ការប្រគល់រាជ្យឲ្យ ទុកដូចប្រគល់គំនរភ្លើងទុក្ខឲ្យដល់កូនស្រីវិញទេ ដូច្នេះ ចូរនាងទៅបួស ក្នុងពុទ្ធសាសនា តាមពេញប្រាថ្នានាង ដើម្បីធ្វើឲ្យអស់ទុក្ខចុះ ។

ព្រះនាងសុមេធា រាជកញ្ញា កាលបានព្រះរាជានុញ្ញាតអំពីព្រះមាតាបិតាហើយ ក៏បានចេញទៅបួស ហើយបានចំសិក្សានូវមគ្គធម៌ បានសម្រេចអភិញ្ញា ៦ ព្រមទាំងបានលុះអរហត្តផល ដល់នូវភាពជាព្រះខីណាស្រព ១ អង្គ ។ ក្នុងកាលជិតនឹងបរិនិព្វាន ព្រះសុមេធាថេរី បានប្រកាសនូវបុព្វចរិត គឺអំពើកុសលដែលនាងបានសាងមកក្នុងភពមុនថា ៖

កាលព្រះមានព្រះភាគ ព្រះនាមកោនាគមនៈ ទ្រង់បានត្រាស់ឡើងក្នុងលោក ខ្ញុំសុមេធា នឹងសំឡាញ់ខ្ញុំពីរនាក់ ឈ្មោះនាងធនញ្ជានី ១ ឈ្មោះនាងខេមា ១ ទាំង ៣ នាក់ មានសទ្ធាជ្រះថ្លាក្នុងពុទ្ធសាសនា បានរួបរួមធនធាន ចំណាយកសាងព្រះវិហារថ្មីមួយ ក្នុងអារាមនៃសង្ឃ ថ្វាយដល់ព្រះសម្មាសម្ពុទ្ធព្រះនាមកោនាគមនៈ ។ ដោយអំណាចអានិសង្សនៃវិហារទាននេះ យើងទាំង ៣ នាក់ បានទៅកើតក្នុងឋានសួគ៌ទេវលោក មួយម៉ឺនដង បានទៅកើតជាមនុស្សក្នុងត្រកូលខ្ពង់ខ្ពស់ ក៏រាប់ម៉ឺនដងដូចគ្នា ។ កាលយើងទៅកើតជាទេវតាក៏ជាទេវតាមានឫទ្ធិ

ធំ មានអានុភាពធំជាងទេវតាទាំងពួង កាលយើងមកកើតជាមនុស្សក៏ជាអ្នកសម្បូរដោយសេចក្ដីសុខជាងជនទាំងពួង ៗ ចំណែកខ្លួនខ្ញុំសុមេធានេះបានកើតជាស្រីកែវ ជាអគ្គមហេសីនៃស្ដេចចក្រ មានរតនៈ ៧ ប្រការ ក៏ជាច្រើនជាតិ ៗ អានិសង្សនៃវិហារទានរបស់ខ្ញុំនោះ ជាហេតុជាប្រភពជាឬសគល់ នៃព្រះនិព្វាន ដែលទុកដូចជាស្ពានឬនាវានាំចម្លងខ្ញុំ ឲ្យមកដល់ឋានៈជាអ្នករលត់អស់កិលេស ហើយនឹងបរិនិព្វាន ក្នុងថ្ងៃនេះឯង ៗ

កន្សែប្រវត្តិព្រះសុមេធាថេរី
មានសេចក្ដីលែបិក្ខុតិ៍ពោសកាម
ឲ្យឃើញច្បាស់ជារបស់នាំអាមណាម
នាំរហាមកើតទុក្ខព្រួយគ្មានស្រាកស្រាន្ដ ៗ
នុអនិច្ចាមនុស្សយើងបុថុជ្ជន
កម្សត់ក្រាសផ្ទន់ស្លុំទ្រាំធន់តាមកាមប្រាន
ពោះកាមកាចអាចផ្ដល់ទុក្ខអំបាលមាន
ក៏មិនបានយកព្រះធម៌មកដាក់ខ្លួន ៗ
បើឆ្លើចិត្តឲ្យបានដូចសុមេធា
នោះមុខជានឹងបានសុខដ៏សមសួន
សមជាអ្នកកាន់ពុទ្ធសាសន៍ហើងខ្ជាប់ខ្ជួន
អាចរើខ្លួនរួចផុតទុក្ខទាំងពួងអើយ ! ៗ

---

# សុរពជាតក

(តមក)

លោក ជង-វង ចម្លងពីសាស្ត្រស្លឹករឹត

រីទុក្ខដ៏ជាធំលើសអស់ទុក្ខទាំងពួងក្នុងលោកិយនេះ គឺទុក្ខដូចម្តេច? ។

សោ កាកោ រីក្អែកនោះឆ្លើយថា ក្អែកណាដែលបុគ្គលកាត់ស្លាប កាត់កន្ទុយហើយ ក្អែកនោះ ទឹងដល់នូវសេចក្តីទុក្ខលើសអស់ទុក្ខទាំងពួងហោង ។

ក្តាមឆ្លើយថា អើក្អែក! អជានន្តោ អ្នកពុំដឹងអ្វីឡើយ អញទឹងដណ្តឹងប្រស្នាជាគម្រប់ពីរតទៅទៀត; អញ្ញេហិ សុខំ វរៈ តមោ ។ល។ ត្វញ្ញ មេ ឧសេល្បហិ បញ្ហាត្តិ សុខអ្វីជាធំលើសសុខទាំងអស់ ក្នុងលោកនេះ ទឹងបរលោក? ចូរអ្នកដោះស្រាយនូវប្រស្នានេះ ។

ក្អែកឆ្លើយថា បើបុគ្គលណា បានបរិភោគសំឡញាំក្ងាដែលបុគ្គលរៀបណ្តាប់តាក់តែងល្អហើយ ដកបដល់ក្អែកស្កប់ស្កល់, ដូច្នេះឈ្មោះថា ជាសុខលើសសុខទាំងពួង ។

តំ សុត្វា កក្កដកោ ក្តាមបានស្តាប់ពាក្យនោះហើយ ឆ្លើយថា ម្នាលក្អែក! អ្នកពុំដឹងឡើយ អ្នកចេះតែស៊ីទេ, ដូច្នោះ យើងទឹងដណ្តឹងប្រស្នាជាគំរប់ ៣ តទៅទៀត; ម្នាលក្អែក! ថាបើឃ្លានបាន

បរិភោគដល់ប៉ុន្មានៗក្តី ពុំអាចនឹងបំបាត់ឃ្លានបាន តើអ្នកយល់ថា ឃ្លានអ្វី ?, ចូរអ្នកដោះស្រាយប្រាប់យើងផង ។

ក្អែកឆ្លើយថា យោ អាហារុបច្ឆេទោ បើអ្នកណាមួយ អត់អាហារគេពុំបាន លុះឃើញគេបរិភោគ ក៏មានសេចក្តីស្រេកឃ្លាន កើតឡើង នេះឈ្មោះថា អតិឆាតៈ ។

ក្អាមឆ្លើយថា ម្នាលក្អែក ! អ្នកដឹងតែខាងលោកម្យ៉ាង ពុំដឹង ប្រស្នានេះឡើយ យើងនឹងសួរប្រស្នាជាគំរប់ ៤ តទៅទៀត, ម្នាលក្អែក ! រស្មីអ្វី ល្អលើសរស្មីទាំងពួង ក្នុងលោកិយ និងបរលោក ? ។

ក្អែកដោះស្រាយថា រស្មីដែលហូរចេញពីក្នុងព្រះអាទិត្យ ក៏ព្រោង ព្រាតពេញទាំងអាកាស មានអ័ព្ទនឹងពពកប្រាសចេញអស់ ហៅថា រស្មីល្អលើសរស្មីទាំងពួង ។

ក្អាមស្តាប់ហើយឆ្លើយថា អើក្អែក ! អ្នកឥតដឹងថា គួរពុំគួរទេ ដូច្នោះ ចូរដោះសានូវប្រស្នាជាគំរប់ ៥ តទៅទៀត; ម្នាលក្អែក ! អាក្រក់អ្វីលើស ពីសម្បុរសៅហ្មងទៅទៀត ក្នុងលោកិយ និងបរលោក ? ។

ក្អែកឆ្លើយថា សត្វណាមួយ អត់អាហារពុំបានបាយទឹកបរិភោគ សម្បុររមែងសៅហ្មង ស្គាំងស្គមអាក្រក់ណាស់ហោង ។

ក្អាមស្តាប់ហើយនិយាយថា ម្នាលក្អែក! អ្នកពុំដឹងសេចក្តីកក់ជ្រៅ

គុណទោសទេ អ្នកថាឲ្យត្រូវចំពីមាត់ ដូច្នោះ យើងនឹងដណ្តឹងប្រស្នាជាគំរប់ ៦ តទៅទៀត; ម្នាលក្អែក! អ្វីធំ ក្រៃលែងធំក្នុងលោកិយ នឹងបរលោក ? ។

ក្អែកឆ្លើយថា ថ្ងឯណាពុំមានទន្ទៃណាទតាន់ក្ស នេះឈ្មោះថា ធំលើសរបស់ទាំងពួង ។

ក្តាមស្រដីថា អ្នកឯងពុំដឹងថា អ្វីជាប្រយោជន៍ អ្វីមិនមែនប្រយោជន៍ ឡើយ ដូច្នេះចូរអ្នកដោះប្រស្នាទី ៧ តទៅទៀត; ម្នាលក្អែក! ខ្ពស់អ្វីក្រៃលែងខ្ពស់ ក្នុងឥធលោក នឹងបរលោក ?, ចូរអ្នកប្រាប់យើងផង ។

ក្អែកឆ្លើយថា អាកាសខ្ពស់លើសអ្វីទាំងអស់ ក្នុងឥធលោក នឹងបរលោកនេះ គ្មានអ្វីខ្ពស់ជាងអាកាសឡើយ ។

ក្តាមនិយាយថា ឥ! អ្នកពុំអាចដោះស្រាយបានឡើយ ដូច្នោះ អ្នកត្រូវដោះស្រាយប្រស្នាទី ៨ តទៅទៀត; ម្នាលក្អែក! អ្វីក្តៅ ក្រៃលែងក្តៅ ក្នុងឥធលោក នឹងបរលោក ? ។

ក្អែកឆ្លើយថា ភ្លើងធម្មតាក្តៅពុំស្មើនឹងភ្លើងនរក ភ្លើងនរកក៏ក្តៅពុំស្មើនឹងភ្លើងកល្ប ភ្លើងកល្បនេះឈ្មោះថា អតិឧណ្ហៈ ហោង ។

ក្តាមឆ្លើយថា អ្នកស្រដីនេះ ពុំត្រូវទេ ចូរឆ្លើយប្រស្នាទី ៩ តទៅ; ម្នាលក្អែក! អ្វីត្រជាក់ក្រៃលែងត្រជាក់ក្នុងលោកនេះ នឹងលោកខាងមុខ ? ។

វែក្អឆ្លើយថា ទឹកក្នុងក្អំត្រជាក់លើសអ្វីទាំងអស់ក្នុងលោកនេះ និងលោកខាងមុខ ។

ក្អាមបេះន្ទាសថា អ្នកឯងឆោតល្ងង់ខ្លៅខ្លាំងណាស់ យើងទុកអ្នកឯងជាអ្នកអប្បឥតប្រាជ្ញា ឆ្លើយប្រស្នាយើងពុំរួចឡើយ ដូច្នោះចូរឆ្លើយប្រស្នារបស់យើងផងតំរប់ ១០ តទៅ; ម្នាលវែក្អ! អ្វីល្អិតសុខុម លើសវត្ថុដទៃ ក្នុងឥធលោក និងបរលោក? ។

វែក្អឆ្លើយថា វត្ថុដែលល្អិតសុខុមលើសអ្វីទាំងអស់ គឺខ្យល់ ។

ក្អាមឆ្លើយថា អ្នកដោះស្រាយប្រស្នារបស់យើង ពុំត្រូវ ១ ឡើយ អប្បញ្ញា អ្នកឯងជាអ្នកឥតប្រាជ្ញា ឆោតល្ងង់ខ្លៅ ពហុទុញ្ញក្រោ ប្រសប់តែខាងបោកបញ្ឆោតគេ ឯសេចក្តីពក់ព្រៅពុំដឹងសោះ ការជិតយោ កម៉ិសត្តុម៉ិ យើងនឹងទៅជាមួយអ្នកដូចម្តេចកើត ដូច្នេះ យើងពុំទៅឡើយ ។

វែក្អអន្ទះថា ម្នាលសំឡាញ់! ប្រស្នាដែលសំឡាញ់សួរនេះ គួរតែ ពុំគួរតែ អញ្ចឹង បុច្ឆាហ៎ ចូរអ្នកសួរប្រស្នាឯទៀតចុះ យើងនឹងដោះស្រាយឲ្យត្រូវ ។

ក្អាមឆ្លើយថា អើ បើដូច្នោះ អ្នកចាំឆ្លើយនូវប្រស្នាទី ១១ តទៅ; តយោ លោកេ ។ល។ វិស្សជ្ជេហិ មម បញ្ហំ ម្នាលវែក្អ! នន្ទីតអ្វីក្នុងលោកនេះ ព្រមទាំងលោកខាងមុខ លើសលែងជាង

ងងឹតទាំងអស់ ដែលហៅថា អតិតមៈ?, ចូរអ្នកឆ្លើយប្រស្នានេះប្រាប់យើង ។

រត្តិយំ អតិអន្ធកោ ។ល។ អយំ អតិតមោ ណាម ហៃកាម! ងងឹងក្នុងរាត្រី មានពពកអ័ព្ទអន្ធការ ពុំមានរស្មីព្រះចន្ទនឹងផ្កាយ ឈ្មោះថា អតិតមៈ ងងឹតក្រៃលែងជាងងងឹតអ្វីទាំងពួង ។

កាមស្ដាប់ហើយពោលថា អ្នកឯងពុំដឹងអ្វីទេ ដូច្នោះយើងនឹងដណ្ដឹងប្រស្នាជាគំរប់ ១២ តទៅទៀត; ឥមស្មិ លោកេ សទេវកេ ។ល។ អតិរុច្ចតិ សភាពអ្វីរុងរឿងធ្លិនធ្លៅ ក្នុងលោកនេះព្រមទាំងទេវលោក? ។ល។

អ្នកឆ្លើយថា ម្នាលកាម! ព្រះអាទិត្យរុងរឿងក្នុងពេលថ្ងៃ ព្រះចន្ទរុងរឿងក្នុងពេលរាត្រី របស់ទាំងពីរនេះរុងរឿងជាងអ្វីទាំងអស់ ។

កាមស្ដាប់ហើយថា ឱ! អ្នកអើយ! អ្នកនេះជាអ្នកអន្ធពាលមែនពុំដឹងអ្វីឡើយ, ដូច្នោះចូរឆ្លើយប្រស្នាទី ១៣ តទៅទៀត; ម្នាលអ្នក! ក្លិនឫមក្ដី ក្លិនសម្បកក្ដី ក្លិនស្លឹកក្ដី ឬក៏ផ្លែនិងផ្កាក្ដី តើក្លិនអ្វីក្រអូបជាងក្លិនគន្ធជាតនេះ? ។

អ្នកឆ្លើយថា ម្នាលកាម! បណ្ដាគន្ធជាតទាំងអស់ មានស្បែកឈើ ខ្លឹមឈើជាដើម ពុំស្មើនឹងក្លិនសាច់ជាទីត្រេកចិត្តសត្វទាំងឡាយឡើយ ព្រោះក្លិននេះ ក្រអូបលើសលែងក្លិនទាំងពួង ។

ក្ដាមឆ្លើយថា អ្នកឯងដោះប្រស្នានេះ ពុំត្រូវទេ អ្នកឯងដឹងតែខាងស៊ី; ទើបក្ដាមសួរប្រស្នាទី ១៤ តទៅទៀតថា ក្រិនអ្វីស្អុយជាងគេក្នុងលោកនេះ ? ។

ក្អែកឆ្លើយថា លាមកមនុស្សស្អុយជាងគេក្នុងលោកនេះ ។

ក្ដាមសួរប្រស្នា ទី ១៥ តទៅទៀតថា អ្វីខ្លាំងជាងគេក្នុងលោក ។

ក្អែកឆ្លើយថា ព្រះនារាយណ៍ខ្លាំងជាងគេក្នុងលោក ។

ក្ដាមពោលថា ម្នាលក្អែក! អ្នកឯងថា ព្រះនារាយណ៍មានកម្លាំងច្រើននោះ ពុំត្រូវឡើយ អ្នកនេះល្ងង់អ្វីមាលព្យាយ ចេះតែខាងស៊ីទេ, ទើបក្ដាមសួរប្រស្នាទី ១៦ តទៅទៀតថា អ្វីឆ្ងាយជាងគេ ក្នុងលោកនេះ ? ។

ក្អែកឆ្លើយថា ចក្រវាលឆ្ងាយលើសអ្វីទាំងអស់ សត្វបក្សបក្សាហើរទៅពុំដល់ឡើយ ។

តំ សុត្វា កក្កដកោ ក្ដាមស្ដាប់ពាក្យនោះហើយ និយាយថា នេវ តំ ជានាសិ អ្នកឯងពុំដឹងអ្វីទេ ទើបក្ដាមសួរប្រស្នាទី ១៧ តទៅទៀតថា អ្វីរហ័សជាងគេក្នុងលោកនេះ ? ។

ក្អែកឆ្លើយថា ខ្យល់ព្យុះសង្ឃរាហ័សជាងអ្វីទាំងអស់ ។

ក្ដាមសួរប្រស្នាទី ១៨ តទៅទៀតថា អ្វីប្រសើរជាងគេក្នុងលោកនេះ?

ក្អែកឆ្លើយថា ព្រះឥន្ទ្រាធិរាជប្រសើរជាងគេទាំងអស់ ។

ក្ដាមស្ដាប់ហើយនិយាយថា ម្នាលក្អែក! អ្នកឯងពុំដឹងអ្វីទាំងអស់ បានតែខាងបោកបញ្ឆោតគេស៊ី ដូច្នោះ ចូរឆ្លើយប្រស្នាទី ១៩ តទៅទៀត; ម្នាលក្អែក! ខ្ទឹមអ្វីប្រសើរលើសខ្ទឹមដទៃ? ។

ក្អែកឆ្លើយថា ខ្ញុំមានខ្ទឹមលើសអ្វីដទៃទាំងអស់ ព្រោះខ្យល់បក់មកក្ដី ភ្លើងព្រៃក្ដី ពុំអាចធ្វើខ្ញុំឲ្យវិនាសបានឡើយ ។

ក្ដាមឆ្លើយថា ពុំត្រូវទេ, ចូរឆ្លើយប្រស្នាទី ២០ តទៅទៀត, ម្នាលក្អែក! រសអ្វីប្រសើរជាងគេទាំងអស់? ។

ក្អែកឆ្លើយថា រសបាយកោដសាលី នឹងសាច់ ប្រសើរជាងរសទាំងអស់ ។

ក្ដាមបានស្ដាប់ហើយ តិះដៀលក្អែកថា កាក អន្ធពាល ម្នាលក្អែកអន្ធពាល! អ្នកឯងជាអ្នកអប្បឥតប្រាជ្ញា ឧច្ចជាតុគោ លង់ខ្លៅណាស់ ជេគោ រត ប្រសប់តែខាងស៊ី វញ្ចនកុ-សលោ ឈ្លាសវៃតែខាងបោកបញ្ឆោតអ្នកដទៃ ដោះស្រាយប្រស្នាពុំត្រូវ, ន តយា គមិស្សាមិ យើងនឹងមិនទៅជាមួយអ្នកឡើយ ត្វំ ឯវ គច្ឆាហិ ចូរអ្នកទៅតែម្នាក់ឯងចុះ ។

ក្អែកឮក្ដាមតិះដៀលដូច្នោះ ក៏ស្រដីថា កក្កដ ម្នាលក្ដាម! ប្រស្នានេះ យើងពុំដឹងក៏ពិតមែន មយា សហាយា ប៉ុន្តែ ខ្ញុំមានសំឡាញ់ជាច្រើន គេមានប្រាជ្ញា វចនកុសលា ប្រសប់

មានសំដី ចូរអ្នកទៅជាមួយនឹងយើងៗ នឹងនាំអ្នកទៅ តវៈ បញ្ហាស្ស អត្ថំ ជានិស្សាមិ យើងសោតក៏ចង់ដឹងប្រស្នារបស់អ្នកណាស់ដែរ ៗ ទើបក្ដាមពោលថា បើអ្នកស្រដីពិតមែន យើងនឹងទៅជាមួយអ្នកដែរ ៗ ក្អែកស្ដាប់ហើយ ត្រេកអរតេក ៗ បមា ដោយគំនិតថា បើក្ដាមនេះទៅជាមួយអញ ៗ នឹងនាំទៅកាន់សំណាក់របស់សំឡាញ់អញ លុះដណ្ដឹងប្រស្នារួចហើយ នាំវាទៅឯស្រះធំក្នុងព្រៃ រួចនាំទៅកាន់សំបុកអញៗ នឹងហែកវាស៊ីជាអាហារ ៗ ឯក្ដាមក៏ដណ្ដឹងទៅក្អែកថា សំឡាញ់របស់អ្នកឈ្មោះអ្វីខ្លះ? ៗ ក្អែកប្រាប់ថា ទន្សាយ ១, នាយព្រាន ១, ក្ងោក ១ ស្វា ១, ខ្លាធំ ១, កិន្នរ ១, ទេព្ដា ១ ៗ ក្ដាមសួរថា បើយើងទៅជាមួយអ្នក តើទៅដោយវិធីដូចម្ដេច? បើអ្នកហើរទៅដោយស្លាប យើងដើរដោយដី ៗ ក្អែកប្រាប់ថា យើងយកជើងយើងទាំងពីរកៀរគៀតអ្នកទៅ ៗ ក្ដាមឆ្លើយថា ជើងអ្នកទាំងពីរទន់ចុះ យើងនឹងធ្លាក់ស្លាប់ពុំខាន, បើយើងយកដង្កៀបរបស់យើងពីរតោងកអ្នក សឹមអ្នកហើរទៅ, ដូច្នេះ យើងពុំមានភ័យឡើយ ថាបើអ្នកព្រមផង យើងក៏ព្រមទៅ បើអ្នកមិនព្រម យើងពុំទៅឡើយ ៗ ក្អែកស្ដាប់ហើយ ឈរទេនក្បាលចុះ ៗ ក្ដាមយកដង្កៀបទាំងពីរតោងកក្អែកជាប់ ៗ ទើបក្អែកនាំហើរឡើងទៅលើអាកាស ទៅកាន់សំណាក់ទន្សាយជាមុន ៗ (នៅមានត)

## ផ្នែកអក្សរសាស្ត្រ

# រឿងហង្សយន្ត

(តមក)

លោក អឹម–ភន បម្រុងពិសាស្ត្រាស៊ីករត

## បទភុជង្គលីលា

នេះបទប្រាកដចងជា ភុជង្គលីលា ថ្លែងនិទានទៃ ៗ ទឹងថ្លែង
សំដែងស្រដី ដំណើរអំពី ក្សត្រមួយនោះណា ៗ នគរបវរ
សីមា សន្ធតនាមា ពារាណសី ៗ ព្រះអង្គស្ដេចទ្រង់រិទ្ធី ជាចៅ
បុរី នាមព្រះព្រហ្មទត្ត ៗ សម័យថ្ងៃមួយមហាក្សត្រ ស្ដេចចិន្តាថ្វាត់
ប្រពាតព្រឹក្សា ៗ រេហ៍ពលសកលយោធា មន្ត្រីសេនា ហែព្រះជៀស្ល
ជ័យ ៗ ស្ដេចដល់មណ្ឌលព្រឹក្សព្រៃ ព្រះបាទក្សត្រថ្លៃ ប្រពាតសប្បាយ ៗ
ទីឋានហិមពាន្តព្រៃឆ្ងាយ រលវៃងលោះលាយ ឈើផងច្រើនពណ៌ ៗ
ស្រះស្រង់គុំពងរីកចល្អ ស្ទឹងបឹងបវរ ខ្ពង់ខ្ពស់ខ្វែងខ្វាត់ ៗ ព្រះពាយ
រំភើយផាយផាត់ ព្រះអង្គមហាក្សត្រ ក្រសាលក្សេមក្សាន្ត ៗ ព្រះបាទ
នរនាថថ្កើងថ្កាន ស្ដែងស្ដេចលុះបាន ដល់ដើមក្រស្នា ៗ ក្សណនោះ
ស្ដេចផ្ទោះនេត្រា យល់ពជកុមារ ពិសេសពិស័យ ៗ អស់អង្គផូរផង់

ពេកក្រៃ នាងនាថបុត្រី បទុមកេសរ ។ ក្សត្រថ្លៃព្រះទ័យសាទរ
ស្តេចយកព្រះករ បីបុត្ររតន៍ផ្គង់ ។ រាជាទតនាអស់អង្គ យកព្រះទំរង់
រតន៍មានដំឡៃ ។ ចងនាហត្ថាបុត្រថ្លៃ ក្សិណក្សត្រជៀសជ័យ ត្រេក
សោមនស្ស ។ បន្ទូលមធុរត្រាស់ថា រីកូននេះណា មិនកូនក្រស្តផង ។
បុត្រមហាក្សត្រាច្បាស់ច្បង ស្តែងស្តេចគ្រប់គ្រង នគរធំក្តាត់ ។ ទើប
បានសួរកាណិកៃវរតន៍ ត្បូងពេជ្រវិក័តិ ចងជាសំគាល់ ។ កត្រា
សោភាពីពេណិ សោតជាបន្ទាល់ ទៀងប្រាកដក្តាត់ ។ សេចក្តីហេតុអ្វី
វិបត្តិ បានជាប្រាសព្រាត់ មាតាបិតា ។ ជាក័ព្វអញតាប់ហើយណា
អញរើសយកជា កូនធម៌អញហោង ។ អញឲ្យសេពសោយរាជ្យគ្រង
ជាស្តេចស្តែងស្នង អង្គអញឯងណា ។ ក្សត្រក្សាន្តស្តេចបានបុត្រា
ហើយព្រះរាជា ផុំបរិពារពល ។ ស្រាប់ស្រេចស្តែងស្តេចបានដល់ ទី
ឋានមណ្ឌល មណីកេងរតន៍ ។ ពុំលង់ព្រះអង្គមហាក្សត្រ ស្តេចឲ្យ
ជញ្ជូត ព្រលឹងបុត្រា ។ ចរិបូណ៌ពុំយូរឡើយណា សម្តេចរាជា
រើសរកមេនិ ។ រក្សាបុត្រាឧត្តម អង្គុយជិតជុំ នូវបរិពារផង ។
ភាពួករួមរក្សាគ្រង មិនឲ្យមានហ្មង ដល់តិចឡើយណា ។ ក្សិណក្សត្រ
ព្រហ្មទត្តរាជា ទ្រង់ព្រះចិន្តា ក្នុងព្រះហឫទ័យ ។ បុត្រាពុំងារថ្មីមៃថ្ង
អញរើសនៅនៃ ក្រោមដើមក្រស្នា ។ អស់អង្គធុំហួងដូចផ្កា រួសរស
គន្ធា ពិដោរល្វេងល្វើយ ។ ស្តេចគិតក្នុងចិត្តស្រេចហើយ ក្សត្រា

ត្រាណត្រ័យ បើកបន្ទូលថា ៗ សន្ធត់ប្រាកដនាមា ស្ដេចឲ្យហៅថា
ចៅគ្រឹស្នាកុមារ ៗ យើងថ្លែងសំដែងពីកាល សម្ដេចភូបាល ព្រហ្ម
ទត្តពជា ៗ រើសបុត្រពិសុទ្ធសោភា ដំណើរនេះណា យើងស្វែះ
ក្សិណហោង ៗ យើងនិយាយពីដើមវង្ស ដំណើរទំនង នាងនាថឧត្ដម ៗ
ក្សត្រីមហេសីសួស្ដីសម នាងនាថបទុម-កេសរមិញណា ៗ នាងនាថ
សង្វាតយាត្រា ក្នុងព្រៃព្រឹក្សា រកព្រះបាទបង់ ៗ អស់កលពុំយល់ជាមួង
នាងវិលវិងផ្គង ដល់ដើមគ្រឹស្នា ៗ នាងរកពុំយល់បុត្រា នាងគក់ទុក
សោយសោកសល់ក្រៃ ៗ ឈើធៀបហាក់ហៀបទីងក្ស័យ ហេតុនាង
អាល័យ ឈើជ្រិតបុត្របាត់ ៗ នាងវែងផ្កាផ្សងក្ដៅក្ដាត់ ញ័ររង្វើមប្រមាត់
ស្លុតសរសៃសាច់ ៗ ហាក់អ្នកប្រឡាក់ប្រហាច់ យកវិទ្ធូរម្រេច ញាំញីប្រ-
បល់ ៗ នាងឈើជម្ងឺខ្ទាំងសល់ សោកសោះជាលផល់ ដួលសន្ធប់លង់ ៗ
នៅនាឍកឯកអង្គ ឯងឥតចិត្តលង់ ទើបនាងនាថក្បាក់ ៗ ស្មារតីក្សត្រី
អួលអាក់ ទឹកភ្នែកសស្រាក់ ដោយព្រៃសស្រោច ៗ កក្រោកទុករស
ល្អោច ដូចកលគេបោច ពុងពោះបោះបង់ ៗ ក្សត្រីទេវីរម- ង្គលគក់ទ្រូង
ទ្រង់ កន្ទ្យង់សោកា ៗ នាងខ្ទួញខ្ទួញថ្លែងថា ឱកូនស្ងួនក្ស ព្រលឹង
មាសម្ដាយ ៗ ម្ដេចបាបុត្រាពណ្ណពយ ប្រែប្រាសព្រាត់ឆ្ងាយ ពីទ្រូង
ម្ដាយទៅៗ ម្ដាយប្រាសនិពសព្រះចៅ លែងបានបានៅ ជាពីរនាក់ណា ៗ
ឥឡូវម្ដាយនៅកំព្រា ប្រាសម្ដេចតាំងបា បណ្ដូលថ្មើមថ្ងៃ ៗ កូនអើយ

ម៉្ទេះហើយពីថ្ងៃ នេះសមម្ដាយក្ស័យ ជីវិតហោងណា ។ ដៀតប្រាសនិរាស

បិតា ហើយប្រាសទាំងបា ពន្លកហ្ឫទ័យ ។ សូវស្លាប់គួរគាប់ជាក្រៃ

រស់នៅចេះនៃ តែឯងរងទុក្ខា ។ បើរស់ជាមនុស្សចេះណា រស់ឯងវេរា

ទល់ទុក្ខក្រាស់ក្រៃ ។ កូនស្ងួនខ្ញុំមខ្លួនថ្ងើមថ្ងៃ ម្ដាយក្រែងមួយនៃ សត្វ

ធ្ងន់ពាធា ។ មាសថ្ងៃប្រពៃពុំងា នាំយកទៅជា អាហារចំណី ។ ទុបាបក្រ

ភ្ញាពិសី ម្ដាយគិតក្រែងបី- សាចផងទាំងឡាយ ។ យកបាពុំងាតាមឆាយ

ទៅទុកឋានឆាយ ដំបន់នានា ។ ឱស្ងួនខ្ញុំមខ្លួនពុំងា ម្ដាយក្រែងទេព្តា

ទេព្រ័ក្សនោះផង ។ លាក់បាស្ងួនក្ងាស្នេហ៍ស្នង ឱម្ដាយតែឯង ទុក្ខទៀង

ធ្ងន់ក្រៃ ។ ម្ដាយឈ្មួងគិតឯងមួយនៃ ខ្លាចក្រែងថ្ងៃរៃព្រៃ ត្រាប់ត្រង់

ហើយណា ។ មកដល់យន់យល់ស្ងួនក្ងា ហើយរើសបាទបា នាំទៅ

ឋានឆ្ងាយ ។ ក្រឹស្នាសាខាត្រសាយ ឈើនេះដែលម្ដាយ ផ្តកបំប៉ៅបា ។

ម្ដាយអ្នកចាំជាក់ណាស់ណា ឃើញតែក្រឹស្នា ដែលម្ដាយឈប់នៅ ។

ម្ដេចប្រាសកូនមាសផ្អិនផ្អៅ ពីទ្រូងម្ដាយទៅ បាតបង់ឃ្លាតឃ្លា ។

ម្ដាយស្រែករកអ្នកត្រង់ណា ឲ្យម្ដាយយល់បា ដូចចិត្តបំណង ។ ឱស្ងួន

ខ្ញុំមខ្លួនឥតគង់ កូនអើយនេះមង ម្ដាយគិតពុំយល់ ។ ទ្រូងម្ដាយឈឺ

សាយ័សព្វសល់ បុត្របាត់ពុំយល់ មុខមាសថ្ងើមថ្ងៃ ។ នាងសោក

អាមោក្សពេកក្រៃ នាងរៃឯសក្រៃ បុត្រថ្ងៃបាត់បង់ ។ ក្សត្រីទេវីរវៀង

លើកទសករផ្គង់ ដាក់លើសិរ ។ ឱន្ទាទេពសព្វ ទេព្រក្សប៉ិគង

ព្រះព្រៃព្រឹក្សា ។ ក្សត្រីប្រណិធានថា បពិត្រទេព្តា ទេព្រឹក្សនៅនៃ ។
ទីឋានហិមពាន្តព្រះព្រៃ ផងអ្នកដទៃ បិតព្យះសោឡសសួគា ។ សូម
អ្នកកុំហាក់បុត្រា អ្នកប្រាប់ខ្ញុំពី ឲ្យខ្ញុំបានយល់ ។ កូនស្ងួនខ្ញុំមខ្ញួន-
និមល សោះខ្ញុំតែឯងទល់ ទុក្ខដូចខ្លះណា ។ ក្សត្រីទេវីសោកា
អង្វរទេព្តា ទេព្រឹក្សនោះផង ។ សម្រេចស្រាប់ស្រេចហើយហោង
នាងចិន្តាផ្គង នឹងតាមបុត្រា ។ ស្រីគន់នាងគន់ព្រឹក្សា ក្រោមដើម
ក្រឹស្នា យល់ស្នាមដើងជាន់ ។ នៅនាឆាកជាក់ស្បាន់ នាងគិតគ្នេរ
គ្នាន់ ថាមនុស្សនេះនៃ ។ ពាមករះរកលេងព្រៃ ពារើសបុត្រថ្លៃ អញ
មែនពិតណា ។ នាងនាថវិឃាតយាត្រា តាមបុត្រស្ងួនភ្ងា ដោយ
ជាននោះនៃ ។ ក្សត្រីទេវីគន់ថ្លៃ ដើរដោយដងព្រៃ ហិមពាន្តនោះ
ហោង ។ ឈូងធកជ្រោះប្រកជ្រលង អស់ទាំងម្រឹគផង ដើរដោយ
ហ្វូងក់ ។ ស្រីថ្លៃប្រពៃសោកា នាងនាថយាងយា- ត្រាត្រាច់យង់
យល់ ។ រាជសីហ៍ចេញពីមណ្ឌល គុហាថ្កើងថ្កល់ សីហនាទចេញ
ចរ ។ មើលឡើងព្រៃប្រើងឈប់ឈរ ដោយព្រឹក្សាគរ សិពន្ត-
អាត្មា ។ គជសីហ៍ដំរីលៀងកា ដើរដោយហ្វូងក់ រិះរកគោជ្ឈក័ស្ត ។
ដំរីរកស៊ីដេរដាស គោគគៀងពេញពាស ខ្លាឃ្លាស៊ីថ្លាយ ។ រមាំង
ខ្ញីងខ្លាធំប្រើសព្រាយ ញៀងញីងក្សីរខ្យាយ ដោយពណ៌ទីទៃ ។ តាំង
មហឹសាក្រាស់ក្រៃ ទនេន្សាងគោព្រៃ ឈ្លូសរមាសខ្លា ។ សំពោច

ទាំងពោចស្មានស្មា ចចកប្រមា ទន្សាយសោកនៃ ។ ម្រឹគគឹកច្រើន
ក្រៃ ដើរដោយដងព្រៃ ដោយដងថ្នាក់ថ្នល់ ។ ខ្លះស្រប់ខ្លះឈប់ខ្លះ
ដល់ គ្នាឯងអស់កល ខ្លះគៀងគ្នា ។ ខ្លះព្រាត់កូនបាត់ឃ្មាតឃ្មា
រត់រកកូនវា ពុំឃ្មានស៊ីស្មៅ ។ ខ្លះយល់កូនដល់ឈប់នៅ អត់ឲ្យ
កូនបៅ ឆ្អែតឆ្អន់ស្កប់ស្កល់ ។ ក្សត្រទេវីនិមិល នាងរត់ទៅយល់
អស់ទាំងម្រឹគផង ។ នាងរែងកណ្តែងកន្ទុង សោយសោកក្តាត់ហោង
ពិលាបខ្ញួញថា ។ ឱសត្វនេះព្រាត់កូនវា ដូចអញឯងណា ព្រាត់កូន
បាត់បង់ ។ កូនស្ងួនខ្ញុំមខ្លួនសាច់ស- ង្សារសូន្យនាក្នុង ព្រះព្រៃ
ព្រឹក្សា ។ សត្វខ្លះប្រទះកូនវា កូនសោកម្ចមា រត់រកបៅមេ ។ ឱអញ
រែងម្ទេញឥតល្ហៃ ប្រាសកូនមាសស្នេហ៍ សោះសូន្យពុំយល់ ។
កូនអើយម៉្លេះហើយម្តាយទល់ ទុក្ខទៀងលុះដល់ ក្សណក្ស័យជន្មា ។
ឱស្ងួនខ្ញុំមខ្លួនមាតា ម៉្លេះហើយសមបា ទឹងអត់ទឹកដោះ ។ ម្តាយទឹក
ព្រួកដើមនោះ កូនអើយពុំងពោះ ម្តាយរែងខ្ទោចផ្សា ។ ក្សត្រខ្មី
ឃ្មាតឃាំងយា- គ្រាគ្រាចលើលា កណ្តាលហ្វូងសត្វ ។ នាងសោក
អមោក្សពេកក្តាត់ នាងនាចពុំគិត ខ្មាចខ្លួនឡើយណា ។
គេជៈព្រះបារមិតា នាងសាងច្រើនគ្រា ថ្លែងថ្លែងពុំបាន ។ ទេវតា
នៅនាហិមពាន្ត សឹងសព្វពិមាន សោឡសស្ទួគ៌ា ។ សឹងតែៈ

ជ្រោមព្រៃនរេក្ខ វិវេកទំជាយា ប្រក្រតីទៅហោង ៗ ហ្វូងសត្វ

ច្រើនក្តាត់កន្ទង ពុំអាចឃើសឃ្លង ចៀតចៀននាងណា ៗ

## បទព្រហ្មគីតិ

ក្សណៈនោះនាងទេវី អគ្គមហេសីវរជាយា នាងតាមរាជបុត្រា
ក្រាចក្នុងព្រៃព្រះហិមពាន្ត ៗ ឈើផងៈសាតច្រើនពណ៌ សត្វវង្គារ
ទំសម្រាន្ត គៀងគូយំសព្វសារិន រលោតលេងលើដើមព្រឹក្សព្រៃ ៗ នាង
យល់អស់បក្សា នាងសោកា-សោកាក្រៃ ទូញរៀព្រះដៀស្វ័យ
នូវទំនួញនោះឯងថា ៗ ឱព្រះបាទបពិត្រ ធ្លាប់តែងស្និទ្ធ-ស្និទ្ធស្នេហា
រួមឯក-ឯកអង្គា មូលមណ្ឌលទីងប្អូនស្រី ៗ នេះម្តងម្តេចព្រះមាស
មិត្តប្រែប្រាស-ប្រាសទិកស ទិកសចាកចេញពី ទ្រង់ប្អូនទៅ
អសារសល់ ៗ ខ្ញុំប្រាសពីព្រះបង កំខ្វល់-វង់ទុក្ខល់ ហើយប្រាស
ប្រាសពុំយល់ តាំងកូនស្ងួន-ស្ងួនស្នេហ៍ស្ងួន ៗ ប្អូនតែងឃើផ្កាសល់
ម្តេចមកយល់-យល់សត្វផង តាំងពីរហោះត្រសង ទៅទំលងៈលើព្រឹក្ស
ព្រៃ ៗ ឱបាន-បានក្រឹស្មា ដើមសាខាលាស់លូតលៃ ទ្រង់ផ្កា-ផ្កា
ប្រពៃ រីករុះពេយដោយដាព ៗ ពិដោរដូចអ្នកអប់ ផ្កុំក្រឡប់តាំង
ដាព ត្រសៀកផាត់ពាំតា បក់លំៈទោន-លំទោនទង ៗ ហង្សហើរ

លើទាំងគូ ទៅទំនៅរុក្ខាហោង ចឹកចាប់-ចាប់ផលផង ហើរទៅទំ.
ទំទាំងគូ ៗ ខព្រះ.ព្រះបពិត្រ ធ្លាប់វែងបិត-បិតខែបនៅ នឹងប្អូនម្តេច
ឥឡូវ ព្រះប្រែប្រាស-ប្រាសពុំយល់ ៗ ខដើម-ដើមក្ទាំពាក់ ធំត្រ
សាក់ត្រសាយសល់ ទ្រង់ផ្កា.ផ្កាទិមល ពិដោរក្រៃ.ក្រៃពេកណា ៗ ទៀវ
ហើរ.ហើរទៅទំ ទំយាសយំរកគូវ ដូចអង្គអញឯងណា ទៀងទូញ
រកព្រះរៀមថ្ងៃ ៗ ខដើមកល្បព្រឹក្ស លូកសាស់ស្លឹក.ស្លឹកល្អក្រៃ
ទ្រង់ផ្កា ផ្កាប្រពៃ ប្រពៃពេក-ពេកកន្ទុង ៗ រុះកេយដាសដោយដី ធុំ
ក្លិនពិដោរល្អប់ល្អង ព្រះពាយបក់ទទួង ធុំត្រឡប់ទាំងទិសា ៗ មយូរ
ទំយាសយំ យំរងំច្ចើយចុងគ្នា ប្រគៀង-គៀងគូវ រាំចិកចាប់បុប្ផាផល ៗ
ចម្ប៉ា.ចម្ប៉ាទុំ ទុំត្រសុំត្រសាយសល់ មានផ្កា-ផ្កាខិមល ធុំក្រអូបក្រ
វែមបណ្ឌូប ៗ មយូរ.មយូរចឹក ចាប់កល្បព្រឹក្សបរិភោគស្កប់ ហើយ
ហើរ.ហើរទៅឈប់ នៅនាដើម.ដើមចម្ប៉ា ៗ ខប្អូនយល់បក្សី ទាំង
ឈ្មោលញីគៀងគូវ ប្អូនផ្អក.ផ្អកឈឺផ្សា ឈឺខ្លា.អួលក្តៅក្តាត់ ៗ ខ
ព្រះបាទចមទៅ ធ្លាប់វែងនៅ.នៅនៃវនិត្យ ធ្លាប់ស្នាល.ស្នាលស្នេហ៍
ស្និទ្ធ ស្និទ្ធនៃបនិត្យនឹងប្អូនខែ ៗ ឥឡូវម្តេចព្រះអាស មកប្រែប្រាស-
ប្រាសទីទៃ ប្អូនផ្អក.ផ្អកអាល័យ អាឡោះលន់ពន់ពេកណា ។ ខដើម
ដើមកាកែស ល្អពិសេសទ្រង់បុប្ផា ខសត្វ-សត្វសារិកា ហើរទៅទំ.ទំ
លោតលេង ៗ មាក់ប៉ែន-មាក់ប៉ែនធំ ផ្លែសោកទុំ.ទុំរុះឯង ពិដោរ

ពិដោរល្វេង នូវក្លិនផង-ផង៖ត្តម ៗ សារិកា-សារិកាមើល មើលហើយ

ហើរ-ហើរទៅទំ ទំហើយ-ហើយយាសយំ យំហើយប-បរិភោគផល ៗ គួ

គាន-គួគានគន់ ផ្កាល្អលនពិសេសសល់ ហើយទ្រង់-ទ្រង់នូវផល ផល

ប្រសើរ-ប្រសើរក្រៃ ៗ សេកហើរ-ហើរទៅទំ ទំសម្ងំ-សម្ងំញ

គួគាន-គួគាននៃ ទំទាំងគូ-ទាំងគូរ ៗ ៖ដើម-ដើមសុក្រំ លាសគ្រសុំសឹង

ទ្រង់ផ្កា មានផល ផលផងជា ជាចង្កោម-ចង្កោមទង ៗ ស្រគំស្រ

គាលផល សេកសោមយល់-យល់ហើយហោង ហិចហើរ-ហើរត្រ

សង់ ចេញពីដើម-ដើមគួគាន ៗ រន្ទេប-រន្ទេបទំ នៅទ្រទំសូរសព្វ

សារិន បរិភោគផលផងមាន សេពិសា-ពិសាសល់ ៗ ប្អូនឃើញ

ឃើញបក្សា ប្អូនសោកា-សោកាសល់ ប្អូនផ្អក-ផ្អកគិតដល់ ដល់ព្រះបាទ

ព្រះបាទបង ៗ ធ្លាប់នាំ-នាំនៃបនិត្យ និត្យស្នាលស្និទ្ធ-ស្និទ្ធស្នេហ៍ស្នង

៖ឥឡូវនេះម្តង ក្រោតប្រែប្រាសពីប្អូនថ្ងៃ ៗ លលក-លលកហើរ

ហើរហើយមើល-មើលរំពៃ ចុះទំទ្រទំក្រៃ ឮលើដើម-ដើមរំដួល ៗ រំដួល

រំដួលផ្កា មានផលាដូចគេព្យួរ លលក សាតសៀស្នួ ទៅទំលេ-

លើក្តោ ៗ ៖ប្អូនយល់លលក យាសយំរក-រកគូរ ប្អូនផ្អកស្រ

ណោះណា ឱឱព្រះមាសប្អូនអើយ ៗ ប្អូនឈឺអន់អួលអាក់ ប្អូនរកអ្នកពុំ

យល់ឡើយ ឱអម្ចាស់ប្អូនអើយ អ្នកនិត្យនៅ-នៅឯណា ៗ ឱសត្វ

សត្វទុកទ្រ ទំទាំងគូ-ទាំងគូរ លើដៃជ្រ-ដៃជ្រសាខា ជាដំណោក-ដំណោក

ទៅ ៗ បរិភោគ-បរិភោគផល ផ្អែតស្កប់ស្កល់ហើយហើរទៅ ខ្ទះទំ-ទំនិត្យ

ទៅ ទៅទាំងគូ-ទាំងគូណា ៗ ឱសត្វ-សត្វបក្សី ដែររកស៊ីទាំងគូរា

ឱអញម្ដេចឃ្លាតឃ្លា នឹងព្រះបាទព្រះភូមី ៗ ប៉ោលគោកហិចហើរ

ទៅ ទៅទំនៅ-ដើមស្មុក ទាំងគូគៀងឈ្មោលញី ស៊ីហើយយំ-

យំលើងល្ហើយ ៗ ឱប្អូនព្វសព្វសត្វ ប្អូនអាណិតណាស់អ្នកអើយ

ដ្បិតប្រាសព្រះគ្រាណាគ្រើយ ពីទ្រង់ប្អូនអសារសោះ ៗ ម្ដេចឡើយ

ព្វសព្វសត្វ យំស្រងាត់ឲ្យអាឡោះ ឱប្អូនដែងស្រណោះ ដែងលង្វង់

លះឡាចលង់ ៗ ប្អូនដែងអន់អួលអាក់ ព្រោះអ្នកណាប្រសកន់ ដែង

ឈឺ-ឈឺចៀបលង់ ឥតឯស្បើយដល់តិចណា ៗ គាពេ-គាពេរ៉ ទៅ

រាំងកំពុំសិងផ្កា ស្ទឹកស្មោម-ស្មោមសាខា គាពើយំរកគូរ ៗ ឱអញ

គួរអនិច្ចា សត្វនេះណាប្រដូចជា អន្ដែអញឯងឯកា កែងខ្លួនគេព្រះ

កជា ៗ រន្ទប-រន្ទបទំ ទាំងគូយំទូរសារិកា ហើយហើរពីនោះណា

ទៅទំលើរដេញមាស ៗ ទ្រង់ផ្កា-ផ្កាក្រពុំ ផលផងទុំរដេរដាស រ

ដេញ-រំដេញមាស សត្វរន្ទប-រន្ទបទំ ៗ ឱប្អូនយល់បក្សា ភាង

គូរ-រយាសយំ ឱឥឡូវម្ដេចខ្ញុំ កំព្រាព្រាត់ព្រះភូមី ៗ ឱព្រាប

ព្រាបព្រៃទំ ទំហើយយំទាំងឈ្មោលញី ខ្ទះសោតរកចំណី មកឲ្យកូន

បរិភោគ ៗ ឱម្ដាយយល់បក្សី រកចំណីឲ្យកូនភ កូនអើយទ្រង់ម្ដាយ

ផង ផ្សព្វទូវទុក្ខពេកណាស់នៃ ៗ ដ្បិតម្ដាយកំព្រាព្រាត់ ប្រាសកូន

វេទន៍ស្ងួនថ្មើមថ្ងៃ ច្រូងម្ដាយឈើក្រៃក្រៃ ទើនថ្ងៃផ្ទឹងតុំបានឡើយ ៗ ការ
វិក-ការវិកយំ យំរងឹសត្តុំល្ហើងល្ហើយ ចាំងគូ្ន-គូ្នហើយ ទំនៅ
លើដើមឫសនាគ ៗ ខ្ញុំប្អូនព្រួសព្រួសត្វ ក្នុងព្រៃស្ងាត់ស្រមៃហាក់ ប្រហែល
ដូចពាក្យអ្នក ព្រះរៀមរក្សដង្ហោយហៅ ៗ ប្អូនវែង-វែងខ្ញុំឃ្លាត ខំ
សង្វាតធ្លោះសំដៅ ដើរត្រាច់ដើរត្រាច់ទៅ យល់ការវិក ការវិកយំ ៗ
ហើយប្អូនវែងឈើផ្កា គក់ទក-ទុកក្រំ ឈើធៀបម្លូលអាក់អន់ ច្រូង
វែងធ្ងន់-ធ្ងន់កន្ទុង ៗ ខុបាបផ្តល់នាជាតិ នេះខ្ញុំឃ្លាតទីងព្រះបង ខ្ញុំសូម
សព្វជាតិផង កុំបីមានហៅឃ្លាតឃ្លា ៗ ជាតិអើយជាតិនេះហោង បើ
ព្រះបងកើតជាតិណា សូមសេពសោយសុខសា-ន្តាយទូរបុណ្យបរិបូណ៌
ក្រៃ ៗ ខ្ញុំប្អូនសូមប្រាថ្នា សូមកើតជាស្រីសួគ៌ថ្ងៃ ប្រកបទីងជៀស្ដជ័យ បាន
ជាខ្ញុំស្វាមីភក្តិ ៗ ជាតិអើយជាតិឯណា ព្រះកើតជា-ជាស្ដេចយក្ស
ហើយខ្ញុំជាប្អូនអ្នក សូមកើតជាស្ដេចយក្សស្រី ៗ អញខ្ញុំសូមប្រាថ្នា
ឲ្យបានជាអគ្គមហេសី ជាតិអើយជាតិណាក្ដី បើព្រះបងស្ដេចកើតជាៗ
រាជហង្សមាសមណី កំប្អូនស្រីសូមប្រាថ្នា ឲ្យបានទៅកើតជា គូទីង
ព្រះបាទកូម៌ ៗ ជាតិអើយជាតិណាហោង បើព្រះបងចាប់បដិ-សន្ធិ
ជារាជសីហ៍ ប្អូនសូមកើតជាគុហា ៗ មាសមានស្នេហ៍ឆ្ងាយ ជាបំនៅ
ព្រះរាជា ស្ដេចគង់ក្សេមសុខសា-ន្តាយក្រសាលព្រះហឫទ័យ ៗ ប្ដី
មួយស្ដេចកើតជា ជាមច្ឆា-មច្ឆាថ្ងៃ ឲ្យប្អូនព្រះជៀសជ័យ សូមកើត

ជាព្រះគង្គា ៗ ថ្វាយធំៈយង់ជ្រះជ្រៅ ជាំលំនៅព្រះពជា ស្ដេចហែល
ហែលលេងណា ក្រសាលឥត-ឥតឯហ្នឹង ៗ ព្រះហើយខ្ញុំប្អូនស្រី ប្រា
ថ្នាពីជាតិនេះមួង សូមសព្វសព្វជាតិផង កុំបីមានហៅឃ្លាតឃ្លា ៗ
ដកបរួចលុះបាន ដល់និព្វាននិរទុក្ខា ព្រះហើយខ្ញុំប្រាថ្នា ឲ្យបានជួបនឹង
ព្រះបង ៗ

## បទកាកគតិ

បទកាកគតិតែង ដំណើរដំណែង អំពីនាងនាថ ទៀងទុញ ព្រះបង នោះហោងសល់ខ្លាត នាងនាថសង្វាត ត្រាច់ក្នុងព្រៃហោង ៗ កាលនោះទេវី វរពដក្សត្រី អនុជស្នេហ៍ស្នង សោយសោកទួញពី ស្វាមីនាងហោង នាងនាថរែងរង ទុក្ខទោមនស្សា ៗ នាងឈឺពីក្ដី មួយឈឺស្វាមី មួយឈឺបុត្រា នាងសោយសោកសល់ ទួញទល់ទុក្ខា នាងត្រាច់រកជា អំឡុងយូរក្រៃ ៗ នាងតាមដោយដាន ដល់ស្រុកពាក- ណសីនោះនៃ គាប់ជួនរាត្រី ឥតបីអាស្រ័យ ក្សត្រីគន់ថ្លៃ នាងខំយាត្រា ៗ ដល់ផ្ទះដូនចាស់ មានសប្បុរសណាស់ ជាអ្នកក្រង ផ្កា ក្សំណនោះក្សត្រី ទេវីគិតថា អញសំចតណា ផ្ទះដូននេះនៃ ៗ ទើបនាងថ្លែងថា អ្នកដូនអ្នកតា . ខ្ញុំសូមអាស្រ័យ សូមផ្ទះដូនឈប់ តែយប់នេះនៃ រួចបានដល់ថ្ងៃ ខ្ញុំលាដូនទៅ ៗ យាយមាលាស្ដាប់

ពាក្យពីរោះគាប់ ៈ ត្រេកអរហើយហៅ នាងអើយយាយអរ នាងចរមក

ទៅ នេះទឹងយាយទៅ អម្ចាស់យាយអើយ ៗ នាងនាថកល្យាណ នាង

ឡើងទៅថ្កាន ផ្ទះដូនចាស់ហើយ វរពជក្សត្រី ទៅត្រាណត្រើយ នាង

គង់ស្រេចហើយ នាងនាថប្រណិប័តន៍ ៗ នៃដូនទឹងតា សម្រេចហើយណា

នាងគង់ស្ងៀមស្ងាត់ ទើបយាយមាលា ចរចាផ្ដេកផ្ដិត សួរក្សត្រីរតន៍

នូវពាក្យនេះថា ៗ អ្នកម្ចាស់យាយ មានរូបឆោមឆាយ អ្នកមកពី

ណា ចូរនាងរៀបរាប់ ប្រាយប្រាប់យាយក៏ នាងអើយយាយអា· សូរ

នាងពេកក្រៃ ៗ នាងនាថឆ្លើយ ថាអ្នកយាយអើយ ខ្ញុំនេះ

នៃ ព្រាត់ប្រាស់ពីប្ដី ស្វាមីថ្មើមថ្លៃ នាមអ្នកនោះនៃ សុវណ្ណកុមារ ៗ

ប្រាសចាំងបុត្រា ទើបប្រសូតជា គំរប់ឫក្សពារ បីនេះទៀតចាត់

ហើយព្រាត់អសារ សូនសោះគន្ធារ ព្រឹក្សានោះនៃ ៗ ដោយបាន

មើលដាន ស្នាមដើងសម្រាន្ត មនុស្សផងដើរព្រៃ រករើសបុត្របាន

នាំថ្កានមកឮ ក្នុងស្រុកនេះនៃ មែនមិនទេឡើយ ៗ ឯយាយមាលា

ស្ដាប់នាងប្រាប់ប្រ- ការដូច្នោះនៃ ទើបគាត់ចរចា ប្រាប់ថានាងអើយ

មហាក្សត្រត្រាណត្រើយ នាមព្រះព្រហ្មទត្ត ៗ ស្ដេចទៅប្រពាត

សម្ដេចនរនាថ រើសរកជបុត្ររតន៍ ព្រះបាទក្សត្រា លីលាវីងថ្វាត់ មក

ថ្កានឋានបិត ស្ដេចឲ្យរើសរក ៗ មេទំក្រមការ រក្សកុមារ បុត្រា

ពន្លក សព្វព្រះហឫទ័យ ក្សត្រថ្លៃឲ្យយក បុត្រាពន្លក មកជាកូន

ធម៌ ៗ នាងអើយពាក្យយាយ ដំណើរប្រាប់ប្រាយ ឲ្យនាងបាន
ស្គាល់ កុំបីនាងថ្លែង ចារចែងទូទេរ ជ្រាបដល់ព្រះភាណី ទ្រង់ព្រះ
គ្រោធក្រៃ ៗ យាយសូមឃាត់នាង នៅនៃអំភ្ទាំង ទើបយាយឯងនៃ
ក្រែងបានជួបជួន កូនស្ងួនថ្មីថ្ងៃ បានដូចហឫទ័យ ចិត្តនាងប្រាថ្នា ៗ
នាងនាថស្ដែងស្ដាប់ ពាក្យពីរពេះគាប ទើបនាងឆ្លើយថា បើអ្នកយាយ
មាន ចិត្តករុណាមេត្តា ខ្ញុំនៅនេះណា ទើបយាយឯងហោង ៗ ឯ
យាយមាលា ពិភក្តិរក្សា ស្រឡាញ់ស្នេហ៍ស្ងួន យកនាងទុកនៅ
ជាចៅទៅហោង មិនមានឲ្យហ្មង ដល់តិចឡើយណា ៗ ឯក្សត្រថ្ងៃ
នាងនៅនេះនៃ ទើបយាយមាលា រំពាជក្សត្រ ទេវីក្រងផ្កា តាង
យាយមាលា ប្រក្រតីសព្វដង ៗ ឯយាយទើបតា បានចៅក្រងផ្កា
ជួយតាំងយាយហោង រីយាយមាលា តែងយាត្រាចង នាំផ្កានាងក្រង
ទៅថ្វាយកជា ៗ

## បទភុជង្គលីលា

នេះបទប្រាកដចង់ជា ភុជង្គលីលា ដោយដានវំនង ៗ ថ្លែង
កាលទេវីនាងក្រង លម្អះហ្មត់ហ្មង រំលេចបុប្ផា ៗ ទើបថ្លែងសំដែង
ពណ៌នា កាលនាងក្រងផ្កា ក្បូរក្បាច់ច្រើនពេក ៗ បុប្ផានានាដក
រែក ច្រើនពណ៌អនេក អនន្តណាស់ណា ៗ

(នៅមានត)

# ព្រោះហេតុអ្វីបានជាសត្វសេក ត្រាប់ពាក្យមនុស្ស តែមួយម៉ាត់ៗ ជាពាក្យឥតន័យ?

ដោយភិក្ខុ ម៉ែន-រៀម សិស្សពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ

ក្នុងអតីតកាល សត្វដែលគេរក្សាទុកក្នុងផ្ទះ ហើយបង្ហាត់បង្រៀនឲ្យចេះនិយាយនោះ មិនតែសត្វសេកទេ គឺមានបក្សីម្យ៉ាងទៀតហៅ លោរិកេត(១) ។

ដោយមនុស្ស បានដឹងថា បក្សីតូចនេះ ជាសត្វឆ្លៀវឆ្លាសវាងវៃ, ម្ល៉ោះហើយ គេត្រូវការបង្ហាត់បង្រៀនវាតែបន្តិចបន្តួចប៉ុណ្ណោះ ។ បក្សីនេះ បើវាឮពាក្យអ្វីមួយ, វាអាចធ្វើត្រាប់បានដោយស្រួល ហើយមិនត្រឹមតែប៉ុណ្ណោះ វាថែមទាំងអាចនិយាយ បញ្ចេញគំនិតផ្ទាល់របស់វាទៅរកមនុស្ស ជំនួសការធ្វើត្រាប់សំឡេង ដែលវាបានឮជុំវិញខ្លួនវាថែមទៀតផង ។ ប៉ុន្តែសភាពទាំងនេះ បានផ្លាស់អស់ទៅ នៅគ្រាមួយ ៖

ថ្ងៃមួយ គេដំណាលថា មានកសិករម្នាក់ បានឃើញក្របីមួយ ត្រាច់ឆ្ពោតទៅក្នុងស្រែរបស់ខ្លួន ។ ក្របីនេះ ជារបស់អ្នកជិតខាងម្នាក់នៃកសិករនោះ ប៉ុន្តែបើទុកជាដូច្នោះក៏ដោយ កសិករបានចាប់ក្របីនោះយកទៅសំឡាប់, ពន្លះសាច់ ចំអិនបរិភោគ, សល់ប៉ុន្មាន កសិករយកទៅលាក់ទុក ។ សាច់មួយចំណែក គាត់លាក់ទុកលើធ្នើរផ្ទះបាយ

---

(១) សត្វនេះ នៅក្នុងសន្តានសេក, តែតូចជាងសេក ។

ហើយចំណែកដែលសល់ពីនេះ គាត់លាក់ទុកក្នុងរាវចាន ។

ថ្ងៃក្រោយមក, អ្នកជិតខាងនោះ បានដើរមករកក្របីរបស់គេ បាន សួរកសិករថា:

"អ្នកបានឃើញក្របីខ្ញុំទេ?"

"ទេ, ឥតឃើញទេ", កសិករឆ្លើយ ។

ខណៈនោះ បក្សីលោរិកេត របស់កសិករ ក៏និយាយឡើងថា:

"ក្របីនោះ ម្ចាស់ខ្ញុំសំឡាប់ទៅហើយ, គាត់បរិភោគខ្លះ លាក់ទុកខ្លះ ; សាច់មួយចំណែកគាត់លាក់នៅក្នុងរាវចាន ហើយមួយចំណែកទៀត គាត់លាក់នៅលើធ្នើរផ្ទះបាយឯណោះ!" ។

ឮដូច្នេះ, អ្នកជិតខាងនោះ ក៏ទៅរកមើលគ្រង់កន្លែងដែលបក្សីប្រាប់ ក៏បានឃើញសាច់ក្របី ក្នុងទីនោះមែន ។ ប៉ុន្តែ កសិករបាននិយាយថា :

"បា១! ទីនេះ ជាកន្លែងដែលខ្ញុំតែងតែទុកសាច់, ក្របីអ្នកខ្ញុំមិនឃើញទេ, ឯសាច់នេះ ជាសាច់សត្វដទៃទៀតទេ!" ។

បក្សីលោរិកេត បានស្រែកឡើងម្តងទៀតថា:

"គាត់សំឡាប់វា! សាច់មួយចំណែកគាត់លាក់ទុកនៅក្នុងរាវចាន មួយចំណែកទៀត គាត់លាក់នៅលើធ្នើរផ្ទះបាយឯណោះ!" ។

អ្នកជិតខាងនោះ ក៏ទៅជាឡប់គំនិត មិនដឹងថា តើត្រូវយកតាមពាក្យមនុស្ស ឬ តាមពាក្យបក្សី ។ ម្ល៉ោះហើយ គាត់ក៏យករឿងក្ដីនេះ ទៅប្ដឹងតុលាការ ។ សំណុំរឿងនេះ ត្រូវគេសំរេចការកាត់សេចក្ដី នៅថ្ងៃណាមួយ ជាខាងក្រោយមកទៀត ។

កសិករដែលបានលួចក្របី និយាយទាំងខ្ទុងឯងថា: "ហេតុដូចម្ដេចបានជាគេយកតាមពាក្យលោកគេត ជាងពាក្យអញ ! " ។

រាត្រីនោះ កសិករ បានចាប់បក្សីលោកគេតចេញពីទ្រុងរបស់វា ហើយយកទៅដាក់ក្នុងកាជន៍ទៅលើស្ពានធំមួយ ។ គាត់គ្របកាជន៍ ដោយក្រណាត់យ៉ាងជិតងងឹតសូន្យខាងក្នុង ។ ឯខាងក្រៅវិញ ជារាត្រីមានព្រះចន្ទ្រពេញវង់ មានរស្មីភ្លឺត្រចះ តែលោកគេត ដែលនៅក្នុងកាជន៍ មិនអាចឃើញទេសភាពទាំងនេះសោះឡើយ ។ រួចហើយ គាត់ចាប់ផ្ដើមគោះកាជន៍, ដំបូងបន្តិចៗទេ បន្ទាប់មក រឹតតែខ្លាំងឡើងៗ រហូតដល់លាន់សំឡេងដូចផ្គរ ។ គាត់យកប៉ោយទឹក ជួលទឹកស្រោចបន្តិចៗ ទៅលើក្រណាត់រាលដាប់ រហូតដល់មានសំឡេងដូចជាភ្លៀងបង្អុរចុះ ។ ពេញមួយរាត្រីនោះ គាត់គោះកាជន៍ ហើយចាក់ទឹកតែយ៉ាងនេះរហូតដល់ពេលព្រលឹមស្រាង ។ ទើបឈប់ ហើយគាត់យកបក្សីលោកគេតចេញពីកាជន៍ មកដាក់ក្នុងទ្រុងដដែលវិញ ។

ព្រឹកនោះ ជាពេលត្រូវកាត់ក្តី, កសិករបានយកបក្សីលោរិកេតចូលទៅកាន់ក្រសួងតុលាការ ។ អ្នកជិតខាងដែលបាត់ក្របី ក៏រាប់រៀបជំរាបចៅក្រមពីដំណើរសត្វលោរិកេត ប្រាប់គាត់ ឲ្យឃើញនូវសាច់ដែលកសិករបានលួច ។ ចៅក្រម ក៏សួរទៅសត្វលោរិកេតដើម្បីកត់ស្គាល់ ។ បក្សីនិយាយតាមពាក្យដែលវាបាននិយាយពីមុនរួចមកហើយ ម្តងទៀតថា:

"គាត់បានសំឡាប់ក្របី, សាច់មួយចំណែក គាត់លាក់ទុកក្នុងការដាន ហើយមួយចំណែកទៀត គាត់លាក់ទុកលើធ្នើរផ្ទះបាយ" ។

បុរសដែលលួចក្របី ឆ្លើយឡើងថា:

"ទានទេ! សាច់ដែលខ្ញុំប្របាទទុកនៅលើធ្នើរផ្ទះបាយ ទឹងក្នុងការដាននោះ ជាសាច់សត្វដទៃទៀតទេ, ម្តេចបានជាគេឲ្យទម្ងន់ គេជឿទៅលើពាក្យបក្សីចំកួតនេះ ជាងពាក្យខ្ញុំទៅទៀត ?" ។

„បក្សីលោរិកេត ជាសត្វឆ្លៀវឆ្លាសពិតណាស់!" ចៅក្រមនិយាយ ។

"ទានទេ! វាច្រើនតែនិយាយពាក្យឥតន័យជាងពាក្យមានន័យ" កសិករឆ្លើយ, សូមទានមេត្តាសួរវានូវបញ្ហាដទៃទៀតមើល, សូមសួរវាថា "តើយប់មិញ មានសភាពយ៉ាងណាខ្លះ ?" ។

ចៅក្រមសួរទៅបក្សីលោរិកេត ហើយបានទទួលចម្លើយថា :

« យប់មិញ ជារាត្រីងងឹត មានព្យុះបោកបក់ខ្លាំងណាស់ ថែមទាំងមានភ្លៀងបង្អុរចុះ ហើយមានរន្ទះលាន់ខ្ទរខ្ទារសម្បើមអស្ចារ្យ!» ។

កសិករនិយាយថា :

« បើតាមលោកចំណាំ, យប់មិញនេះ ជារាត្រីស្ងប់ស្ងាត់ ហើយក៏ស្រឡះ ដោយមានព្រះចន្ទ្រះពេញវង់ចែងចាំងស្មើគ្រប់គ្រង់, បើដូច្នេះ តើឥឡូវនេះ លោកអាចចោទខ្ញុំពីបទលួចសំឡាប់ក្របី ដោយភស្តុតាងរបស់បក្សីនេះបានដែរឬ ? » ។

ពេលនោះ មនុស្សទាំងអស់ ក៏ត្រូវកសិករនេះធ្វើឲ្យស្ងងតាម ឯចៅក្រមក៏ដូចគ្នា, ចៅក្រមនិយាយថា :

« ទេ, បើយ៉ាងហ្នឹង អ្នកឯងគ្មានទោសអ្វីទេ គ្រាន់តែប្រឡែកប្រឡូសជីវិត ដោយភស្តុតាងរបស់បក្សីចំកួតនេះប៉ុណ្ណោះ, ហើយចាប់តាំងពីពេលនេះទៅ យើងមិនត្រូវចិញ្ចឹមក្រោសត្វនេះ ទុកក្នុងផ្ទះរបស់យើង ឲ្យជាសត្វមួយក្នុងចំណោមយើង តទៅទៀតឡើយ » ។

ដោយហេតុនេះ កសិករដែលលួចក្របី ក៏រួចខ្លួន ហើយលោកកេតត្រូវគេលែង ឲ្យទៅនៅក្នុងព្រៃវិញទៅ ។ បក្សីបានរស់នៅដូចអតីតកាល មុនពេលដែលវាបានស្គាល់មនុស្ស ហើយវាថែរក្សាការពារខ្លួនវា តាមបំណងរបស់វា ។

ប៉ុន្តែថ្ងៃមួយ, បក្សីលោរិកេត បានជួបបក្សីថ្មីមួយទៀត រូបរាងធំជាងខ្លួនវា មានពណ៌ក្រហមខៀវយ៉ាងស្រស់រលើប ៗ លោរិកេតបានសួរឈ្មោះបក្សីថ្មីនេះ ហើយបានទទួលចម្លើយថា:

« ខ្ញុំជាសត្វសេក, ខ្ញុំមកពីទិសខាងត្បូង ហើយឥឡូវនេះខ្ញុំប្រុងនឹងអាស្រ័យនៅក្នុងប្រទេសនេះ, ខ្ញុំនិយាយភាសាមនុស្ស » ។

ពេលនោះ លោរិកេត និយាយថា:

« ចូរអាស្រ័យនៅក្នុងប្រទេសនេះ ឲ្យសប្បាយចុះ! ប៉ុន្តែកាលបើអ្នកឯងជាសត្វបែក មកនៅក្នុងទីនេះ ចូរទទួលយកឧបទេសនឹងការព្រមានរបស់ខ្ញុំ កុំបំភ្លេច; ខ្ញុំក៏និយាយភាសាមនុស្សដែរ ហើយខ្លួនខ្ញុំ ត្រូវគេឃុំគ្រងរក្សាទុកក្នុងផ្ទះមនុស្ស អស់រយៈពេលជាច្រើនឆ្នាំ; ខ្ញុំឮអ្វី ៗ នឹងត្រចៀកខ្ញុំ ហើយឃើញអ្វី ៗ នឹងភ្នែករបស់ខ្ញុំ; ខ្ញុំមិនត្រឹមតែនិយាយពាក្យ ដែលមនុស្សនិយាយនោះទេ គឺថែមទាំងអាចបញ្ចេញនូវគំនិតដ៏ល្អរបស់ខ្ញុំត្រង់ ៗ ថែមទៀត ហើយខ្លួនខ្ញុំ ត្រូវគេបំបរបង់ចេញមក; តទៅនេះ ជាការព្រមានរបស់ខ្ញុំ កាលបើមនុស្សបានដឹងថា អ្នកឯងចេះនិយាយភាសារបស់គេ, គេមុខតែនឹងចាប់អ្នកឯង ហើយនាំយកអ្នកឯង ទៅផ្ទះរបស់គេពុំខាន; អ្នកឯងកុំនិយាយអ្វី

ក្រៅពីពាក្យដែលនេះបង្រៀនអ្នកឯងនោះឱ្យស្មោះ! ជាការមួយតែប៉ុណ្ណោះ បានហើយ កុំថាអ្វីតទៅទៀត" ។

បក្សីថ្មីគឺសេក បានស្តាប់ហើយ ក៏ថ្លែងអំណរគុណទៅលោកកេតវិញ ។

បន្ទាប់មក ព្រឹត្តិការណ៍ក៏កើតឡើងដូចសត្វលោកកេត បានព្យាករ ទុកមកមែន ។

មនុស្ស កាលបានដឹងអំពីដំណើរដែលសេកចេះនិយាយនេះហើយ ក៏នាំគ្នាចាប់ យកទៅចិញ្ចឹមថែរក្សាទុកក្នុងផ្ទះ បង្រៀននិយាយ តាមបំណងរបស់គេ ដូចគ្រាដែលគេចិញ្ចឹមសត្វលោកកេត ដូច្នោះឯង ។

ប៉ុន្តែ ដោយខ្លាចចំពោះការនិយាយបញ្ចេញនូវគំនិតដ៏ពិតៗរបស់វា ដែលជាហេតុធ្វើឱ្យមនុស្សខឹង មិនគាប់ចិត្តចំពោះគំនិតទាំងនោះ, សេក ក៏និយាយធ្វើត្រាប់ត្រឹមតែពាក្យ ដែលវាបានឮពីបបូរមាត់របស់មនុស្ស តែប៉ុណ្ណោះឯង ។

## អណ្ដាតជាអាទ៌កន្លង
## ស្លាប់ផងរស់ផង ពីព្រោះអណ្ដាត

×

× ×

# រឿងព្រេងនិងរឿងបុរាណប្រទេសជប៉ុន

(តមក)

លោក ភ័យ-ប៊ុក រៀបរៀង

## គំរូកតញ្ញូតាធម៌នៃបុត្រម្នាក់

លោកកុមាតហ្ស៊ូកាលនៅជាកុមារ មានចិត្តស្រឡាញ់មាតាបិតាពន់ពេក ព្រមទាំងការគោរពនិងមានកតញ្ញូតាធម៌ចំពោះមាតាបិតាជាអនេក ។ លោកកុមាតហ្ស៊ូ មិនដែលធ្វើឲ្យមាតាបិតាព្រួយបារម្ភអ្វីសោះ ។ លោកបានធ្វើតាមចិត្តរបស់មាតាបិតានៃលោកទាំងអស់ ។ មាតាបិតាលោកមានចំណង់ចង់បានអ្វី លោកផ្គាប់ឲ្យត្រូវចិត្តបាន, លោកជួយធ្វើកិច្ចការផ្សេង ៗ ជាទេទៀត ដូចជាចំអិនម្ហូបអាហារ និងគេហកិច្ចទាំងអស់ ដោយទឹកមុខសោមនស្សជាទីបំផុត ។

មិនត្រឹមតែប៉ុណ្ណោះ គេតែងឃើញលោកកុមាតហ្ស៊ូទៅទិញត្រីនិងទំពាំងដើម្បីយកមកធ្វើម្ហូបក្នុងគ្រួសារ, ករណីយកិច្ចម្យ៉ាងទៀត គឺលោកបានជូតខ្នងឪពុកលោក ដែលមុជទឹកក្នុងបន្ទប់ទឹក, ឬនាំប្អូនប្រុសនិងប្អូនស្រីតូចដែលចងពីក្រោយខ្នងដើរលេងកំសាន្តសប្បាយ ។

លុះចំរើនធំឡើង លោកក៏កាន់តែជ្រាបដោយជាក់ច្បាស់អំពីការលំបាកនៃមាតាបិតាចំពោះខ្លួនលោក ។ ដោយលោកគិតឃើញថា មាតាលោក បានបំបៅលោក រហូតដល់លោកមានអាយុ ៣ ឆ្នាំ ។ បិតា

របស់លោក ពិតមែន តែក្រទ្រព្យសម្បត្តិ ប៉ុន្តែអាចទិញវត្ថុផ្សេងៗ សម្រាប់ក្មេងលេងជាច្រើន គឺៈ ខ្លែងដើងឈើសំកប់ជិះលេង, មុខយក្ស និងខ្លែធំៗ ធ្វើពីក្រដាស ដែលកុម៉ាតហ្សូចូលចិត្តលេង ។

លោកកុម៉ាតហ្សូ ដល់គិតពីគុណូបការៈរបស់មាតាបិតាដូច្នោះ ក៏នឹកថា គុណដ៏ប្រសើរនេះ អញមិនអាចនឹងសងគុណវិញបានឡើយ ។

លុះលោកមានវ័យវឌ្ឍនាការចំរើនធំឡើង លោកខំសង្រ្គាហ៍អានសៀវភៅពួកសីលធម៌បណ្ឌិតចិន ដែលជនជាតិជប៉ុនច្រើនចូលចិត្ត ។ ក្នុងពួកសៀវភៅសីលធម៌បណ្ឌិតចិននេះនោះ បានពណ៌នាដោយសព្វគ្រប់ អំពីអាកប្បកិរិយា និងកាយវិការរបស់ក្មេង ចំពោះមាតាបិតាខ្លួនៗ គឺពោលថា កូនមិនត្រូវស្តោះទឹកមាត់ ស្ទាប ក្អក ឬកណ្តាស់ ចំពោះមុខមាតាបិតាឡើយ កូនត្រូវមៀងមើលមាតាបិតាដោយចក្ខុដ៏ស្រទន់ស្រគាប, អេះរមាស់ជូនលោក និងបរិភោគអាហារដែលសល់អំពីលោកទាំងពីរ ។

លោកកុម៉ាតហ្សូ ពេញចិត្តយ៉ាងក្រៃលែង នឹងជាតំរូវនៃគតញ្ញូតាធម៌ដែលគេបានផ្សាយឈ្មោះលោកយ៉ាងឱឡារិក នៅចុងបូព៌ាប្រទេស ។

កុម៉ាតហ្សូ ពេញចិត្តខាងរឿងព្រេងចិននៃនាងអាដូក៉ូ ជាធីតានៃមន្ត្រីធំម្នាក់នាម គូអែនយូ (ប្រែថា ស្ពាបប៉ាកកាធំ) ។

ក្នុងរឿងនេះ មានសេចក្តីថា ព្រះចៅអធិរាជចិនទ្រង់ត្រាស់បង្គាប់ឲ្យលោកគូអែនយូធ្វើកណ្តឹងមួយយ៉ាងធំ ឲ្យមានសូរលាន់ឮឆ្ងាយ ។

លោកគូអែនយូ ក៏ហៅជាងរំលាយលោហធាតុយ៉ាងជំនាញម្នាក់មក ហើយ លោកយកស្ពាន់លាយជាមួយមាស ដើម្បីឲ្យកណ្ដឹងលាន់ឮល្អ ហើយយកប្រាក់លាយថែមទៀត ដើម្បីឲ្យមានសំឡេងស្រួយរងំ, តែលទ្ធផលនៃការលាយនោះ មិនបានសម្រេចដូចបំណង; តមក លោកក៏បានទទួលព្រះរាជតម្រិះ ព្រះចៅអធិរាជថា បើលាយលោហធាតុជាលើកទីបីមិនបានលទ្ធផលទេ នឹងត្រាស់បង្គាប់ ឲ្យគេកាត់ក្បាលលោកគូអែនយូជាអវសាន ។

ខណៈនោះ នាងអាយូវ៉ាំ ជាធីតាលោកគូអែនយូ ខំលក់គ្រឿងមាសប្រាក់ដោយសម្ងាត់ ដើម្បីឲ្យបានសោហ៊ុយចំណាយក្នុងការរករាគសាស្ត្របណ្ឌិតម្នាក់ឲ្យជួយពិចារណារឿងនេះ ។ គាពសាស្ត្របណ្ឌិតនោះ ក្រោយដែលបានបើកសៀវភៅគម្រាផ្សេង ៗ ព្រមទាំងពិនិត្យមើលរូបតំនួរធាតុ តាមជោគជតាពរាសី ក៏ឆ្លើយតបទៅនាងវិញថា " មាសប្រាក់ និងស្ពាន់ជាលោហធាតុសម្រាប់ធ្វើកណ្ដឹងនោះ មិនរលាយចូលគ្នាទេ លុះណាតែ មានលោហិតព្រហ្មចារីមួយរូបចូលទៅលាយគ្នាផង ទើបលោហធាតុទាំងនេះ រលាយចូលគ្នាបាន " ។

លំដាប់តមក លោកគូអែនយូ ក៏ត្រៀមការរំលាយលោហធាតុនោះជាលើកទី ៣ ។ ក្នុងពេលនោះ នាងអាយូវ៉ាំ ក៏ពោលថា នាងចង់ឃើញកិច្ចការដែលបិតាធ្វើឲ្យបានជោគជ័យ, ក្នុងពេលលោហធាតុកំពុង

រលាយ, នាងនឹកលោតចូលទៅក្នុងឡរលាយលោហធាតុ ហើយស្រែកថា "ដោយអំណាចកតញ្ញូតាធម៌ចំពោះបិតាខ្ញុំ សូមឲ្យលោហធាតុនេះរលាយចូលគ្នាជាសាច់មួយ" ។ ពេលនោះ គណ្ឌឹងក៏កើតឡើង បញ្ហាញរូបរាងយ៉ាងច្បាស់ប្រាកដ មានទម្រង់ទ្រង់ពណ៌សម្បុរយ៉ាងវិសេស មានសំឡេងលាន់ឮខ្លាំងជាងគណ្ឌឹងឯទៀត, នៅក្នុងសូរនោះ មានសំឡេងដូចជាស្រក់ក្រំខ្ញុំយំ ស្រ្តីថ្ងៃ . . . . ។

កុមារតហ្ស៊ីពេញចិត្តនឹងការរៀនបែបនេះ ហើយមានបំណងចង់តាំងខ្លួនជាវីរបុរសដូចរឿងខាងលើ ។ តែជីវិតរបស់លោកបិតនៅដោយស្រួល គ្មានព្រឹត្តិការណ៍ដូចខាងលើនេះសោះឡើយ ។

លោកកុមារតហ្ស៊ី បិតនៅដល់អាយុ ៧៥ ឆ្នាំ ក៏គ្មានបានបំពេញករណីយកិច្ចអ្វីមួយដ៏ល្បីល្បាញ ដែលគេអាចកត់បញ្ចូលឈ្មោះលោកទៅក្នុងពង្សាវតារនោះ ។

តែលោកកុមារតហ្ស៊ី មានចិត្តសោមនស្សយ៉ាងលើសលប់ ដោយមាតាបិតាលោកបិតនៅដល់អាយុជាង ១០០ ឆ្នាំ ។

មាតាបិតាទាំងនោះ ពិតមែនតែកូនប្រុស-ស្រី បានបំពេញករណីយកិច្ចគ្រប់ៗគ្នា តែនៅមានសេចក្ដីព្រួយចិត្តជាខ្លាំង ព្រោះខ្លួនលោកកាន់តែចាស់ជរាទន់ទោរទៅ ។

លោកកុមារតហ្ស៊ី ក្នុងរយៈវេលាដែលខ្លួនរស់នៅអស់ពេលជាយូរ

លង់នោះ បានជួយបង្អន់សេចក្តីទុក្ខនៃមាតាបិតា, ពិសេសជាងនេះ លោកពុំអាចបំបាត់សេចក្តីចាស់ជរារបស់មាតាបិតាបាន ។ លោកបាន រិះរកមធ្យោបាយសព្វយ៉ាង ចំពោះរឿងនេះ ៗ ថ្ងៃមួយ លោកបាន រកឃើញមធ្យោបាយមួយដូចតទៅនេះ ៖

លោកទៅផ្សារទិញវត្ថុសម្រាប់ក្មេងលេង គឺស្គរ ១ ប្រដាប់ទាត់សី ១ ទន្សាយធ្វើពីក្រដាស ១, ហើយលោកទិញអាវ "គិម៉ូណូ" មួយ ជាអាវមានដៃធំទូលាយ ដែលកុមារនៃជនជាតិជប៉ុននិយមប្រើប្រាស់ ៗ កុមារគហ្ស៊ូ បានយកឫស្សីមួយដើមទៅបោះចំមុខផ្ទះលោក, នៅចុង ឫស្សីនោះ លោកយកត្រីដែលធ្វើពីក្រដាសពណ៌ទៅចង ៗ ព្រោះប្រ. ទេសជប៉ុន ពេលពិធីបុណ្យយុវជន មាតាបិតាដែលមានកូនមានអាយុថយ ពី ៧ ឆ្នាំ តែងធ្វើរបៀបនេះដែរ, និមិត្តរូបនេះ សឲ្យឃើញថា កុមារទាំង នេះ មានសភាពដូចត្រី ដែលឡើងទៅលើស្ទឹង តស៊ូនឹងទឹកហូរច្រាស ដូច្នោះ ៗ

មាតាបិតាលោកកុមារគហ្ស៊ូ ដែលមានអាយុជាង ១០០ ឆ្នាំ មាន ចិត្តសង្ស័យ ដោយឃើញដើមឫស្សីពីងពង់មួយដើម បោះចំពីមុខផ្ទះ ហើយនឹងត្រីដែលធ្វើពីក្រដាសពណ៌ ហើយនឹងលោកកុមារគហ្ស៊ូពាក់ អាវគីម៉ូណូ ពណ៌ផ្កាកុលាបស្រស់ ដូចក្មេងពាក់លេង, ដើរទ្រេតទ្រោត លើដី ដូចក្មេងមិនទាន់ចេះដើរ, ពោលពាក្យមិនច្បាស់ដូចទារកតូច ៗ

ខ្ទះស្អុះហើយលើងនឹងខំព្យាយដែលធ្វើពីក្រដាស ។

ការខំព្យាយាមធ្វើដូច្នេះ មកពីលោកមានបំណងចង់ឲ្យមាតាបិតារស់នៅអស់ពេលដ៏យូរតទៅទៀត ដែលគេទុកជាកតញ្ញូតាធម៌ចំពោះមាតាបិតាក្នុងគ្រានោះ ។

ចប់រឿងលោកកុមារតហ្យូ ។

## រឿងព្រេងទាក់ទងដោយព្រះពុទ្ធសាសនា

រឿងព្រេងដែលទាក់ទងដោយ ព្រះពុទ្ធសាសនាបែកខាងមហាយាន គឺ: រឿងរុក្ខជាតិតឿ១, រឿងព្រះជ័ហ្យូទាំង៦រូប១, រឿងបិសាចនៃព្រះសង្ឃមួយអង្គ១, រឿងដើមស្រល់ក្នុងទីក្រុងតិអ្សូ១, ។ បណ្ដារឿងទាំង ៤ នេះ យើងនឹងពណ៌នារឿងរុក្ខជាតិតឿជាមុន ។

### ១– រឿងរុក្ខជាតិតឿ

នៅប្រទេសជប៉ុន មានរុក្ខជាតិតឿខ្លះអាយុ ៥០ ឆ្នាំ ខ្លះអាយុ ១០០ ឆ្នាំ ខ្លះអាយុ ១៥០ ឆ្នាំ ខ្លះទៀតអាយុ ២០០ ឆ្នាំ, រុក្ខជាតិនេះពិតមែនតែរុក្ខជាតិមានដើមធំ តាមកំណើតរបស់វា ប៉ុន្តែគេអាចធ្វើឲ្យស មែក ស្វិត ក្តា ឲ្យទៅជាតូចតាចបាន ។

វិធីនេះ ដំបូងគេយកគ្រាប់ទៅដាក់ក្នុងដបកែវតូច ។ លុះវាដុះចេញពន្លកបាក់ឫសជាច្រើន វាជញ្ជក់យកជាតិដីក្នុងកែវនោះអស់ហើយ គេយកវាទៅដាក់ក្នុងដបកែវធំបន្តិច ហើយគេធ្វើតាមរបៀបនេះតទៅទៀត ។

រុក្ខជាតិនេះ ដោយគេឲ្យជាតិដី ដែលជាអាហាររបស់វាមិនគ្រប់គ្រាន់ ក៏ទៅជាតូចតាច, លំដាប់តមក គេយកមែកទៅបង់ព័ទ្ធរ៉ាន់គ្នានឹងគ្នា មែកខ្លះបង់ផ្តាច់នឹងគល់ ធ្វើឲ្យពាល់តែវាដុះបានដោយលំបាក ។

ដោយវិធីនេះ គេអាចធ្វើរុក្ខជាតិដែលមានអាយុច្រើន ឲ្យមានកំពស់នៅតែត្រឹមជាង ៥០ សង់ទីម៉ែត្រ ឯគល់វាមានទំហំ ៤,៨ ឬ ១០សង់ទីម៉ែត្រប៉ុណ្ណោះ ។ រុក្ខជាតិបែបនេះ មានមនុស្សជាច្រើនតែងចូលចិត្ត ។

មានសេចក្តីដំណាលថា: លោកតូម៉ូណារ នឹងភរិយា មានតែរុក្ខជាតិតឿ ៣ ដើមជាគោលទ្រព្យគឺ: ១-រុក្ខជាតិធុយ៉ា អាយុ ១០០ ឆ្នាំ, ២ រុក្ខជាតិស្រល់ អាយុ ១២០ឆ្នាំ, ៣-រុក្ខជាតិអេរ៉ាប៉្លឺ អាយុ ២០០ ឆ្នាំ ។ អ្នកទាំងពីរព្យាយាមថែទាំរុក្ខជាតិតឿ៣ដើមនេះជានិច្ច តែងស្ទាបអង្អែលដោយសេចក្តីស្នេហាពន់ពេក, ដូចជាអ្នកកំណាញ់ទាយគន់សម្បត្តិរបស់ខ្លួន ឬដូចជាមាតាឃើញកូនដូច្នោះ ។

អ្នកទាំងពីរក្រណាស់ ជួនកាលខ្វះអាហារបរិភោគផង តែបើទុកជាយ៉ាងណាក៏ដោយ ក៏អ្នកទាំងពីរ មិនដាច់ចិត្តយកដើមឈើទាំង ៣ ទៅលក់យកប្រាក់មកចិញ្ចឹមជីវិតបាន ។ ពេលនោះ លោកតូម៉ូណារ៍ នឹងភរិយា ឋិតនៅក្នុងការលំបាកជាខ្លាំង បានបរិភោគតែនំមួយ ដែលធ្វើពីដើមមីល្ហ ហើយទុកមួយទៀតពេលក្រោយ, អ្នកទាំងពីរមានសភាពរងាយ៉ាងក្រៃលែង ព្រោះពេលនោះ ជាពេលព្រឹកព្រហាមមាន

ព្រិលធ្លាក់ចុះពេញផែនដី ។

អ្នកទាំងពីរ កំពុងបិតទៅក្នុងផ្ទះ ស្រាប់តែឮស្នូរគេគោះទ្វារ... , អ្នកទាំងពីរក៏បើកទ្វារ ក្រឡេកទៅឃើញព្រះសង្ឃមួយអង្គ ស្លៀកដណ្ដប់សំពត់ពណ៌ប្រផេះទិមទ្គមកបិណ្ឌបាត ។

ព្រះសង្ឃនោះមានពុទ្ធដីកាថា " អាត្មាត្រជាក់ខ្លាំងណាស់ សូមអ្នកមេត្តាឲ្យអាត្មាចូលជ្រកក្នុងទីនេះបានមួយស្របក់ " ។

លោកតួម៉ូណារ៍ ទូលទៅព្រះសង្ឃវិញថា " មិនបានទេ, ខ្ញុំព្រះករុណាក្រលំបាកពន់ពេកណាស់ មិនអាចទទួលព្រះតេជព្រះគុណបានឡើយ ហើយខ្ញុំព្រះករុណាគ្មានតែអ្វីប្រគេនព្រះតេជព្រះគុណផង កំពុងវេទនាលំបាក ដោយការស្រេកឃ្លានទីងរងាពន់ពេក " ។

ព្រះសង្ឃនោះបានមានពុទ្ធដីកាទាំងរងាញាក់ថា: អាត្មាដែលមកសុំនេះ ក្នុងនាមនៃព្រះសម្មាសម្ពុទ្ធជាម្ចាស.... តែបើលោកមិនអាចទទួលអាត្មាបាន អាត្មាសូមលាហើយ " , ថាតែប៉ុណ្ណោះ ក៏និមន្តហួសទៅ ក្នុងពេលដែលកំពុងធ្លាក់ព្រិលយ៉ាងខ្លាំង ។

ក្រោយមកអ្នកទាំងពីរគិតគ្នាថា កិច្ចដែលយើងធ្វើនេះ មិនសមរម្យទេ ។ ភរិយាពោលថា "យើងខុសធំហើយ មកបណ្ដេញព្រះសង្ឃដែលមកសុំជ្រកនឹងយើង, ប្រសិនបើ ព្រះសង្ឃនេះសុគតទៅដោយសារសេចក្ដីស្រេកឃ្លាននិងរងា តើយើងមានវិប្បដិសារីយ៉ាងណាទៅ" ។

លោកគូម៉ូណារីគិតបេះទៅកិរិយាវិញថា "តើយើងធ្វើដូចម្ដេច" ? ។

កិរិយានិយាយថា "បើទុកជាយ៉ាងណាក៏ដោយ ព្រះសង្ឃនេះមានសេចក្ដីលំបាកជាងយើងទៅទៀត លោកគ្មានទំព្រកសោះ ឯព្យុះព្រិលកំពុងតែបោកបក់មកយ៉ាងខ្លាំងផង ឯងចូរតែតាមលោកទៅ នាំលោកមកផ្ទះយើងវិញ ឯចង្ហាន់នោះចាំយើងលៃលកតាមក្រោយ" ។

លោកគូម៉ូណារី យល់ស្របតាមសំដីប្រពន្ធ ក៏ពាក់ស្បែកជើងសម្រាប់ដើរលើទឹកកកតែទៅតាមព្រះសង្ឃនោះ លុះដើរបន្តិចទៅ ក៏បានឃើញព្រះសង្ឃនោះដួលនៅលើព្រិលទន់ជិតគេហដ្ឋានមួយ ។ លោកគូម៉ូណារីឃើញដូច្នោះ ក៏គ្រាហ៍នាំមកកាន់ផ្ទះខ្លួន រួចនិយាយទៅកាន់ប្រពន្ធថា: "តើយើងមានអ្វីប្រគេនលោកឆាន់" ?

កិរិយាឆ្លើយថា "យើងមានតែនំមួយ ដែលយើងរំលែកទុកពីម្សិលមិញ" ។ លុះប្រគេនហើយ ដោយសេចក្ដីស្រេកឃ្លានខ្លាំង, លោកក៏ឆាន់ទៅ ។

លោកគូម៉ូណារី បានក្រឡេកមើលទៅ ឃើញព្រះសង្ឃនោះរងាខ្លាំង ក៏ពោលទៅកាន់កិរិយាថា "គួរដុតភ្លើង" ។

កិរិយាពោលថា "យើងមិនអាចដុតភ្លើងបានទេ ព្រោះយើងគ្មានអុសសោះ" ។

លោកតួម៉ូណារ៉ ពោលបន្ថែមថា យើងមិនអាចដុតភ្លើងកំដៅបានទេ ។

ករ៉យារពោលថា ".យើងគ្មានចំណាំងឈើមួយកំណាត់សោះ បើនឹងរកទសលុះត្រាតែ......" ។

លោកតួម៉ូណា ក៏ពោលថា "លុះត្រាតែ.... លុះត្រាតែយើងយករូបជាតិតឿនោះមកធ្វើអុសទើបបាន" ។

រឿងនេះ អ្នកប្រាជ្ញគួរកត់សំគាល់ថា អ្នកទាំងពីរ លុះនិយាយគ្នាមកដល់ពាក្យថា យករូបជាតិតឿទៅធ្វើអុស ក៏មានសេចក្ដីជ្រួលច្របល់ក្នុងចិត្តជាខ្លាំង, ម្យ៉ាងទៀត បើអ្នកទាំងពីរនេះលះបង់រូបជាតិតឿទាំង ៣ ដើម គឺមិនមែនយកខ្លួនទៅធ្វើពលិកម្មទេ គឺយកដួងចិត្តរបស់ខ្លួនដ៏ស្អាតបរិសុទ្ធទៅធ្វើពលិកម្មវិញ ។

លោកតួម៉ូណារ៉ី មានទឹកភ្នែករលេងរលោង ពោលថា យើងមិនត្រូវឲ្យព្រះសង្ឃនេះអន្តរធម្មដោយសាររងានេះទេ ត្រូវតែយករូបជាតិនេះភ្លើងសដុត ។

ពេលនោះ ករ៉យាក៏ដើរទៅយកឈើ ធុយ៉ា អាយុ ១១០ ឆ្នាំនោះមក នាងមានទឹកភ្នែកហូរសស្រាក់ ហើយនាងកាប់ឈើធុយ៉ាបោះទៅក្នុងភ្លើងទៅ ។ នាងមានបំណងចង់ស្រោចស្រង់ឈើពីរដើមទៀតតែភ្លើងឥតត្រាប្រណីឡើយ, ឈើធុយ៉ាក៏ត្រូវជាចំណីភ្លើងអស់គ្មានសល់;

តមក ក៏ត្រូវយកឈើស្រល់មកកាប់ថ្ពោះពៅក្នុងភ្លើងទៀត ។ ប្តីប្រពន្ធគិតលៃលុកឈើអេក៏ច្ងៃ តែទុកមិនបាន ដោយភ្លើងនេះអស់ឈើ ២ ដើមហើយ ម៉្លោះហើយនាងជាភរិយាក៏យកឈើអេកច្ងៃដែលមានអាយុ ២០០ឆ្នាំ កាប់ថ្ពោះពៅក្នុងភ្លើងជាទីបំផុត ។

លុះព្រះសង្ឃនោះបានឆន់ឆ្អែតហើយ, អ្នកទាំងពីរក៏ក្រឡេកមើលមុខគ្នាដោយសេចក្តីប្រាថ្នាឲ្យយ៉ាងក្រៃលែង ។

## ២- រឿងព្រះធិបរូបទាំង ៦ រូប

មានគហ័តម្នាក់ឈ្មោះ ម៉ាត់ស៊ុដា ជាអ្នកមានភ្នែកងងឹតមើលមិនសូវច្បាស់, ប៉ុន្តែ ជាអ្នកគោរពកប់ការព្រះពុទ្ធសាសនាពន់ពេក ។ កុងពេលដែលលោកធ្វើស្រែ លោកបានធ្វៀតឲ្យកាសមួយដងមួយកាល អញ្ជើញទៅឯទីក្រុង ឬភូមិជិតខាងដើម្បីពិនិត្យមើលទូវព្រះពុទ្ធ-រូបទាំងឡាយ, តែដោយលោកមានភ្នែកងងឹតមើលពុំសូវច្បាស់ លោកតែងពិនិត្យព្រះពុទ្ធរូបទាំងឡាយដោយហ្មត់ចត់ ។

បានជាលោកគោរព ដោយសេចក្តីស្មោះស្ម័គ្រ ព្រោះលោកគិតឃើញថា ព្រះពុទ្ធរូបនេះ ជាដំណាងនៃព្រះសម្ពុទ្ធជាម្ចាស់ ដែលទ្រង់ដឹកនាំពន្យល់មនុស្សលោកនូវចតុរារិយសច្ច, ក្នុងពេលដែលលោកពិនិត្យនោះ ដូចកាលលោកលើកម្រាមដៃប្រណម្យ សំដៅងគារវកាពចំពោះព្រះពុទ្ធរូប ដូចកាលលើកដៃចុះ-ឡើង ដើម្បីពោលធម៌ ឬសិក្សាធម៌ ។

លោកតែងធ្វើអភិវន្ទនាការចំពោះព្រះពុទ្ធអមិតាភៈ(១) ដែលជាងចាក់មានសភាពជាប្រុសកំឡោះ មានរង់មូលនៅលើព្រះលលាដ(ថ្ងាស) ជានិមិត្តរូបនៃគតិបណ្ឌិត ព្រះនេត្របិទម្ខាង ព្រះហស្ដនៅលើព្រះទុទរ ព្រះមង្គុលី (ម្រាមមេដៃ) ទល់គ្នា ។

ជាការចម្លែក, លោកមានចិត្តគោរព ទឹងមានសេចក្ដីស្ងប់ស្ងៀម ចំពោះព្រះរូប ព្រះអង្គម្ចាស់ក្សត្រី « ក្វាន់ឥន » ដែលលោកពណ៌នាជាញឹកញយចំពោះរឿងនេះ ។

តាមសេចក្ដីដំណាលក្នុងរឿងព្រេងជប៉ុននោះថា «ព្រះអង្គម្ចាស់ក្សត្រី ក្វាន់ឥន ទ្រង់មានព្រះរូបឆោមលោមពណ៌ស្រស់ប្រិមប្រិយប្រកបដោយព្រះរាជហឫទ័យជាមហាសប្បុរស ។ ដោយហេតុនេះហើយ បានជាព្រះនាងទ្រង់បានរួបរួមសេចក្ដីទុក្ខ ជាមួយសត្វលោកទាំងអស់, ព្រះនាងទ្រង់បានជួយសម្រាលសេចក្ដីទុក្ខនៃសត្វលោកទាំងអស់ដែលអាចជួយបាន ។ ព្រះនាងទ្រង់ព្រះតម្រិះទៅកាន់សត្វដែលរងទុក្ខទោសក្នុងនរក, ទ្រង់មានព្រះរាជហឫទ័យអាណិតអាសូរដល់សត្វដែលរងទុក្ខឈឺ

---

(១) ប្រែថា អ្នកមានពន្លឺ ឬរស្មីរាប់ពុំអស់ ។ តាមសេចក្ដីដំណាលក្នុងគម្ពីរលទ្ធិមហាយានថា ព្រះអមិតាភៈនេះ ទ្រង់ប្រតិស្ឋាននៅឯឋានសុខាវតី ។ មហាយានិកពួកខ្លះហៅថា អមិតាយុស ប្រែថា ព្រះពុទ្ធមានព្រះជន្មវែងឥតគណនា ។ ហៅខ្លីថា អមិតៈ ហៅក្លាយថា អមិដា ឬ អមីដា ។ (មានសេចក្ដីពិស្ដារក្នុងគម្ពីរលទ្ធិមហាយាន ខាងលទ្ធិហីនយានពុំមាននិយាយទេ) ។

ចាប់ខ្លួនប្រាណក្នុងទីនោះ ។ មានកាលមួយថ្ងៃ ព្រះនាងទ្រង់យាងចុះទៅក្នុងស្ថាននរក, ក្នុងពេលនោះ ព្រះនាងទ្រង់បានសំដែងបាដិហារិយ៍ចំពោះមុខសត្វនរក ពាល់តែពួកនេះ ក្រឡេកមកឃើញព្រះនាងទ្រង់មានរូបឆោមស្រស់ប្រិមប្រិយ ព្រមទាំងមានទឹកព្រះភ័ក្ត្រ ប្រកបដោយមហាករុណា ។ ពេលនោះ ពួកសត្វនរកមានចិត្តសប្បាយរីករាយឥតឧបមា ។ ព្រះនាងក្វាន់ឥម ទ្រង់បញ្ចេញរស្មីក្រោងក្រាតជុំវិញសត្វនរក នៅព្រះបាទាមានបុប្ផាដុះចេញមកយ៉ាងស្រស់, ដោយអានុ-ភាពនៃព្រះនាង ទីដែលសត្វនរករងទុក្ខទោស ទៅជាស្ថានមួយយ៉ាង

៨ សប្បាយ ដូចស្ថានសួគ៌ ។ -

លោកម៉ាត់ស៊ូដា ពេញចិត្តនឹងទស្សនាព្រះនាង ក្វាន់ឥមយ៉ាងក្រៃលែង ។ ព្រោះព្រះបដិមាករនេះ មានទ្រង់ទ្រាយផ្សេងៗគ្នា ព្រះបដិ-មាករខ្លះទ្រង់សណ្ឋិត, អង្គខ្លះគង់, អង្គខ្លះទ្រង់ផុសចេញពីបទុមជាតិ, អង្គខ្លះ មានអាការដូចជាទ្រង់ព្រះសណ្ដាប់ឮសំឡេងទួញយំអង្វរដោយការឈឺចាប់នៃសត្វលោកទាំងអស់, អង្គខ្លះ មានព្រះហស្តជាច្រើន ហើយមានទំនងដូចជាទ្រង់ស្ទុះអណ្ដែតសត្វលោក ឲ្យផុតពីសេចក្ដីទុក្ខសោក ។

(មានត)

# រឿងស្រីគ្រប់ល័ក្ខណ៍

(តមក)

លោក ឃុត-វង់ រៀបរៀង លោក ផេង-ជ្រីវ ពិនិត្យ

ទៅឯត្រើយស្ទឹងម្ខាង ទំទទួមគ្នាលើ មកខ្ពួចទីនេះ បែរមុខមករកស្ទឹង គ្រលីងគ្រលោងទាំងគូរប្រៀងផ្កាផ្ដងលេងសប្បាយ យ៉ាងរីករាយ ៗ នៅលើចុងឈើតាលខ្ពស់ត្រដូចដែលដុះក្បែរនោះ លលកឈ្មោលញីប្រៀងចូលផ្ទឹមគ្នាជាទីពេញចិត្ត ទាំងនេះហាក់ដូចគេប្រគុំតន្ត្រីជូនដំណើរ នឹងប្រសិទ្ធពរចំពោះសិរីវត្តន៍ សុំឲ្យអ្នកចរទៅដោយសុវត្ថិភាព ៗ

## ជំពូក ៣

ទៅក្នុងផ្ទះធនសេដ្ឋី ការប្រព្រឹត្តទៅ មានសភាពវាប្រក្រតីដូចពេលមុនៗរៀងមកៗ សោកណា ដោយមានសុភ័ទ្ទិងចន្ទីជាជំនួយ តែងបំពេញការក្នុងផ្ទះឥតខ្ចះចន្លោះត្រង់ណាឡើយៗ កិច្ចត្រួតត្រាការក្រៅផ្ទះជាភារៈនៃធនសេដ្ឋីជាបិតា ៗ កូនឈ្នួលប្រុសស្រីនាំគ្នាធ្វើកិច្ចការសស្រាក់សស្រាំ ឥតដែលមានពុតត្បុតម្តងសោះ ព្រោះចៅហ្វាយនាយមានចិត្តទូលាយឥតប្រកាន់បុគ្គល ចែកចាយម្ហូបចំណីស្មើភាគគ្នា និងតាមឧបការគុណជូនស្រាល ៗ ម្ល៉ោះហើយគេក្តីឈ្មោះធនសេដ្ឋីលេចព្រឺទ្ធិសុះសាយ ទៅក្នុងភូមិស្រុកជិតឆ្ងាយ ថាជាអ្នកមានធម៌សប្បុរស ចំពោះកូនឈ្នួល ចំពោះមនុស្សជិតខាងនិងសម្មយាចក អ្នកកំសត់ទុគ៌តទាំងឡាយ ៗ

ជាធម្មតា នៅពេលរសៀលប្រហែលម៉ោងប្រាំ តែកាលណាកិច្ច

ការផ្ទះរួចសព្វគ្រប់ហើយ សោភណាសេដ្ឋីធីតា មួយអន្លើដោយសូភី និងនាងចន្ទីជាបរិវារ ក៏នាំគ្នាទៅងូតទឹកជំរះកាយឯកំពង់ នៅមាត់ស្ទឹងជាពល់ថ្ងៃ ។

ថ្ងៃនេះ ពេលដែលយុវតីទាំងបីប្រាណកំពុងប្រុងប្រៀបទីនផ្លាស់សំពត់អាវ ដើម្បីចុះងូតទឹក ស្រាប់តែមានឈើគល់មួយអណ្តែតសៀរៗខាងក្បែរច្រាំងមកប៉ះជាប់នឹងកំពង់នោះ ។ មានបុរសម្នាក់ ការខោកណ្តាបច្រៀកនៀត សក់ដុះទ្រុបធ្លាក់មកលើស្មា ពុកមាត់ស្រមាម មុខស្មុកស្មាំងក្អែកស្មុក ទំនៅលើនោះ ដូចសត្វគីង្គក់កង់រដូវទឹកដំឡើង ។ ដោយសេចក្តីអៀនខ្មាស បុរសអនាថា មិនហ៊ានងាកមើលនារីទាំងនោះឡើយ ។ អ្នកអង្គុយឱនលាក់មុខ ដោយទឹកតួបចិត្តនឹងវាសនាអាក្រក់របស់ខ្លួន ។

សូភីស្រែកថា: „យី! មើលមនុស្សចំកួតនេះ មកពីណាខ្លួនអាក្រាតយ៉ាំងដូច្នេះ!" ។

ចន្ទីស្រែកបន្ទាន់គ្នាទៀតថា: "យី! មនុស្សនេះ គឺមនុស្សទក្សាកចង្រៃទេ! រុញច្រានវាឲ្យអណ្តែតចេញទៅអញខ្ពើមណាស់ ! រួចហើយក៏ងាកខាកស្តោះទៅតាម កុយ.. កុយ .. ។

ឃើញអាកប្បកិរិយាទាសីទាំងពីរមិនសមរម្យដូច្នោះ សោភណា មានវាចាយ៉ាងសុភាពទៅកាន់សូភីនិងចន្ទីថា: "បងអើយ កុំពោលអ្វីមិនសមទេ

មនុស្សយើងគ្រប់រូប គ្មានអ្នកណាចង់ទុក្ខទេ ចង់តែសុខ គ្មានអ្នកណាចង់ក្រទេ ចង់តែមាន ចង់តែសប្បាយ ដែលគាត់ធ្លាក់ខ្លួនទៅក្នុងស្ថានការណ៍ដ៏ជូរចត់ស្ទើរតែមិនឡើងយ៉ាងនេះ យើងក៏ពុំដឹងដើមហេតុ ថាមកពីអ្វីបានទេ គួរយើងអាណិតអាសូរមេត្តាគាត់ផង ព្រោះគាត់ក៏ជាមនុស្សម្នាក់ដូចយើងដែរ ណាបង ! ។

ចន្ទីឥតឆ្លើយតបអ្វី ស្រាប់តែដើររឹងទៅផ្ទះ ហើយជំរាបធនសេដ្ឋីថា:

-សូមជំរាបប្រសាសន៍ព្រះតេជព្រះគុណ! មានមនុស្សទ្រគ្យាតពីណាអាក្រាត ទុំលើគល់ឈើដូចគឺក្ដក់ អណ្ដែតមកប៉ះជាប់នៅកំពង់យើង ។

ឮដូច្នោះ ដោយខ្លួនធ្លាប់ជាអ្នកមានធម៌សប្បុរស ធនសេដ្ឋីញញឹមមួយស្របក់ ទើបសួរថា:

-មនុស្សនោះរូបរាងបែបដូចម្ដេច ធំ ឬតូច ស ឬខ្មៅ? យី! អាសំឡាញ់អញទេដឹង! ហ៊ី! ហែងយកក្រមានេះទៅបោះឲ្យវា រួចហៅវាឲ្យឡើងមកមើល ! យី! អញដូចនឹកសង្ស័យណាស់ ច្បាស់ជាអាសំឡាញ់អញហើយ ព្រោះបាត់ដំណឹងអំពីវាចំនួនជាង ២០ ឆ្នាំហើយ ។ ហ៊ី! រត់ឲ្យឆាប់ទៅ នៅបង្អែបង្អង់ចាំអ្វីទៀត ?

ចន្ទីចាប់យកក្រមារត់ចុះមកកំពង់ទឹកវិញ ហើយនឹងរៀបប្រាប់សោកណាថា :

-អ្នកអូន! លោកឪពុកបង្គាប់ថា ឲ្យហៅគាត់ឡើងទៅ ព្រោះទឹកសន្ស័យ ក្រែងសំឡាញ់របស់លោក ដែលឃាតគ្នាតាំងពីយូរណាស់មកហើយ នោះ ៗ សោកណាងក់ក្បាល ហើយឆ្លើយតបទៅវិញ ដោយទឹកមុខស្ងៀមស្ងាត់ថា:

-មែនហើយ អ្នកបង! លោកប៉ាខ្ញុំធ្វើដូច្នេះទើបសមទៅតាមច្បាប់មនុស្សធម៌ កុំថាឡើយជាសំឡាញ់របស់លោកប៉ា សូម្បីមនុស្សដទៃក៏ត្រូវតែធ្វើដូច្នេះដែរ ព្រោះការសង្គ្រោះជាករណីយកិច្ច នៃមនុស្សទាំងឡាយៗ រួចនារីនេះ ក៏បោះក្រមាទៅឲ្យអ្នកកំសត់យើង ហើយស្រែកប្រាប់ថា:

-តូ! ចូរយកក្រមានេះស្លៀកឡើងមក លោកខ្ញុំឲ្យតូឯងទៅឯផ្ទះមានការណ៍ ៗ

ដោយយល់ថា ឥឡូវដល់ភូមិគេហើយ ត្រូវតែឡើងគោក ទើបបុរសកំសត់យកក្រមានោះមកស្លៀកវណ្ឌពីក្រៅខោរហែក ហើយចុះលុយទឹកឡើងគោក ដើរតាមបន្ទាំងមុខក្រៀមស្រពោន ទាំងទឹកបារម្ភក្រែងមានហេតុដ៏មិនគប្បីអ្វីកើតមានឡើង ៗ លុះទៅដល់ផ្ទះហើយ បុរសកំសត់លុតជង្គង់សំពះធនសេដ្ឋី ។ ក៏លើកដៃសំពះមកវិញ ព្រមទាំងមានវាចាថា: “សំពះថ្វាយព្រះ” ហើយចង្អុលប្រាប់កន្ទេលឲ្យអាគន្តុកជនអង្គុយដ៏សមគួរ ៗ បុរសកំសត់មិនហ៊ានមើលមុខធនសេដ្ឋីទេ គឺអង្គុយមុខឱនចុះក្រៀមចាំស្តាប់ ក្រែងមានហេតុជាអនិដ្ឋារម្មណ៍កើតឡើង ៗ

ចំណែកកុដុម្ពិក លុះសំឡឹងសង្កេតមួយស្របក់ ទើបស្រែកថា "សិរីវឌ្ឍន៍ សិរីវឌ្ឍន៍! មែនឬទេ!" ។ អ្នកកំសត់ងើបមុខឡើង សំឡឹងចំធនសេដ្ឋី ស្រាប់តែក្តួលក្នុងខ្លួន ព្រោះអ្នកស្គាល់វាសំឡាញ់របស់ខ្លួនវិញដែរ ។ សេចក្តីកើតឡើងមកដល់ដើមក ទឹកភ្នែករៀបហូរចេញមក ប៉ុន្តែអ្នកខាំធ្មេញសង្កត់ចិត្តជាប់ ទើបឆ្លើយតិចៗទាំងសោកសួលថា: "មែនហើយ ខ្ញុំឈ្មោះសិរីវឌ្ឍន៍!" ។

លុះបានដឹងការណ៍ច្បាស់ហើយ ធនសេដ្ឋីក៏ស្ទុះចាប់ឱបសំឡាញ់ ទាញឲ្យក្រោកឡើង ព្រមទាំងមានសំដីសោកសួលពេញដោយការរំភើបដូចគ្នាដែរ ។ រួចលោកងាកទៅប្រាប់សោភណាដែលនៅជិតនោះថា:

-កូនស្រី ! ចូរប្រញាប់ ទៅយកខោអាវថ្មីមួយសម្រាប់មកឲ្យសិរីវឌ្ឍន៍ ហើយចូរមើលធ្វើបាយយ៉ាងឆាប់ៗផង ឮឬទេកូនស្រី !

លោកធនសេដ្ឋីបែរទៅប្រាប់ឈ្នួលប្រុសម្នាក់ថា:

-ឯងនាំសំឡាញ់អញទៅងូតទឹកជម្រះកាយយ៉ាងស្អាត ស្ដាប់បានឬទេ? ហើយលោកពោលដោយវាចាយ៉ាងស្និទ្ធស្នាលទៅកាន់សិរីវឌ្ឍន៍ថា:

-ទៅសំឡាញ់! ទៅងូតទឹកជម្រះប្រាណឲ្យស្អាត ឲ្យត្រជាក់ស្រួល សឹមយើងសន្ទនាគ្នាលេង ឈប់ព្រួយទៅ ឯងមកដល់ទីនេះហើយ!

ខាងក្រោយស្ពានកិច្ច ជនទាំងពីរនាក់ ចាប់សន្ទនាគ្នាពីនេះពីនោះ

មានពេលរំលឹកដល់សម័យ នៃការនៅរៀនសូត្រក្នុងសំណាក់លោកគ្រូអាចារ្យជាមួយគ្នាជាដើម ។ ប៉ុន្តែ អាកប្បកិរិយានៃជនទាំងពីរ មានសភាពផ្សេងគ្នា លោកធនសេដ្ឋីច្រើននិយាយសំដីធំៗខ្លាំងៗ ហើយបន្តិចៗតែងបួរលោកហៅសំឡាញ់ឲ្យជក់បារី ឲ្យផឹកតែ ចំណែកសិរីវឌ្ឍន៍និយាយសំដីតិចៗថមៗ ក្នុងឋានៈជាអ្នកមានសេចក្ដីគោរពក្រែង និងព្រួយបារម្ភ ។ ចួនកាលធនសេដ្ឋី សួរអំពីសេចក្ដីទុក្ខលំបាកដែលសិរីវឌ្ឍន៍បានជួបប្រទះក្នុងរយៈកាលនៃការដើរស្វះស្វែងរកស្រីគ្រប់លក្ខណ៍ ប៉ុន្តែលោកមិនហ៊ានបន្ទោសសំឡាញ់អំពីការចចេសមុខរឹងទេ គ្រាន់តែបន្ទុយពាក្យថា: មើលទៅដូចជាមិនងាយទេ ស្រីគ្រប់លក្ខណ៍ គួរសំឡាញ់លះបង់បំណងដ៏កម្រហ្នឹងចេញទៅ ៈ ដល់ត្រង់រឿងនេះ សិរីវឌ្ឍន៍គ្រាន់តែញឹមៗ មិនហ៊ានឆ្លើយតបថាដូចម្ដេចទៅវិញឡើយ ។

ខណៈនោះ សោភណាដើរបន្ទន់ខ្លួនបន្ទៀមៗចូលមករកអាពុក ហើយគេះដំរាបប្រសាសន៍តិចៗថា: បាយរៀបរួចហើយ ប៉ា ។

ធនសេដ្ឋីនាំសំឡាញ់ទៅបន្ទប់ទទួលទានអាហារ ។ លុះសិរីវឌ្ឍន៍បរិភោគឆ្អែតហើយ សំឡាញ់ទាំងពីរ ក៏ចាប់ផ្ដើមពោលសំណេះសំណាលគ្នាទៅទៀត អំពីរឿងផ្សេងៗ មានរឿងប្រកបការចិញ្ចឹមជីវិតជាដើមៗ សំឡាញ់លោកសេដ្ឋីពោលអំពីជីវភាពថ្មីៗ ដែលខ្លួនបានប្រទះឃើញក្នុងរយៈ ពេលនៃការធ្វើដំណើរស្វែងរកស្រីគ្រប់លក្ខណ៍ ។ ជាអវសាន

ធនសេដ្ឋីលោកួយសំដីថា:

អើសំឡាញ់! ឯងពិនិត្យកូនស្រីអញលមើល ៗ តើវាមានលក្ខណៈដូចម្ដេច? នឹងមានចូលក្នុងក្របខណ្ឌក្បួនតម្រាដែលសំឡាញ់បានរៀនមកនោះខ្លះដែរឬទេ?

• រួចពេកតស្រែកហៅឡើកូនស្រីមក ៗ សោភណាក៏ដើរចូលមកដោយសេចក្ដីគោរព ហើយអង្គុយបត់ជើង នៅចំពោះមុខសិរីវឌ្ឍន៍តាមសេចក្ដីបង្គាប់ឪពុក ៗ

សិរីវឌ្ឍន៍ចាប់ពិនិត្យចំពីមុខ មើលចំហៀង សួរនាងឲ្យនិយាយស្ដាប់សំឡេង សុំឲ្យនាងក្រោកដើរ ដើម្បីពិនិត្យដំណើរ ទីនឹងមើលកាន់ ៗ

លុះបានសង្កេតពិនិត្យលក្ខណៈសោភណាសព្វគ្រប់ហើយ សិរីវឌ្ឍន៍ញឹមៗ ៗ ដោយចង់ដឹងទាំងពេក ធនសេដ្ឋីសួរភ្លាមថា:

– ដូចម្ដេចទៅសំឡាញ់? ត្រូវសមដែរឬទេ?

ឈប់ស្ងៀមមួយស្របក់ ទើបសិរីវឌ្ឍន៍ឆ្លើយប្រាប់ថា:

– គ្រាន់បើសំឡាញ់!

ធនសេដ្ឋីឆ្លើយតបជាបន្ទាន់ទៅវិញឥតបង្អង់ថា:

– បើអីចឹង អញឲ្យឯងយកធ្វើជាភរិយា ឯងព្រមឬទេ?

ឮដូច្នោះភ្លាម អ្នកកំសត់យើងអស្រ្ចារ្យ ដោយទឹកក្នុងចិត្តជាបំណងតាំងសម្រេចហើយ តែមិនហ៊ានបញ្ចេញកាការគ្រេកអរឲ្យសំឡាញ់ដឹង

ខ្លាចក្រែងថួសការណ៍ ហើយអ្នកគ្រាន់តែឆ្លើយដោយពាក្យសុភាពថាៈ

ការណ៍ត្រង់ហ្នឹង ស្រេចតែលើសំឡាញ់ ខ្ញុំជាដើនក្រោយទេ ។

អាពាហ៍ពិពាហ៍បានប្រព្រឹត្តទៅ នៅថ្ងៃទី៧ ចាប់ពីពេលដែលមានសេចក្ដីព្រមព្រៀងគ្នារវាងសំឡាញ់ទាំងពីរ ។

## ជំពូក ៤

ក្រោយពិធីមង្គលការបានប្រាំពីរថ្ងៃ ក្នុងពេលរាត្រីប្រកបដោយបរិយាកាសត្រជាក់ស្រួល មានខ្យល់ដំនោរបក់មករហៀក ៗ សិរីវឌ្ឍន៍នឹងបិតាក្មេក អង្គុយសន្ទនាគ្នាលេងយ៉ាងសប្បាយរីករាយនៅត្រង់យ៉ផ្ទះ ។ យូរបន្តិចមក សិរីវឌ្ឍន៍ឆ្លៀតឱកាសនោះ ដើម្បីនិយាយនឹងឪពុកក្មេកថាៈ

-សំឡាញ់ ! បំណងខ្ញុំសម្រេចហើយ ។ ដូច្នេះ ខ្ញុំចង់ល្បងស្រីគ្រប់លក្ខណ៍មើល ។ សូមសំឡាញ់មើលដីភូមិត្រង់ណា ដែលតាមក្បួនមើលដីភូមិថា អាក្រក់បំផុត ជាភូមិដែលឈ្មោះណាទៅនៅហើយ តែងតែធ្វើឲ្យអ្នកនោះ ជួបប្រទះតែសេចក្ដីវិនាសហិនហោចជានិច្ច ខ្ញុំនឹងទៅនៅសាកមើល ។

លុះឮសំដីមិនគប្បីដូច្នេះជនសេដ្ឋីក្ដៅឆួល ដោយនឹកថា អានេះគ្មានអាណិតឯងសោះ ឯងកំពុងគិតនឹងរកមើលទីដីត្រង់ណាល្អគួរសម ដើម្បីឲ្យវាទៅនៅរកស៊ី ហើយកើតការរាលគុម្ពដូចឯងផង វាត្រឡប់ចង់រកតែសេចក្ដីវិនាស វាមិនពិចារណា មិននឹកដល់រឿងចំលើគល់ឈើអាក្រាត

មានតែខ្លួនទទេ អានេះចំជាអាឈាមកប់ វាមើលងាយដល់វិជ្ជា មើលដីភូមិរបស់ឯង ជាមិនដល់ស្រីគ្រប់លក្ខណ៍ វាមិនយល់ពាក្យបុរាណថា: "អាគមផ្សំអាយុ" សោះ អានេះជាមនុស្សអកតញ្ញូពេញទី ។ អើ! ជាមីទូចជាស្រីគ្រប់លក្ខណ៍មែនចុះ តែគ្រប់លក្ខណ៍ហ្នឹង នឹងទៅធ្វើដូចម្តេចឲ្យកើតទ្រព្យសម្បត្តិបាន បើវាខ្វះដើមទុន បើភូមិប្រាសចាកសេចក្តីសុខ គឺជាទេវតាមិនជួយថែរក្សា តើគ្រប់លក្ខណ៍ហ្នឹងអាចហាមឃាត់មិនឲ្យឈឺបានឬទេ បើខ្មោចព្រាយ អារក្ស អ្នកតា មិនព្រមសុខចិត្តរួមជាមួយនឹងយើងផង ? ។

ធនសេដ្ឋី មានចិត្តអាណិតកូនស្រីអាត្មាពន់ពេក ហើយនឹកថា: ឱ! សោកណាកូនស្ងួនអាពុក ធ្វើម្តេចប៉ាបានជាធ្លោយឲ្យកូនទៅអាចំក្អួតនេះរួចហើយ បើប៉ាដឹងគំនិតវាស្អុយបែបនេះ ប៉ាមិនធ្លាក់ឲ្យកូនឯងទៅវាឡើយ នេះគឺវាសនាអកុសលរបស់កូនដែលបានកសាងមក ។

រួចលោកសេដ្ឋីឆ្លើយតបយ៉ាងខ្លី បំពោះសិរីវឌ្ឍន៍ទាំងមុខស្មើស្មើ ក្រោយថា:

-បើសំឡាញ់ចង់ មិនជាការក្រអ្វី !

តមក សំឡាញ់ទាំងពីរក៏បែកចេញពីគ្នាដោយស្ងៀមស្ងាត់ ហើយទៅកាន់បន្ទប់ដំណេករៀងខ្លួន ។

ថ្ងៃជាបន្ទាប់មក ធនសេដ្ឋីចាប់ផ្តើមដើរពិនិត្យដីភូមិ ហើយបាន

ប្រទះដីមួយកន្ទេង នៅចម្ងាយប្រហែលប្រាំបីគីឡូម៉ែត្រពីផ្ទះអាត្មា ជាភូមិចាស់មានសុទ្ធតែព្រៃ និងដើមឈើធំ ៗ ស៊ុបទ្រុបដែលគេបោះបង់ចោលតាំងពីយូរអង្វែងឆ្នាំណាស់មកហើយ ព្រោះគេនៅពុំបានសុខសោះ ។ ពេលយប់ គេឮតែសំឡេងសត្វទូក ទីទុយ មៀម រលកខ្លាច ខ្វិងស្រាក គួរឲ្យព្រឺខ្លួនជាពន់ពេក ។ តែព្រលប់កាលណា ត្រង់នោះគ្មាននរណាហ៊ានដើរសោះឡើយ ព្រោះខ្លាចលង់សម្បើមណាស់ ជួនកាលវានិម្មិតជាស្រីក្រមុំ រំសាយសក់ទម្លាក់ពីលើចុងពោធិ៍មក ជួនកាលវាធ្វើជាពស់ថ្លាន់ ឬជាទឹកនៅពេញតែផ្លូវ ឬជាខ្លា ជាឆ្មា ។ល។

តាមក្បួនតម្រាមើលដីភូមិ ទីនោះមានការចង្រៃនិងការហិនហោចរកទីដទៃមកប្រៀបពុំបាន គឺថា បើឈ្មោះណាហ៊ានទៅនៅ ទោះបីខ្លួនធ្លាប់មានទ្រព្យសម្បត្តិជាមហាសេដ្ឋី ជាអ្នកមានយសសក្តិធំក្តី និងត្រូវតែប្រែក្លាយជាអ្នកទុគ៌ត ឬរបូតងារសក្តិចេញដោយពិត ៗ បើអ្នកនោះទីទ័លក្រស្រាប់ គង់តែហិនហោចហេមហោចអស់មួយជីវិត សូម្បីខ្លួនប៉ិនប្រសប់យ៉ាងណាក៏ដោយ ។

លុះរកដីភូមិបានហើយ ជនសេដ្ឋនាំសិរីវ័ន្ទទៅចង្អុលប្រាប់ដោយសំដីព្រះគោះព្រះបោកថា :

–នុះន៎! ដីត្រង់នុះហើយ សំឡាញ់! បើឯងចង់ហិនហោច ចូរទៅនៅចុះ! ៗ

(មានត)

# តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

## ការស្រាវជ្រាវ

## រកប្រភពនៃបុណ្យកាន់បិណ្ឌ និង ភ្ជុំបិណ្ឌ

លោក ចាប-ពិន រៀបរៀង

## តាមដែលបានស្រាវជ្រាវមកឃើញថា៖

ក្នុងប្រទេសកម្ពុជាយើងមានសាស្ត្រា ឬគម្ពីរ ៣ បែប ដែលពីប្រភព គឺដើមកំណើតនៃបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ ដូចបានស្រង់ខ្លី ៗ មកបរិយាយតទៅនេះ ៖

### ១–សាស្ត្រាវិជ្ជាធរថែងថា ៖

កាលព្រះសម្មាសម្ពុទ្ធគង់ព្រះជន្មនៅឡើយ មានព្រះមហាថេរ ១ រូប ឈ្មោះព្រះឧបគុត្តត្ថេរ បានហោះទៅកាន់ឋាននរក ៗ ពេលនោះ ដោយឫទ្ធិរបស់លោក ពួកសត្វនរកបានដកដង្ហើមស្រួលចស្រាក់ ក៏នាំគ្នាផ្ដាំលោកថា « សូមប្រាប់ម្ដាយឪពុកបងប្អូនកូនចៅញាតិផៅរបស់យើងខ្ញុំ មានឈ្មោះដូច្នោះ ៗ នៅស្រុកឈ្មោះដូច្នោះ ៗ សូមឲ្យអាសូរករុណាមកដល់យើងខ្ញុំ ធ្វើបុណ្យឲ្យទានឧទ្ទិសផលមកឲ្យយើងខ្ញុំផងកុំខាន បើដល់រនោចខែភទ្របទហើយ ញាតិសន្តានបានធ្វើបុណ្យឲ្យទានឧទ្ទិសផលមកឲ្យយើង, យើងខ្ញុំគ្រប់គ្នានឹងឲ្យពរសព្ទសាធុការដល់ពួក

ញាតិទាំងនោះឲ្យបានសេចក្ដីសុខសប្បាយ » ។ល។

កាលព្រះមោគ្គល្លានត្រឡប់ពីឋាននរកមកវិញ លោកបានថ្វាយព្រះពរព្រះរាជា ១ ព្រះអង្គ ព្រះរាជាអង្គនោះទ្រង់បានទូលសួរព្រះសម្មាសម្ពុទ្ធថា « បើមាតា - បិតា ញាតិការបស់យើងខ្ញុំស្លាប់ទៅ ។ សោយទុក្ខក្នុងនរកហើយ យើងខ្ញុំត្រូវការធ្វើបុណ្យឧទ្ទិសផលជូនទៅលោក តើត្រូវធ្វើបុណ្យអ្វី ? » ។

ព្រះដ៏មានបុណ្យទ្រង់ត្រាស់ថា « ត្រូវធ្វើបាយបិណ្ឌបាយបត្តបូរ ពលថ្ងៃតាំងពីថ្ងៃ ១ កេចទៅដល់ថ្ងៃ ១៥ កេច ខែភទ្របទ, ត្រូវសមាទានសីល ៥ និងឧបោសថសីល, ត្រូវនិមន្តព្រះសង្ឃសូត្រធម៌ទេសនាជារៀងរាល់ព្រឹក ហើយត្រូវឧទ្ទិសផលជូនទៅពួកញាតិសន្ដានដែលទៅកើតក្នុងទុគ្គតិភព, ញាតិទាំងនោះនឹងរួចផុតចាកទុក្ខ បានសុខក្នុងសុគតិភព ដូចសេចក្ដីប្រាថ្នា » ។ល។

## ២-សាស្ត្រាអានិសង្សបិណ្ឌបែងបិា :

ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ចំពោះអនាថបិណ្ឌិកសេដ្ឋីថា « កែដល់រនោចខែភទ្របទ ដែលគេរៀបកាន់បិណ្ឌនោះ ម្ដាយឪពុក និងញាតិសន្ដាន ដែលស្លាប់ទៅកើតក្នុងទុគ្គតិភពទាំងប៉ុន្មាន សុទ្ធតែបានមកជួបជុំចាំទទួលផលដែលកូនចៅបានធ្វើបុណ្យកាន់បិណ្ឌ និង ក្ដុំបិណ្ឌឧទ្ទិសជូនទៅឲ្យ ។ ដោយអំណាចអានិសង្សប្រគេនបាយបិណ្ឌបាយបត្តបូរដល់

ព្រះសង្ឃនៅវេលាចេញខែកត្តិក ដែលកូនចៅខ្ញុំសូមជូនទៅនោះ ពួកញាតិទាំងប៉ុន្មានក៏បានរួចរំដោះចាកទុគ្គតិភព ទៅកើតក្នុងឋានសួគ៌ទេវលោកដូចសេចក្តីប្រាថ្នា ..." ។ល។

៣–គម្ពីរបេតវត្ថុចែងថា :

កាលព្រះសម្មាសម្ពុទ្ធគង់ព្រះជន្មមាននៅឡើយ មានព្រានម្នាក់នៅក្រុងពារាណសី តែងទៅបាញ់សត្វក្នុងព្រៃ កាលព្រានត្រឡប់ពីព្រៃមកវិញ ពួកកូនក្មេងតែងដេញតាមពេមសុំសាច់រាល់ថ្ងៃ ។ ថ្ងៃមួយ ព្រានទៅបាញ់សត្វ ព្រានក៏បេះផ្កាត្របែក ឬផ្កាកដព្រឹក្សចងជុំវិញខ្លួនខ្លះ រែកខ្លះ យកមកផ្ទះ ។

លុះពួកក្មេងសុំសាច់ ព្រានក៏ឲ្យផ្កានោះ ១ ស្នែងម្នាក់ ។ ដោយទោសនេះ ដល់ព្រាននោះស្លាប់ទៅ ។ កើតជាប្រេតអាក្រាត មានផ្កាត្របែក ឬ ផ្កាកដព្រឹក្សជាប់នៅនឹងក្បាលដើរក្នុងទឹក ដើម្បីទៅសុំអាហារអំពីពួកញាតិបរិភោគ ។ វេលានោះគោលិយអាមាត្យនៃព្រះបាទពិម្ពិសារ ជិះទូកទៅបង្ក្រាបស្រុកបច្ចន្តគ្រាមបានឃើញប្រេត ហើយមានសេចក្តីអាណិតក៏សួរប្រេតថា "យើងមានសត្វជុំ បើយើងត្រូវការឲ្យអ្នកតើធ្វើម្តេចអ្នកទើបនឹងទទួលបរិភោគបាន ?" ។ ប្រេតឆ្លើយថា "បើក្នុងទូកនេះមានឧបាសកណាជាអ្នកមានត្រៃសរណគមន៍ មានសីល សូមលោកឲ្យសត្វដល់ឧបាសកនោះ ហើយឧទ្ទិសផលឲ្យមកខ្ញុំចុះ ..." ។ គោលិយ-

អាមាត្យធ្វើតាមប្រេតប្រាប់ ប្រេតក៏បានរួចចាកប្រេតភូមិនោះ ហើយប្រេតនោះផ្ដាំថា "សូមលោកមេត្តា បើលោកធ្វើបុណ្យទានឯណានីមួយ ហើយសូមឧទ្ទិសផលដល់ប្រេតឯទៀតៗផង" ។ លុះកាលយអាមាត្យត្រឡប់មកស្រុកវិញ បានថ្វាយពានចំពោះព្រះពុទ្ធជាម្ចាស់ហើយ ក្រាបបង្គំទូលរឿងប្រេតនោះ ព្រះអង្គទ្រង់សំដែងទេសនាឲ្យប្រាកដឡើងដល់ពុទ្ធបរិស័ទក្នុងគ្រានោះ ។ល។

បណ្ដាសាស្ត្រនិងគម្ពីរទាំង ៣ គឺ សាស្ត្រវិជ្ជាធរ និងសាស្ត្រអានិសង្សបិណ្ឌ ជាសាស្ត្រសម្រាយ គ្មានឈ្មោះអ្នកតែង គ្មានប្រាប់ថាតែងក្នុងសម័យណាទេ, ឯគម្ពីរ ១ គឺគម្ពីរបេតវត្ថុ ជាអដ្ឋកថាព្រះសុត្តន្តបិដក ខុទ្ទកនិកាយ ព្រះធម្មបាលចារ្យតែងក្នុងសម័យក្រោយពុទ្ធបរិនិព្វាន ដំណាលគ្នានឹងអដ្ឋកថាព្រះសុត្តន្តបិដកទាំងពួង ។

ការពិចារណាតាមរូបរឿងក្នុងសាស្ត្រ និងគម្ពីរដែលពោលមកហើយនេះ ឃើញថារបៀបបុណ្យកាន់បិណ្ឌក្នុងកម្ពុជរដ្ឋយើងនេះ ត្រូវតាមសេចក្ដីក្នុងសាស្ត្រវិជ្ជាធរខ្លះ សាស្ត្រអានិសង្សបិណ្ឌខ្លះ គម្ពីរបេតវត្ថុខ្លះ គឺកំណត់ថ្ងៃ-ខែធ្វើ ត្រូវតាមសាស្ត្រវិជ្ជាធរ និងសាស្ត្រអានិសង្សបិណ្ឌ, ឯរបៀបធ្វើផ្កាបិណ្ឌនិងកិច្ចឧទ្ទិសផលទៅប្រេត ត្រូវតាមគម្ពីរបេតវត្ថុ គឺបាយបិណ្ឌដែលគេធ្វើឧទ្ទិសឲ្យប្រេតនោះ គេប្រដាប់ដោយផ្កាធ្វើពីស្លាតក្រាប ឬក្រដាសពណ៌និងផ្កាឈើផ្សេងៗ មាន

ទំនងប្រហែលគ្នា នឹងការរបស់ប្រេតដែលមានចែងក្នុងគម្ពីរបេតវត្ថុ នោះថា ប្រេតមានផ្កាត្របែកប្រដាប់ក្បាលដើរមករកអាហារ ឯផ្ទះញាតិរបស់ខ្លួន គឺថា ទំនៀមដែលគេធ្វើបាយបិណ្ឌ បាយបត្តបូប្រគេនព្រះសង្ឃ ដោយមានក្បូរក្បាច់ក្ដាំផ្កាជាល់ប្លែកពីបិណ្ឌបាតទានឯទៀត ប្រហែលជាបុរាណបណ្ឌិតប្រឌិតធ្វើតាមរឿងប្រេតក្នុងគម្ពីរបេតវត្ថុនោះឯង ។

ការដែលពុទ្ធបរិស័ទជាតិខ្មែរ តែងដល់ថ្ងៃ ១ រោចខែភទ្របទ តែងនាំគ្នាទៅកាន់បិណ្ឌ ក្នុងទីអារាមរាល់ថ្ងៃ ដរាបដល់ថ្ងៃ ១៥ រោច គេភ្ជុំគ្នាធ្វើបង្ហើយហៅថា ភ្ជុំបិណ្ឌ ទោះបីអ្នកទ័លក្រលំបាកយ៉ាងណាក៏ធ្វើឲ្យបានយ៉ាងតិចណាស់ត្រឹមថ្ងៃភ្ជុំ ជាថ្ងៃបង្ហើយពុំហ៊ានខាននោះ ក៏ដោយហេតុគេជឿតាមសាស្ត្រាវិជ្ជាធរ សាស្ត្រាអានិសង្សបិណ្ឌ គម្ពីរបេតវត្ថុ ហើយនឹងជឿតាមដំណើរចាស់ ៗ ដែលធ្លាប់ធ្វើឲ្យឃើញរៀងៗមកតែរឿយ ៗ ដោយមានចិត្តអាណិតដល់មាតាបិតាជីដូនជីតា និងញាតិសន្តានដែលចែកឋានទៅហើយ ។

បរិយាយពីប្រភពនៃបុណ្យកាន់បិណ្ឌ និង ភ្ជុំបិណ្ឌចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

---

# រឿងមរណមាតា

(តមក)

លោក ប៊ី សុវណ្ណ បម្រួលពីសាស្ត្រាស្លឹករឹត

កុដុម្ពីកប្រែជាខ្វាត់ ខ្វាយប្រាកដកើតសៅហ្មង ខ្ញុំរត់ហោលអស់ផង
នៅតែកូននឹងភរិយា ។ ទើបគិតនឹងប្រពន្ធ ថាទ្រព្យធនទូទៅសា
អន្តរាយការនោគា យើងបានមុំចិញ្ចឹមជន្ម ។ នាងកុលកេសីឆ្លើយ
ថាអ្នកអើយយើងគិតគន់ គិតដួញសព្វដំបន់ បានចំណេញបរិភោគា ។
កាលឆ្លើយទៅវិញ ថាយើងចេញទៅផ្សារណា រកទិញសំណាញ់ផ្កា
ចេញទៅបង់ត្រីប្រាកដ ។ បានត្រីមកដូរដាក់ លក់យកប្រាក់តាម
កំសត់ ចិញ្ចឹមជន្មកំណត់ កំណើតក្រដូច្នេះណា ។ កុដុម្ពីជាសាមី
ស្តាប់កាលត្រូវចិន្តា ទទួលពាក្យទៅថា គិតនោះគាប់ណាស់នាងអើយ ។
ឯនាងកុលកេសី យាត់ស្រដីថាអ្នកអើយ កុំគិតប្រមាទឡើយ គួរគោ-
រពដោយធម្មា ។ ជាតិនេះយើងលំបាក ហ៊ានគោកយ៉ាកព្រោះវេរា
យើងពីអតីតា ទើបកើតមកលំបាកម្ល៉េះ ។ យើងខ្ញុំធ្វើវេរា កម្មបា-
ណាក្នុងជាតិនេះ យើងគួរនាំគារវះ រកកាប់ខុសបេះបន្លែ ។ ទៅ
លក់ចិញ្ចឹមជន្ម ដោយដំបន់ចំការស្រែ តាមក្រគាមបុព្វេ កុំសាងបាប
កម្មទៀតទៅ ។ កាលស្តាប់ហើយខឹង ខំសំឡឹងមើលក្រឡៅ ក្រ-
ឡេកភ្នែកមើលទៅ ក្តៅក្នុងចិត្តឥតឧបមា ។ ស្រីដីលូកលឡក ល-

ចុំអកចុំអេងថា លោកជាអ្នកប្រាជ្ញ ចិត្តដឹងទាស់ដឹងបាបបុណ្យ ។
លោកទៅកេទ្ចសនោះ មកលក់ចុះចិញ្ចឹមជន យើងពីរប្ដីប្រពន្ធ ជា
អ្នកល្ងង់ទុព្ភលភាព ។ ពុំដឹងការកុសល បុណ្យមគ្គផលអស់ដកពប
យើងពីរជាអ្នកបាប យើងទៅបង់ត្រីចុះវិញ ។ ថាហើយនាំគ្នាកេ
ប្រាក់បានមកដើររកទិញ សំណាញ់បានមកមិញ បង់ត្រីលក់ដូចចិន្ដា ។
ឯនាងកុលកេសី បរបួលព្រៃព្រួលព្រឹក្សា កាច់ទ្ចសបេះផ្លា ត្រើង
ពង្រលក់អាស្រ័យ ។ មួយថ្ងៃបានមួយស៊ឹង មួយហ្វូងទីងហើយមួយ
ពៃ បានប្រាក់ហើយស្រីថ្វៃ ដើររកទិញទំចំណី ។ មកផ្ញើគ្នាដំទ្វេ
ហា បុត្រអាត្មាបុត្រកាលី ដោយចិត្តនាងមេត្រី ស្ម័គ្រស្មើគ្នាមិនដូច
គេ ។ ផ្ចិតទឹកបញ្ចុកបាយ ថែសប្បាយដេកបំពេ ស្រឡាញ់
បុត្រទាំងទ្វេ មិនថាកូនគេឯងឡើយ ។ កុដុម្ពីកន្ទ្វកាលី ទៅបង់ត្រី
បានមកហើយ ឯនាងពុំះគោះគើយ ជួយជញ្ជូនត្រីដូរលក់ ។ ជួបមុខ
កុលកេសី មេកាលីមិនមានសុខ ក្ដៅក្ដាត់ចិត្តជាទុក្ខ តែងដៀមដាម
ដៀលយ៉ាងភាប ។ បញ្ឆៀសដេរស្ដីថា ទៅផ្តែក្ដាកល់ព្រឹកល្ងាច
ញុះញង់ប្ដីឲ្យកាច ឲ្យកើតស្អប់កុលកេសី ។ ថានាងមានសហាយ
ប្រុសទាំងឡាយជាស្វាមី បើបានទំចំណី យកទៅជូនសហាយវ៉ា ។
ស៊ីផ្អែកសេសសល់ក្រោយ យកមកឲ្យអ្នកពិសា ទៅស្និទ្ធទៅស្នេហា
ទីងសហាយជាប្រក្រតី ។ កុដុម្ពីកដេរហើយថា កាលដើមវ៉ាមានមេត្រី

ស្លូតត្រង់នឹងស្វាមី ទើបកើតមានទ្រព្យសម្បត្តិ ។ ឥឡូវក៏ក្សត់ប្តី ខ្ញុំ
ប្រុសស្រីតត់ខ្លាយខ្លាត ខូចទ្រព្យខូចសម្បត្តិ ព្រោះតែចោរបើកអប្រិយ ។
កុដុម្ពិកស្វាមីនោះ ដេរចំពោះមុខកាលី ដេរវាយកុលកេសី ថាប្រមូល
ពេកណាស់ណា ។ ថាមានប្រុសជាទៃ មិនមូលមែសង្សារ បាននិចណាវា
ជូនទៅប្រុសជាប្រក្រតី ។ នាំគ្នាស៊ីសប្បាយ នឹងសហាយកលកត្រី
ផ្អែតផ្អូលសល់ចំណី ទើបឲ្យឯងស៊ីក្រោយវា ។ កុដុម្ពិកដេរស្រដី
វាយកេសីសព្វវេលា តែឈ្មោះឡើងកាលណា ដៀលកេរ្តិ៍កោះឲ្យ
អាម៉ាស់ ។ ថ្ងៃមួយនោះកាលី ប្រាប់ស្វាមីថាអ្នកម្ចាស់ ខ្ញុំចង់នៅ
ផ្ទះណាស់ ពីរបីថ្ងៃផ្សៀតឈឺក្បាល ។ កុដុម្ពិកជាស្វាមី នាំកេសីចេញត្រ-
អាល ទៅបង់ត្រីដូចកាល ពីមុនក្បួតាមកាលនោះ ។ វាដែងមិន
បានត្រី ឯស្វាមីញរញុំពោះ ខឹងខេរដេរគំរោះ ថាមេនេះស្រីចង្រៃ ។
ទើបដែងពុំបានត្រី មេអប្រិយកាន់កន្ទៀ វាទកវាអាល័យ សហាយវា
ទើបដែងម៉េះ ។ ឯនាងកុលកេសី ឮស្វាមីដេរដៀលគះ ខំអត់ចិត្តគិត
រិះ ខ្លាចស្វាមីពុំគប់ប្ដាត់ ។ កុដុម្ពិកជាស្វាមី ស្អប់កេសីខឹងមិនបាត់
ហាស្តីដេរពលមាត់ ពល់ៗល្ងាចមិនបាត់ង៉ាយ ។ ខ្លួនរាថាកេសី
បានប្រុសថ្មីជាសហាយ នាងស្ដាប់ញរត្នងកាយ ខឹងអត់សៀម
នៅពុំបាន ។ ទើបមានពាក្យឆ្លើយថា បពិត្រស្វាមីប្រធាន អ្នកដេរ
វាយប៉ុន្មាន ខ្ញុំអាចអត់ឥតបើថា ។ គួរតែអ្នកពិនិត្យ មើលយល់ពិត

នឹងប្រុសណា ត្បិតកំសត់នឹងគ្នា ពីមុនមានគុណខ្វះដៃរ ៗ ម្តេចពុំពិ-
តារណា រកទោសាឲ្យប្រហែល ទំដេរថ្វីដែល ៗ បើឃើញធ្វើតាម
ទោសចុះ ៗ

អនិច្ចាថៃងអំពី គុណកេសីឲ្យចំពោះ កាលមុនកុដុម្ពីក៍នោះ ជាតិ
ជាកូនអ្នកស្រែក្រៅ ៗ ឯនាងកុលកេសី ជាបុត្រីមេស្រុកនៅ
កុដុម្ពីក៍នោះបានទៅ ស្ត្រីស្នាភមនឹងកេសី ៗ ទើបនាំគ្នារត់ទៅ អា-
ស្រ័យនៅក្រៅបុរី ជាចុងស្រុកក្តន្ទី កាសីខេត្តពជសីមា ៗ រីឯអ្នក
ស្រុកនោះ សឹងស្រួលស្រុះបបួលគ្នា ធ្វើចោរលួចទ្រព្យា មកចិញ្ចឹម
ជីវិតនៅ ៗ លុះដល់រដូវកាល ធ្វើជាពាលចោរឃោរ យៅ នាំគ្នាចរចូល
ទៅ ឃ្មាំចាំផ្លូវចាប់មនុស្សា ៗ បើបានហើយពិឃាដ ខ្ញុំជនជាតិ
ពុំការ អាក្រក់ដែលរក្សា ស្លិតកន្ទៃព្រសូមជ័យលាភ ៗ កុដុម្ពីក៍
កុលកេសី នាំគ្នាលីលាដកប ដល់ស្រុកចោរទោមចាប់ ទូវកុដុម្ពីក៍បាន
ហើយណា ៗ ប៉ុនប៉ងនឹងពិឃាដ ថ្វាញជន្មជាតិពុំការ កេសីភ័យ
តក្កមា យកចិញ្ចៀនមាសមួយនៅ ៗ អង្វរមេស្រុកថា សូមមេត្តា
ទុកប្តីនៅ មេស្រុកមេត្តាទៅ កុលកេសីស្តីទៅថា ៗ ហែអស់គ្នាយើងអើយ
កុំចាប់ឡើយលែងទៅក៏ ព្រោះតនាងនេះជាប់ជា ញាតិសាច់យើងទេ
លែងទៅ ៗ ឯចោរទាំងនោះស្តាប់ ព្រមប្រាប់ថាញាតិដៅ ឲ្យ
លែងប្តីនាងទៅ ទើបស្រាយលែងចេញមួយមា ៗ ហេតុនោះកុលកេសី

នាងស្រដីតបទៅថា បើអ្នកខឹងម្តេចម្តា សូមគិតកាលត្រាក់សត់ ។ កុដុម្ពិកក្បៀកស៊ី គប់សេចក្ដីខឹងពុំអត់ ក្នុងពោះញ័រខ្ទត់ ចាប់ប្រវ៉ា ឡើងសំពង ។ វាយវ័ធក្បាក់ទឹកត្រាំ ហើយឈរច្រំទឹងប្រវ៉ា មិនមានទឹកមេត្តា មិនអាណិតកុលកេសី ។ នាងក្រៀណក្រៀយផ្ទា ចាប់ជាតិជាត្រីដំរី ហែលទៅជាប្រក្រតី ទឹកពង់ទឹកនោះណាំ ។

## បទកាកគតិ

រីឯកុដុម្ពិក វាយកុលកេលី ស្លាប់ហើយម្ដីមា មកផ្ទះប្រញាប់ ខ្សិបប្រាប់ភរិយា ថាបើកូនវ៉ា សួរកេម្ដាយនោះ ។ យើងប្រាប់ថាម្ដាយ រត់តាមសហាយ គិតគ្នាដូច្នោះ ហើយទើបលើនា ត្រៃហាក្សាមចុះ ឯបុត្រីនោះ មើលផ្លូវមាតា ។

## បទព្រហ្មគីតិ

ថ្ងៃនពីកូនកេសី ឈ្មោះនាងស្រីកុមារិកា អាយុដប់ឆ្នាំណា នាងចាំផ្ទះមើលផ្លូវម្ដាយ ។ នាងឃើញតែឪពុក នាងជាទុក្ខរលឹកម្ដាយ ដើរទៅសួរនិយាយ ថាឪនើយណាម៉ែខ្ញុំ ។ មិនឃើញគាត់ទៅណា ឪពុកថាថ្ងៃហង់យំ កុំដណ្ដឹងដើមដំ- រណើរម្ដាយហង់ទៅទៀត ។ នាងជាព្រឹកមិញទេ ឪនាំម៉ែទៅបង់ត្រី ម៉ែពុនសំណាញ់ថ្មី ឪឯងលើថ្នាល ដើរមុន ។ ឪអើយប្រាប់ខ្ញុំក្រ- ក្រូងកូនផ្កាកុំអន់ ប្ដីម៉ែដើរមិនទាន់

៙មកមុនដើរហោលគាត់ ។ ៙នាំកូនទៅយក ម៉ែខ្ញុំមកក្រែងអស់សត្វ ពដេញពហោមព័ទ្ធ គាត់ជាស្រីសមគិតភ័យ ។ ៙ពុកវិលវេះថា កូនពុំដាក់គិតអ្វី ម្តាយសួនកមានប្តី រត់ទៅតាមសហាយក ។ នាងស្តាប់៙ពុកថ្លែង ថា៙ឯងលាក់ដឹងក៏ ម៉ែខ្ញុំទៅឯណា ៙ប្រាប់ខ្ញុំឲ្យត្រង់ទៅ ។ ៙ពុកកុហកទៀត ប្រាប់បំបៀតបំបាំងនៅ ម្តាយកូនមាសល្អញញល្អ មុខទឹកទៅឯនាគនាយ ។ នាងដឹងនឹងប្រាជ្ញា បុណ្យកសនាថាអ្នកម្តាយ ៙ពុកអញគាត់កយ គាត់សម្លាប់ពីព្រឹកមិញ ។ ដឹងហើយញ៉ាំចំប្រប់ ទួញសន្ទប់ភ្ញាក់ឡើងវិញ គក់ទ្រូងដំប្រដេញ ថាម្ល៉េះហើយសមក់ក្រោ ។ កូនអត់ពីម៉ែទៅ ឲ្យកូននៅទីនេណា គេទីនសន្ទោក្យ កូនស្នេហាដូចអ្នកម្តាយ ។ ម៉ែមកឲ្យឆាប់ ៗ ទៅជាប់ជតឬទៅឆ្ងាយ មកយកកូនឯអាយ កូនទីទៅនៅទីអ្នក ។ អ្នកម៉ែកូនហៅហើយ មិនព្រួយឆ្លើយមកឬអ្នក ឬមួយបានដៃយក្ស កនាំអ្នកទៅឯនាយ ។ បានជាមិនឆ្លើយ ដូចម្តេចឡើយឬខ្មោចព្រាយ អារក្សក្លួតផងកយ សត្វពាំនឡាយចិកខាំស្លាប់ ។ មិនមានដំណឹងឡើយ ម្ចាស់កូនអើយឥតគេប្រាប់ ម៉ែរស់ឬម៉ែស្លាប់ ឲ្យប្រាកដកូននឹងដឹង ។ ឱ ម៉ែម្តេចមិនឆ្លើយ ហៅឡើយៗ ចំសំឡឹង ទ្រូងកូនរឹងតានតឹង រឹងចង្អៀតថៃថប់សល់ ។ កូនរស់នៅពុំគាប់ សូវកូនស្លាប់សោះអំពល់ កូនទួញដកបដល់ ជាច់ខ្យល់ស្លាប់តាមម៉ែណា ។ នាងទួញៗ ពនពេក ស្រែកទឹកភ្នែកស្រោច

ភក្ត្រា ទន់អស់កំលាំងកាយា អត់តាំងអាហារសន្ធៃ ៗ ខ្សឹកខ្សួលអួលអាក់
អន់ ហាក់ទឹងស្រន់ទួញទៀតនៃ លន់លង់ឥតស្មារតី ស្គាំងស្គមក្រៃ
ស្ងឹតស្ងាំងថ្ងស់ ៗ ទើបឪពុកគិតថា កូនពុំងាអញល្អណាស់ ហាក់
ស្រីស្មគ្គិស្រៀវស្រស់ យំទួញខ្លាំងយល់ចម្លែក ៗ សម្បូរប្រមុខជ្រប់
ស្រិញស្រស់ស្រប់មិនបើកភ្នែក អញមើលឃើញដូចប្លែក បើមិនឃាត់
កូននេះស្លាប់ ៗ ជាហែមាសឪពុក កុំទួញទុក្ខយំអួរអាប់ អញ
ខឹងអញវាយស្លាប់ ចូរកូនស្ងៀមក្ងូវទៅវិញ ៗ នាងឮពាក្យឪពុក ខឹង
គំហកគំហរមិញ នាងថាឪឪអញ ខឹងសម្លាប់អញទៀតនៃ ៗ ទើប
នាងខំក្រោកឈោង ចាប់ប្រគោងដើរយកដៃ ដូតទេក្រគន់រវៃ ឈ្ងោក
រកម្ដាយសព្វច្រកផ្លូវ ៗ ពុំឃើញខាងស្រយុត ដើរដួលស្ទុតលុតឡើង
ទៅ លើផ្ទះហើយស្រែកហៅ ម៉ែទៅណាចោលកូនបាត់ ៗ កូនដូច
កូនចាបព្រាប ឥតមេក្រាបថ្មប្រយ័ត្ន ឡើងឡង់រកមេបាត់ សសិត
ស្លាបក្រាបខ្លួនឯង ៗ ពីថ្ងៃនេះទៅមុខ សមជាទុក្ខស្ងាត់សូន្យផង
ឈឺស្លាប់តែម្នាក់ឯង ឥតញាតិព្រៀងមួយគិតដល់ ៗ ទឹងស្ទួរដណ្ដឹង
ណ៎ា ជួយដេរថាឡេរៀនស្គាល់ កិច្ចការអាចថ្នាក់ថ្នល់ ប្រដៅកូនឡេ
បេះដូង ៗ ម៉ែអើយខ្លួនកូននេះ មិនចាន់ចេះការផ្សេងៗ បេះតែ
ដើររត់លេង សព្វៃដោយល្បែងធ្លាប់សប្បាយ ៗ ដើរលេងលុះម៉ែទៅ
ដើររកហៅកូនហួបបាយ នាំកូនដេកនិយាយ ឥឡូវអើយស្ងាត់ជ្រង៉ំ ៗ

ឱម៉ែកូនស្រមៃ ដូចសំដីម៉ែហៅខ្ញុំ ចាំងកូនមិនបាត់ធុំ បាត់តែខ្លួនពួន គ្រង់ណា ៗ កូនឃើញតែពូកព្រំ តែត្របៀមចាំខ្នើយត្រៀបត្រា ម៉ែដេកនៅនេះណា ប្រកបកូនប្រឡែង ៗ ឱកម្មពីបុកណា ខ្លួនកូនបានសាងពីព្រេង ទើបឥឡូវនេះឯង ព្រាត់ប្រាសម្ដាយពីខ្លួនចេញ ៗ នឹងថាអ្វីលើសកម្ម ឯងតែងតាមពីមុនមិញ ឲ្យរងទុក្ខផ្សារម្ញាញ កម្មអញម្ដេចដល់ម៉្លេះណា ៗ កម្មឲ្យកូនវល់ទុក្ខ ពុំស្រណុកក្នុងចិន្ដា សោកសៅក្ដៅខ្លោចផ្សា តាំងពីថ្ងៃដល់យប់មក ៗ កូនដេកឱបតែខ្លួន មិនលក់សូន្យកូនស្ទាបរក មិនឃើញម៉ែហើយក្រោក កូនដើររកម៉ែក្នុងផ្ទះ ៗ កូនស្ទាបរកអស់ថៃ សព្វពូកគ្រែមិនប្រទះ បពិត្រតេជតេជៈឲ្យយល់សប្ដិយប់នេះណា ៗ

## បទកាកគតិ

អ្នកម្ដាយកូនអើយ ម៉្លេះកូនឥតត្រើយ ឥតពឹងឥតពួន ឥតអ្នកណាទឹង ទីពឹងផ្ញើខ្លួន ឯងឥតទីពួន ទីពឹងអាត្មា ៗ សង្ឃឹមជនក បិត្តគាត់អាក្រក់ វង្វេងបុស្សា អ្នកយកកូនទៅ ផងនៅអ្នកណា អ្នកនៅឋានណា ជិតឬឆ្ងាយៈហើយ ៗ ធ្វើម្ដេចនឹងដឹង ដំណើរដំណឹង គ្រាន់បានសះស្បើយ អ្នកក័យពទ្ទឹក ខ្វាចទឹកណាស់ហើយ អម្ចាស់កូនអើយ សមគួរយជន្មា ៗ មួយទៀតឬអ្នក ឪពុកគាត់អាក់ គាត់អន់ចិន្ដា ទេវទឹងក៏យដំ ម្ដាយខ្ញុំមរៈណា ឬក្រពើរ៉ាំ ខាំពាំទៅស៊ី ៗ ធ្វើម្ដេចនឹងបាន យង់យល់រូបប្រាណ

សាកសពជនទី ពោះអង្គកាយា សិរសាអ្នកគ្រី មិនបានយល់ទី យល់
សាកអស្មុក ៗ ឬមួយក្រែងយក្ស បិសាចនាំអ្នក លបលួច
លាក់លុប ទើបបាត់យូរក្រៃ ពីថ្ងៃលុះយប់ ខ្ញុំអញគិតគ្រប់ គិត
ក្រែងអ្នកម្តាយ ៗ អន់អាក់ទីងទុ គាត់ដើរខ្វីខ្វៅ រតបាត់ខ្លាតខ្លាយ
ថាបើអ្នកនៅ ឬទៅស្រុកឆ្ងាយ កំគួរអ្នកម្តាយ យកកូនទៅផង ៗ
ម្តេចអ្នកចោលកូន បង់បោះសោះសូន្យ ពុំគិតឡើយហោង ខ្ញុំឥតអ្នក
ណា រក្សាស្ងួនគ្រង ស្មាលស្ងួតស្នេហ៍ស្នង ដូចអ្នកឡើយណា ៗ
ឃើញតែដំណេក ដំណែលដែលដេក ជាដានមាតា កន្ទេលពូក
ខ្នល់ ខ្នើយកល់សិរសា រៀបរៀងល្អជា ទំនងនិត្យនៅ ៗ កូន
មើលហើយនៃ កូនទឹកស្រវៃ ស្រមើគិតទៅ ហាក់ដូចអ្នកម៉ែ
ប្រិតប្រែហៅ ឲ្យកូនជិតទៅ ទីងទុបបំពេ ៗ អ្នកម៉ែភ្ញាក់ទៅ
មិនចាន់ប្រដៅ ទូន្មានកូនទេ ខ្ញុំឥតអ្នកណា មេត្តាដូចម៉ែ រក្សាកូន
ថែ កូនថប់មួយណា ៗ ថប់ត្បិតអ្នកម៉ែ អ្នកមិនមានគេ កំដរជាគ្នា
ធ្វើម្តេចដឹងផ្លូវ អ្នកទៅឋានណា កូននឹងយាត្រា ទៅតាមអ្នកម៉ែ ៗ
គ្រាន់បានជាគ្នា កំដរទៅក៏ ម្តេចឡើយៈទៅតែ អ្នកម្តាយម្នាក់ឯង
កណ្តោងគេងទេ កូនតែងរំពេ លុះដល់យាមបី ៗ កុមារីរែង ទល់
ទុក្ខម្នាក់ឯង កណ្តាលរាត្រី ហើយលុតលើកករ បវរទាំងទ្វី ដាក់លើ
សិរសី សាសូត្រគាថា ៗ គោរគ្គាទេវ. សង្វាយោច មមវិន្ទា

និគណ្ឋ បមាតុយា ជាទាចក្ខុ នមោគេសំ ៗ ពាលិកាកេះ ម៉ត់
អ្នកថា ប្រែអត្ថ នមោប្រែថា នមស្ការ មេនៃខ្ញុំតាំង ប្រណម្យអញ្ជលី ៗ
ផ្គុំប្រាមទាំង១០ ទុកតាំងគ្រឿងគ្រប់ មាលាផ្កាក្បិ ជាគ្រឿងក្រយា
បូជាពលី- កាកោលអគ្គី- ភាវវន្ទនា ៗ កោះន្តាទេវ សង្ឃាយោច
បពិត្រទេវតា អ្នកឋិតនៅឋាន វិមានបញ្ចា ប្រាំបីទិសា អញ្ជើញ
ចូលមក ៗ មមន្ទេះ និគណ្ឋ ចូរទទួលយក ការវន្ទនា ក្រយា
ខ្ញុំរក អញ្ជើញអ្នកមក ជៀងជួយវក្ខ ៗ សូមអ្នកព្រមាន ប្រាយ
ប្រាប់ទីឋាន លំនៅជនទី អ្នកឋិតឋានណា មេត្តាប្រាប់ទី ផ្សងស្រេច
កុមារី ដែកលនលក់ទៅ ៗ កាលេតទា ក្នុងកាលនោះណា អគ្រាត្រ
យប់ជ្រៅ គេដះសព្វា កុមារិកាផ្សងទៅ ទេវតាឋិតនៅ ប្រាំបីទិសា ៗ
រំជួលកក្រើក ហាក់ដូចគេលើក ឋានទេពធីតា ចាំងហោមពាន្ត ទីឋាន
ព្រឹក្សា សួគ៌សុខកាមា- វចរម៉េនសល់ ៗ នាងទេពធីតា ប្រែព្រះភក្ត្រា
ទៀងទតយង់យល់ កុមារីវ្រង់លក្ខណ៍ ដូងភ័ក្ត្រនិម៌ល នាងមានអំ-
ពល អំពីមាតា ៗ ទេពទិសប្រាំបី ជ្រាបសព្វសេចក្តី ថាទុ
អនិច្ចា កុមារីវរលក្ខណ៍ នាងអ្នកកំព្រា ព្រាត់ប្រាសឃ្លាតឃ្លា មិនមួល
ជនទី ៗ គិតហើយហៀរម៉ោះ ហៀវហាចផ្ទុកផ្ទោះ ចាកឋានទិព្វ
ទី រំពៃសំដៅ លំនៅទេវី ចូលដល់ក្នុងទី ដំណេកកុមារិកា ៗ
រមិលមើលសព្វ ផង្អើមធំថប់ ផ្អិតផ្អែតទុក្ខ អាណិតអនេក ស្ងើរ

វែកចិន្តា លុះលាន់មាត់ថា អាស្ចូរគីម៉្លេះ ។ អាយុ១០ឆ្នាំ ក្មេង ណាស់ម្ដេចកម្ម មកផ្ដល់ផ្ទះ ខុះខុអនិច្ចា កុមារិកានេះ គួរអេញ គិតរិះ ប្រាប់ទីមាតា ។ ហើយទើបទៅ នាំហេតុនោះនិ- យាយពីបិតា នាំម្ដាយនាងទៅ បង់នៅគង្គា ហើយដេរណ្ឌោះគ្នា ពុំស្រាកពុំស្បើយ ។ ឪនាងរាយធាក់ ម្ដាយនាងនោះធ្លាក់ ទឹកស្លាប់ទៅហើយ ពីថ្ងៃម្សិល មិញ សម្លាញ់ម្ដាយអើយ អាងចាប់ជាតិហើយ ជាត្រីដរី ។ ហែល មកចាំនៅ កំពង់ទឹកផ្សរ ដងទឹកប្រក្រតី ទេពតាប្រាប់ហ្នះ ហើយ ហោះវិលខ្ចី ទៅឋានទិព្វទី ពិមានអាត្មា ។ នាងកុមារី ភ្ញាក់ ឡើងអំពី ដំណេកហើយណា ក្រោកចុះដើរត្រង់ កំពង់គង្គា ដល់ នាងម្ទម្ម បុះក្នុងទឹកហើយ ។ ស្រែចស្រែកហៅថា បពិត្រមាតា អម្ចាស់កូនអើយ អញ្ជើញអ្នកមក រកកូនអ្នកអើយ មច្ឆាព្ធហើយ ហែល មកម៉្នម្ម ៗ ដល់ហើយបម្រះ នទៀលខនះ ជិតកុមារិកា នាងយល់សេចក្ដី ជាត្រីមាតា មកដល់នាងអា- ធិដ្ឋានផ្សំផ្សង ។ ថាបើមច្ឆា នេះជា មាតា ប្រាកដពិតហោង ឲ្យចេះភាសា ដូចមនុស្សនោះហោង ឲ្យ ប្រាកដផង កាលគ្រានេះឯង ៗ ផ្សងស្រេចហើយណា គេជ:កុមា- រិកា មានចិត្តទិព្វវែង មច្ឆាដរី ចេះស្ដីជាក់ស្ដែង ប្រាប់កូនថ្លាថ្លែង អំពីអតីតា ។

## បទព្រហ្មគីតិ

មច្ឆាជាជនទី ថ្លែងប្រាប់ពីហេតុខ្លួនថា កូនអើយកាលមាតា បង់សំណាញ់ទីឯផុត ។ ម្ដាយមិនមានទោសទេ ស្រាប់តែគេដៀលជាក់មុខ ហើយវាយម្ដាយឈឺចុក ធ្លាក់ទឹកស្លាប់កាលនោះណា ។ កើតជាត្រីដំរី ឥតចំណីបរិភោគា នាងស្លាប់ហើយសោកា ទៀងខ្ញទៀតតែងខ្វល់ទុក្ខ ។ ជាអ្នកមានគុណក្រៃ នៅសព្វថ្ងៃនេះឲ្យសុខ កូនទឹងនាំកន្ទុក បុងអង្ករជាភោជនា ។ មកជូនអ្នកម្ដាយថ្ងៃ ព្រឹកល្ងាចថ្ងៃឲ្យពីសា អ្នកកុំព្រួយចិន្ដា ត្រង់អាហារចំណីនោះ ។ ថាហើយនាងសោកា យកហត្ថាលូកចម្មចុះ បីពទ្រម្ដាយនោះ កើតទោ-មនស្សក្នុងទុក ។ មច្ឆាជាជនទី ឃើញបុត្រីនាងសោកា នាងលួងនាងលោមថា កូនកំសត់មាសម្ដាយអើយ ។ កុំនាងយំទុក្ខពេក កុំសង្វេគចូរនាងស្បើយ កុំខ្ញុំកុំសោកឡើយ កុំសង្រេងក្រៃឈឺថ្ពាត់ ។ មិនមានអ្នកណាថែ ចូរមាសម៉ែនាងស្ងៀមស្ងាត់ ម្ដាយស្លាប់ចោលកូនបាត់ ពិតពុំទាន់បានខ្លួនាន ។ ហើយទើបត្រីដំរី ប្រាប់បុត្រីតាមនិទាន ពីកាលប្រសព្វបាន ជាកិរិយានៃកុដុម្ពិក ។ កំសត់ពង្រត់គ្នា ចោលបិតាមាតាស្រី ដូចបាននិទានពី មុនមកស្រាប់មិនមានសល់ ។ ហើយប្រាប់ពីកុដុម្ពិក ផ្ទាញជីវិតពបដល់ ចាប់ជាតិកន្ទជោរផល ជាមច្ឆាដំរីនោះ ។ ហើយនាងប្រដៅច្បាប់ ជាតម្រាប់កូនស្រី

ស្មោះ សាស័ព្ទច្បាប់តាំងនោះ មាននៅក្នុងច្បាប់ស្រីស្រាប់ ៗ ឯនាង
កុមារី ស្តាប់ជននីទូន្មានប្រាប់ ហើយនាងស្តាប់តាំតាប់ ចប់សព្ទស្ទុះផត
ហ្មង់សៅ ៗ ស្រេចហើយកុមារី លាជននីទៅលំនៅ ជននីបើក
បុត្រទៅ តាមចិន្តាបុត្រក្សាប្រិយ ៗ

ខ្សែមួយជាដើមទី ថ្លៃងអំពីកុលកេសី ក្ស័យទៅកើតជាត្រី បាន
ជួបជួនបុត្រពុំងា ៗ បន្ទបន្ទាយលើក ល្បងល្បិចល្បើកពោលពណ៌នា
បរិបូណ៌ជួបចូលជា ខ្សែមួយចប់ជាសូរេច ៗ

## បទកាកគតិ

នេះនៅរៀបរាប់ រៀបរៀងសាសព្ទ សាសងកាព្យកិច្ច ពីខ្សែមួយមក
ថៃលកពាក្យពេចន៍ ពាក្យពោលសម្រេច សំម្រួមចរចា ៗ ពិតពីកុមារី
លាកលាជននី ចេញចរយាត្រា តាំងយប់ងងឹត ពុំគិតអាត្មា គិត
តែមាតា ស្រងូតស្រងាត់ ៗ នាងដើរម្នាក់ឯង ដលនេត្រហូរល្ហែង
មិនស្បើយមិនបាត់ មុខគួរអនិច្ចា កុមារីការូបរ័ត្ន ទល់វុត្តប្រាសព្រាត់
កណ្តាលរាត្រី ៗ ដៃមួយជូតក្អែក ហូរខ្លាយពន់ពេក ពោរពេញផត
ប័ ដៃមួយដាលដំ ទ្រូងយំផតបី ទួញទៀតសែនថ្វី នឹកដល់មាតា ៗ
ឱអ្នកមានគុណ ប្រាសចោលកូនគន់ ឲ្យនៅឯកា ឥឡូវកូនខ្ទង់
ទីពឹងអ្នកណា អ្នកអើយកូនផ្កា កូនខ្លោចថ្លើមថ្លាយ ៗ ធ្វើម្តេចកូន
បាន យង់យល់រូបប្រាណ ស្លាប់ស័ព្ទអ្នកម្តាយ អ្នកនៅក្នុងទីក ពន្ទឹក

ជ្រៅឆ្ងាយ ស្វាគសពអ្នកម្ដាយ នៅជាប់ទីណា ៗ ឬមួយក្រែងសត្វ
ក្រពើឆ្មាមកាត់ ពាំយកកោក្ដា ហេតុនោះទើបបាត់ សូន្យស្ងាត់សោះ
សោ ឬក្រែងមច្ឆា ចឹកពាំយកទៅ ។ បើសត្វកោក្ដា សាច់ស្បែកកា-
យា គួរឃើញឆ្អឹងនៅ ឆ្អឹងតើអ្នកបាត់ សូន្យស្ងាត់បាត់ទៅ លិចក្នុង
ទឹកជ្រៅ អន្ទង់ត្រង់ណា ៗ ធ្វើម្ដេចកូនបាន យល់ឆ្អឹងរូបប្រាណ
សាកសពមាតា បើពុំឃើញគ្រប់ ឃើញសពកាយា តោះឆ្អឹងសិរសា
បាតាអ្នកថ្លៃ ៗ កូននឹងលើកសព សង្ការឲ្យគ្រប់ ឲ្យអស់សង្ស័យ
តមះជាយកសក់ ទុកគិតក្រៃក្រៃ ស្រេចហើយកូនក្ស័យ ទៅតាមអ្នក
ណា ៗ ឪអ្នកម្ចាស់ថ្លៃ អ្នកមកក្សណក្ស័យ ពុំយល់កំព្រា បើអ្នក
ក្សណក្ស័យ ប្រល័យម្ដេចម្ដា គួរមានពាក្យា ផ្ដែផ្ដាំកូនផង ៗ ឲ្យកូន
បានដឹង ដំណើរដំណឹង ពាក្យពោលសាសង បើអ្នកបិតា ក្រោធ
កន្ទង់ កូនយកខ្លួនផង តោសគាំងមាតា ៗ បើអ្នកឪពុក ឃោរខឹង
ញញឹក វាយដំក្ដីណា គួរវាយទៅផុះ បោកប្រាស់ម្ដេចម្ដា កូននឹងជួយ
ការ ជួយការពារអ្នកម្ដាយ ៗ នេះម្ដងនាំម៉ែ នាំមកបង់ឯ ទន្លេជ្រៅឆ្ងាយ
ឃោរខឹងជាក់ច្រំ វាយដំអ្នកម្ដាយ ឲ្យក្ស័យអន្តរាយ កេសពពុំយល់ ៗ
កុមារគិតគ្រប់ គិតរែងថែមថប់ រីងថែមទុក្ខទល់ ទុក្ខទៀនសែនពាន់
ផ្អែតផ្អូទអំពល់ អំពីពុំយល់ សាកសពមាតា ៗ នាំងខ្ញុំច្រាំងយំ ដួល
ដេកសោកសព្វ ផ្អែតផ្អូទទុក សន្ធប់លុះខ្លង់ នៅក្នុងព្រៃក្សា តែឯងឯកា

ឥតអ្នកពារផង ៗ លុះភ្ញាក់ស្មារតី ព្រួសត្វបក្សី យាក់យំអឺងកង ទំទុយ
មៀមមំ សត្វយំកន្ទង ខ្វែងស្រាកស្រែកផង ព្រាព្រើតសិរសា ៗ ត្កូក
ស្រែកសន្ធាប់ ខ្វះខ្វាយព្រួសត្វ ឪឡ្ធាបា នាងគិតតាន់កាំង ស្ទាំងទាំង
កាមា សូន្យស្មុគបាត ដួលដើរពុំបាន ៗ ផ្កាដោយនៅក្មេង ឮសូរ
សំឡេង ក្នុងព្រៃស្មសាន សុទ្ធសឹងសត្វខ្លាច លន្លោចតិរច្ឆាន ញ័រ
អស់អង្គប្រាណ មុខគួរអនិច្ចា ៗ ដើរយប់តែឯង - កណ្ដោចកណ្ដែង
កណ្ដាលព្រឹក្សា វង្វេងវិលវល់ ទួញទល់ទុក្ខា ដៃដំទ្រូង ទ្រូងស្ទើរធ្លាយ ៗ
តាំងពីអធ្រាត្រ ទុក្ខទួញសល់ខ្នាត ស្មារតីរាយមាយ ប្រទះហ្វូងសត្វ
ប្រវាត់លោតលាយ ទន្សោងប្រើសទ្រាយ ចចកប្រមា ៗ រមាសរមាំង
ប្រើសព្រៃខ្ទីងខ្ទាំង ដំរីខ្លាំងខ្លា កំហែងសន្ធាប់ ញ័រញាប់ព្រឹក្សា ភិត
ភ័យប្រវា ជ្រកពួនលាក់ប្រាណ ៗ ហេតុផលសំណាង កុមារីសាង
សត្វធម៌ពុំហ៊ាន ប្រមាថអង្គនាង ជៀសវាងឆ្ងាយឋាន នាងក្រោក
ដើរបាន តិច ៗ យាត្រា ៗ

## បទពំនោល

លុះស្រាងព្រឹកព្រាងសុរិយា កុមារីយាត្រា វិលដល់មណ្ឌល
ឋានបិត ៗ កាលីមើលយល់ស្រីរ័ត្ន ដើរដល់គន់គិត ក្នុងចិត្តមន្ទិល
ថៃថា ៗ ហេតុអ្វីថ្ងៃនេះកុមារិកា ចុះទៅគង្គា ពីព្រឹកលុះស្មាងសុរិយ ៗ
គិតហើយនិយាយប្រាប់ប្ដី ថាអ្នកកុំបី បណ្ដែតបណ្ដោយកុមារិកា ៗ

កុំឲ្យតែម្នាក់ឯកា គួរហៅយកក៏ មកនិត្យមកនៅឯកាយ ។ មិនត្រូវឲ្យនៅ
ផ្ទះឆ្ងាយ ក្រែងអន្តរាយ អសារអេសោចកើតឈ្មោះ ។ យប់មិនដែលនៅផ្ទះ
សោះ ពុំចុះដើរស្មោះ ដើរដល់ទៅឯកំពង់ ។ ពីយប់ងងឹតសូន្យស្ញុង
សូន្យសោះយូរលង់ យូរលុះព្រឹកព្រាងទើបមក ។ កុដុម្ពិកស្តាប់ហើយ
ហៅគេ ហៅគេកូនមក កូនមិញមកជាទបិតា ។ កុដុម្ពិកដណ្តឹង
សួរថា កូនកែវទៅណា ទៅនៅពីយប់លុះព្រឹក ។ កុមារឆ្លើយថាខ្ញុំនឹក
ខ្ញុំគិតរលឹក រលេះរលួយក្នុងចិត្ត ។ ដ្បិតខ្លួនឥតពួនពីងពិត អនាថ
អាណិត អាណាឯកាម្នាក់ឯង ។ លង់ធ្លង់លន្លោចកណ្តែង កណ្តាល-
ឯកឯង ឯកឥតពំនាក់អាត្មា ។ ខ្ញុំរលឹកអ្នកមាតា ស្រមៃហាក់ជា
ហាក់ដូចសម្តែងជនទី ។ ហៅជាក់ខ្ញុំភ្ញាក់ចាកទី ចុះទៅអំពី មណ្ឌល-
មន្ទិលក្នុងចិត្ត ។ ដើររកសពប្រេកហានបិត ថៃជួនអស់ចិត្ត អស្ចារ្យពុំ-
ឃើញមាតា ។ ហេតុនោះខ្ញុំចុះគង្គា លុយរកមាតា សុំសព្វពុំឃើញ
នេះនៅ ។ បិតាថាពីនេះទៅ បើព្រមាតហៅ កុំទៅកុំទុកចិត្តណា ។
កុំចុះដើរយប់លីលា ក្រែងជួនម្រឹគា ពស់ខ្លាទូរសត្វឃោរឃៅ ។
ម្តាយនាងភ្ញាក់ទឹកស្តាប់ទៅ ពីម្សិលមិញកូវ នាទឹកកំពង់គង្គា ។ កុំនឹក
រលឹកទៅព ចូរមកនៅនា នៅនឹងបិតានេះចុះ ។ ចំណីបាយត្រីនៅនោះ
យកស៊ីចុកចុះ ជួយមើលជួយថែរក្សា ។ បម្រុងទ្រព្យក្នុងគ្រឹហា ទោះ
ទ្រព្យខ្លួនជា កុំបោះកុំបោកបែកបាត់ ។ នាងស្រួលទទួលស្មៀមស្ងាត់

វិលទៅផ្ទះថ្វាត់ ជញ្ជូនកន្ទេលខ្នល់ខ្នើយ ៗ ឃើញតែដំណេកជាគ្រើយ
កើតទុក្ខពុំស្បើយ គិតទឹករលឹកមាតា ៗ ហូរហៀរស្រក់ទឹកនេត្រា
សស្រោកក័ក្រា ក៏យកដៃជូតក័ក្រមិញ ៗ ដាក់ក័ក្រធ្វើហាក់·
សៀមវិញ ក្នុងចិត្តក្តៅមិញ រំដែងរំជួលទុក្ខទល់ ៗ ដៃមួយទបពូក·
ខ្នើយខ្នល់ ដៃមួយជូតជល ក៏ដើរហើយយំថណ្តើរ ៗ លុះដល់ពូក
ខ្នល់ដាក់លើ ផ្ទះហើយនាងរើ នាងរៀបដំណេកទុកនៅ ៗ កាលើ
ជាស្រីយោរយៅ យោរឃើញនាងនៅ ក៏ហៅហើយប្រាប់ប្រាមប្រើ ៗ
ដងទឹកបុកស្រូវសាវតើ ដណ្តាំស្ទះធ្វើ ចំណីចំណុកគោក្តា ៗ មិនល្ហែ
ទំនេរត្រង់ណា ខានតែវេលា យប់ខានសំរាកឈប់ខ្ទះ ៗ ម្ល៉ោះខំធាក់
ច្រំបោកប្រាស់ រាដេរមិនខ្ទះ មិនខាតមិនខានមួយថ្ងៃ ៗ មិនអត់មិនទន
ឈប់ដៃ ហើយប្រើទៅព្រៃ ឃ្វាលគោរកទុសបន្ទៃ ៗ នាងស្តាប់កាលើ
ប្រើប្រែ នឿយហត់ឥតល្ហែ រកបែរបើកទ្វារក្រោលចេញ ៗ បើគោ
បោលមកនាងដេញ ប្រមូលវិលវិញ ដើរចេញដើរដោយព្រៃនោះ ៗ
ហើយចូលក្នុងព្រៃរកទុស ចង់បាច់ស្រេចចុះ ហើយគៀងប្រមូលគោ
បាន ៗ ហើយដើរសព្វព្រឹកព្យាសាន្ត រកម្ចប់បាំងប្រាណ នេត្រគយ
ក្រែងឃ្លាតទៅឆ្ងាយ គៀងចូលប្រមូលហ្វូងហ្វាយ មិនឲ្យព្រាត់ព្រាយ
ព្រាត់ប្រាស់ចរចាកចោលគ្នា ៗ សៀលទេវតាបសុរិយា ជ្រៀងជ្រ
ដីកា គៀងគយប្រមូលគូនាម ៗ រំពឹងជញ្ជឹងជូនថៃ ជាទុក្ខគោមេ គូទ

អាកំមូលមៅ ៗ កម្មអញឲ្យម្នាញខ្មោចផ្សំ ព្រាត់ប្រាសមាតា មិនមិត្ត
មិនមូលដូចសត្វ ៗ គិតហើយមិនស្បើយស្រីរត្ន ខ្សឹកខ្សួលក្តួលក្តាត់
អាណិតអនាថអាត្មា ៗ រឹងថប់រឹងថែមទុក្ខា ទុក្ខទល់កាយា នឹកនារ
ក្រៀមក្រំ ៗ ហត្ថានឹកដាលដំ ដើរដោយទុក្ខម ទុក្ខតែអង្គឯងឯក ៗ
ដើរព្រៃដៃផូតទឹកភ្នែក អាណិតនាងពេក នាងពុំសប្បាយហឫទ័យ ៗ ទៀត
ទន់ពេលពន់ល្ងាចថ្ងៃ ក្បៀននឹងក្រោសព្រៃ ក្រាស់ក្រនឹងស្បើយស្រាក
ស្រាន្ត ៗ រង់ហត្ថានឹងបម្រាណ ក្រណាត់មួយគ្មាន សំពត់បង្កើះជាក់
ជាំ ៗ ឥតឯមានគេថែទាំ រូបរស់រងកម្ម កណ្តាលកណ្តាបទុក្ខម ៗ
ក្បៀនស្បើយផ្គរធ្វើយធំ រង់អួលក្រំ នាងយំអាណិតអាត្មា ៗ ស្រណោះ
អាឡោះមាតា សួគស្ងប់ក័ក្ត្រា នឹកដាលដំនឹងម្តាយ ៗ ស្បើរប្រែះបេះ
ថ្មើមធ្លាយ អនិច្ចាធោមធាយ ទុក្ខជូទក្ខងកាយលទន់លន់ ៗ ស្បើរផុតស្រ
យុតស្រយន់ ស្រយាកអស់អង្គ ឯកឥតនរណាជាទី ៗ ខំផ្លូងតម្រង់
ឥន្ទ្រិយ ក្រោកឡើងបាកទី រឹងរែងទារទុក្ខពុំក្សាន្ត ៗ ក្រោកដើរតឹ
ឈឺអង្គប្រាណ ប្រឹងប្រាណដើរបាន ដោយស្រាកដោយស្រាន្តទ័យា ៗ
កៀងគោម្រមូលគ្នាក់ ហើយចូលព្រឹក្សា រកបេះបន្ទអន្ទក់ ៗ ផ្កាល្បៀង
គ្រងធៀងគ្រថុក ច្រូយរាំងអន្ទក់ ស្ងួនដើងបង្កងគ្រក្អួន ៗ ចងបាច់ស្រាប់
ស្រេចស្រីសួន នាងរៀបលើកផ្ទួន លើកផ្ទុកលើបាច់នឹងសវិញ ៗ ហើយ
នាងប្រមូលគោដេញ គោដើរវិលវិញ វិលរឹងមកដប់ទ្វារក្រោល ៗ ដាក់

ខ្សែបើកទ្វាបញ្ចូល ពប់កូនញីឈ្មោល ហើយនាងរាំងទ្វារបោះស្នៀត ៗ ចូលចាប់អាឈ្មោលចង់ទៀត ហើយវិលមកសៀត គន្ទឹះរនុករាំងទ្វារ ៗ ទើបទូលខ្សែទៅគ្រឹហា ដាក់ខ្សែសម្មីមា សំពះឪពុកលើផ្ទះ ៗ ឪពុកថា គ្រប់ប្តូខ្វះ បានពប់មើលច្បាស់ នាងឆ្លើយថាពប់គ្រប់ហើយ ៗ មិនបង់មិនបាត់មួយឡើយ ចាក់សោទ្វារហើយ ទើបខ្ញុំវិលមកគ្រឹហា ៗ

ហើយនាងឡើងពនគង្គា កាន់កម្មមីមា កណ្តៀតហើយទូលចុះទៅ ៗ យកចុងអង្ក្រប្រែកនៅ ក្នុងកម្មទូលទៅ តម្រង់កំពង់គង្គា ៗ ដល់ហើយនាងហៅមាតា មច្ចាមីមា ហែលមកដល់កូនពុំលង់ ៗ នាងយកកន្ទក់នៅចុង- អង្ក្រលើកជូន កំពេយឲ្យទៅមាតា ៗ ហើយនាងជង់ទឹកមីមា ដើរដល់គ្រឹហា ឡើងយកផ្កាំងបាយលាងដាំ ៗ ឯកូនកាលីប្រចាំ មិនជួយដណ្តាំ អង្គុយបង្គាប់កុមារ ៗ ដូចខ្ញុំកញ្ចះបាទា រាដេរផ្កាសា ប្រទូស្តប្រទេចទះតប់ ៗ ខ្ញាមខ្ញារដោយសារពស្អប់ ប្រានជួលដាល់តប់ ឥតពាស់ឥតពេសទីគ្នា ៗ នាងអត់មិនឈ្លោះនឹងរា ត្បិតខ្លួនកំព្រា ឈើផ្សាឈើទាប់ជាំផាក់ ៗ ដលនេត្រហូរល្ហែងសស្រាក់ សស្រោកឥតអាក់ ដោតជាំដោយសត្វដើងគ្រាន ៗ ខំអត់ក្រោកឡើងលាងចាន បាយជ្អិនស្ងបាន នាងដោះនាងជួសយកទៅ ៗ លើកជូនឪពុកប្រើហៅ ប្រពន្ធកូនទៅ មកជុំមកជួបហូបបាយ ៗ នាងថយអង្គុយទៅឆ្ងាយ រៀបទ្រព្យតាំងឡាយ សិតទឹកលាងដើងឪពុក ៗ គេមកដល់ហើយស៊ីចុក

មិនមានមើលមុខ មើលមកនាងអង្គុយខាង ៗ ស៊ីប្រញាប់ថាសចានផាន

នាងយកទៅលាង ហើយផ្កាប់ទុកដាក់មើលថៃ ៗ ចំណីសេសសល់

ដែលគេ នាងបរិភោគតែ សេសសល់សំណល់សព្វថ្ងៃ ៗ ស៊ីឆ្អែត

ហើយនាងស្រីថ្ងៃ កាន់ក្អមចុះរៃ ទៅដល់កំពង់គង្គា ៗ ចុះដងទឹក

ឡើងម្នីម្នា ដាក់ដល់សិរសា ក្អមពេញទ្រូតចូលមក ៗ ចាក់ពាងអុង

អាងក្រឡ ក្រឡប់ទៅរក ដងដាក់ល្អះពេញពាងគ្រប់ ៗ ថ្ងៃមួយហត់

ព្រួយគ្មានឈប់ ពីថ្ងៃលុះយប់ មិនឈប់មិនឈរសម្រាន្ត ៗ ព្រលប់

នាងអុជខ្លាញ់ចាន ភ្លើងភ្លឺសព្វឋាន ហើយរៀបរបស់ទុកដាក់ ៗ រួច

ហើយកំនត់ទ្វារសោចាក់ គន្លឹះគន្លាក់ ចូលបោសដំណេកបិតា ៗ សិត

ទឹកដាក់ជិតបាទា រៀបហិបដាក់ស្លា លើកដាក់ជិតក្បាលដំណេក ៗ

វេលាបិតាចូលដេក ចូលដល់ដំណេក នាងគក់ច្របាច់បាទា ៗ ឪពុក

ដេកលក់និទ្រា ហើយនាងលីលា ដើរថ្នមមកដំណេកនាង ៗ ចូល

ដល់ជាវេលាយំភ្ញាង ដេកលក់ភ្លឺស្រាង ចុះទៅបុកស្រូវអង្ករ ៗ ស្ទូយក

កន្ទក់សល្អ នូវចុងអង្ករ នាងយកទៅជូនជនទី ៗ ញឹកៗ ល្ងាចព្រឹក

ទៅ ទឹកដល់ជនទី ស្រពោនក្រៀមមិនស្រស់ ៗ មិនលេងមិនសើច

សូន្យសោះ មុខស្ងួនក្រៀមក្រស់ ការឡោះអាល័យមាតា ៗ ចំណីកា

លើនោះណា នាងពុំភោគា នាងចាំបណ្ដាំជនទី ៗ ចំណីរបស់នាងស៊ី

បើគ្មានទៅ នាងអត់នាងអន់ស្ងៀមស្ងាត់ ៗ តែងយកកន្ទក់ទៅផ្លាត់

ទៅជូនប្រណិប័តន៍ ដងទឹកល់ ។ វេលា ។ ធ្វើវត្តប្រណិប័តន៍បិតា ប្រចាប់ចាថា មិនខានមិនឲ្យអាក់ចិត្ត ។ បិតាអាសូរអាណិត ព្រោះនាងមានចិត្ត ស្លូតត្រង់គោរពខ្លាចបិតា ។ ទើបតាំងឲ្យនាមឈ្មោះថា មរណមាតា តាំងតែពីថ្ងៃនេះទៅ ។ កាលជាស្រីយោវយៅ ឃើញនាងស្រីពៅ ឪពុកអាសូរស្រឡាញ់ ។ ខេរខឹងសំឡឹងគ្នាន់ក្លាញ់ រំងៅក្តៅចិត្តម្ចេញ រកទោសកំហុសសព្វថ្ងៃ ។ ព្រឹកឡើងនាងចេញទៅព្រៃ ឃ្វាលគោសព្វថ្ងៃ មានក្មេងចូលលេងជាគ្នា ។ ក្មេងទុរជន់ជាករ៉ា ខ្លះបេះស្លឹកចា ដេរដួងគ្រប់ខ្លួនបិទបាំង ។ ខ្លះបានសំបកទំពាំង មកគ្របមកបាំង មកពាំងរងក្មេងការខ្លួន ។ មរណមាតាស្រីសួន រងាទុបខ្លួន សំពត់តែមួយដោកដាំ ។ មិនហ៊ានអង្គុយដេរឃ្លាំ ដើរមើលថែទាំ គៀងគោទាំងក្មេងក្រែងបាត់ ។ លុះល្ងាចគៀងគោវិលថ្កាត់ អាសូរស្រីរ័ត្ន រងាញ័រអស់អង្គា ។ ព្រឺព្រួចសម្បុរកោមា ខំជួបបាថា ដោយដឹងបង់លំក្រែងដួល ។ រលឹមទូទឹមដង្គាល មេឃមីរខ្មៅខ្លួល ស្រឡប់ស្រឡោចព្យោមា ។ មាត់សត្វស្រងាត់អង្គា លលកទំទា ហ៊ោលគោកក្អាកក្រយង ។ ហូពូបាតូយ៉កងធ្វើយគ្នាសាសង សាសព្វប្រពាត់ហើរទំ ។ ខ្លះហើរទៅរកទ្រូទំ ខ្លះទំយាសយំ ចាប់ចឹកផលាគោគ្គា ។ ត្រីងព្រួសជន្ទូសទ្រៀលស្វា ទ្រមូងពុទ្រាទ្រមួចទ្រមែងភ្នងភ្នូ ។ សត្វយំរងំរគគូ អាអ្នកតុកទ្រូ ពញាក់ទ្រមាក់ខ្លាខ្លួង ។

(មានត)

# រឿងសាមកុក

## ភាគទី ៣៧

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ<br>អ្នកភាងវៃឆ្លាស បើបានអាន<br>នឹងចេះឧបាយកលបំណាន<br>ទាំងមានសន្តានស្នេហាជាតិ ។ |

ឲ្យស៊ុនក្វនពាក់កណ្ដាល ហើយនឹងស្បថស្បែគ្នាជាបងប្អូន មិនបានគិតប្រទូសរ៉ាយគ្នានឹងគ្នាតទៅ បើស៊ុនក្វនឃើញសំបុត្រ ក៏នឹងមានសេចក្ដីកោតញញើតបុណ្យនឹងប្រាជ្ញា មហាឧបរាជខ្ញុំជាក់នឹងមកកាន់លោក ។ ចូទុយល់ឃើញត្រូវ ទើបតែងសំបុត្រប្រើឲ្យមនុស្សកាន់ទៅស្រុកកាំងតាំង ហើយទើបឲ្យប្រុងប្រៀបរៀបចំបំរុងទាហានទ័ពគោកទ័ពទឹក ទុកស្រេច ហើយថែមឲ្យដំណឹងប្រាកដក្នុងទ្រូងទៅថា ទាហានមហាឧបរាជលើកមកគ្រានេះពល ១០០ ម៉ឺន ទ័ពទូកចម្បាំងដែលចតនៅជាយទន្លេនោះ បើដូចជានឹងពេញទៅទាំងផ្ទៃមហាសមុទ្រ ខាងទ័ពគោកនោះ ក៏ឲ្យធ្វើបន្ទាយល្បាតគ្នាចេញទៅតាមបណ្ដោយផ្លូវដល់ ៣.០០០ ស៊ិន (១២០គ.ម.) ។

ឯស៊ុនគួន លុះដឹងថាចូចូលើកទ័ពហ្វឹនកទ្វឹនមកដល់ស្រុកស៊ីនយ៉ុង ឡៅចង់ចេញទៅគំនាប់លើកស្រុកស៊ីនយ៉ុងឲ្យចូចូហើយ ឥឡូវនឹងលើកទៅច្បាំងយកស្រុកកាំងឡេងទៀត ស៊ុនគួនគិតខ្លាចចូចូនឹងមកដល់ស្រុក ទើបប្រឹក្សានឹងពួកខ្ញុំរាជការទាំងពួងថា ចូចូលើកទ័ពមកនឹងវាយយកស្រុកកាំងឡេងមុខជាមិនឈប់តែប៉ុណ្ណោះទេ នឹងចូលរំលងមកដល់ស្រុកយើង ៗ នឹងគិតការប្រការម្ដេច ? ។ ឡោស៊ុកឆ្លើយថា ដែលនឹងការពារមិនឲ្យសឹកសត្រូវចូលមកដល់ស្រុកនោះ ខ្ញុំបាទឃើញថាស្រុកកេងជីវនេះជាស្រុកធំ ពួកអ្នកស្រុកក៏ស្រុះស្រួលព្រមគ្រប់គ្នាបរិបូណ៌ បើយើងនឹងលើកទ័ពទៅវាយយកស្រុកកេងជីវ បានតាំងនៅឲ្យខ្ជាប់ខ្ជួនមាំមួនហើយ នឹងបារម្ភអ្វីនឹងកងទ័ពចូចូប៉ុណ្ណោះ ទោះលើសជាងនេះក៏នឹងការពារទុកមិនឲ្យសឹកសត្រូវចូលដល់ស្រុកបាន មួយទៀត បើបានស្រុកកេងជីវហើយ ឃើញថានឹងតាំងខ្លួនជាធំបាន ឥឡូវឡៅប៉ៀវក៏ស្លាប់ទៅហើយ ឡៅពីសោកក៏បែកខ្ញែកតាំងខ្លួនមិនទាន់បាន បែកទៅនៅនឹងឡៅពីឯស្រុកកាំងហែ ខ្ញុំបាទនឹងសុំយកអាសាធ្វើឧបាយតែងគ្រឿងសែន ធ្វើជាគំនាប់សពឡៅប៉ៀវ ហើយនឹងនិយាយល្បួងលួងលោមពួកអ្នកស្រុកនឹងទាហានកងស្រុកកេងជីវ ហើយនឹងឡៅពីឲ្យចុះចិត្តព្រមគ្នា ហើយក៏ឃើញថា នឹងធ្វើការកំចាត់ចូចូចេញបានដោយងាយ ៗ ស៊ុនគួនឃើញត្រូវដូចចិត្ត ក៏ចាត់ចែងរបស់ទ្រព្យប្រគល់ឲ្យឡោស៊ុកទៅស្រុកកាំងហែ ។

ឯទៀតពីកំប្រឹក្សានឹងខុនបេងថា ចូចូលើកទ័ពមកគ្រានេះធំពន្លឹកណាស់ ខ្លាចក្រែងនឹងលើកតាមមកទៀត យើងនឹងរិះគិតប្រការម្ដេច ៗ។ ខុនបេងឆ្លើយថា ដែលនឹងនៅក្នុងស្រុកកាំងហានេះ ឃើញថាទ័ពឆ្អៀតចង្អល់ណាស់ បើចូចូលើកមកក៏នឹងការពារពុំបានមាំមួន ឃើញថានឹងចួសការទៀត សូមឲ្យលោកលើកទៅនៅស្រុកកាំងតាំងអាស្រ័យទីពឹងស៊ិនគួនសិនចុះ បើសិនណាជាចូចូដឹងថាលោកទៅនៅនឹងស៊ិនគួនហើយក៏គង់នឹងលើកតាមទៅ ខូចថាចូចូនឹងស៊ិនគួន ក៏គង់នឹងខុសចិត្តគ្នាឡើង យើងក៏នឹងនៅជាកណ្ដាល បើនរណាភ្លាត់ចំណាប់ សឹមយើងប្រញាប់ព្រួតដៃបន្ថែមយកឲ្យបានចុងដៃ ឃើញថាបានជ័យជំនះដោយងាយ ។ ទៀតពីឆ្លើយថា ដែលលោកគិតនេះត្រូវណាស់ តែស៊ិនគួននោះមានមនុស្សប្រកបទៅដោយដម្រេះប្រាជ្ញា ជួយតាំពារទំនុកបំរុងច្រើនណាស់ ខ្លាចក្រែងមិនព្រមឲ្យយើងនៅក៏នឹងអព្យាយសន្ទាសគេ ។ ខុនបេងសើចហើយះឆ្លើយថា ចូចូលើកទ័ពមកគ្រានេះសន្ទឹកសន្ទាប់ខ្លាំងណាស់ ដូចជានឹងក្រឡាប់ស្រុកផែនដី មុខជាស៊ិនគួននឹងតក់ស្លុតភ័យខ្លាច នឹងប្រើមនុស្សសុំបការមកខាងយើង បើសិនជាឃើញនរណាមកដល់លោកហើយ ខ្ញុំនឹងសុំអាស្រ័យយកតែទូកតូច ១ ទៅជាមួយនឹងអណ្ដាត ៣ ជាប់ទៅធ្វើឲ្យស៊ិនគួនខុសចិត្តគ្នានឹងចូចូឲ្យបាន បើចូចូចាញ់ក៏នឹងចូលជួយខាងស៊ិនគួន បើឃើញថាបានចំណាប់ហើយ យើងក៏នឹងចូលដណ្ដើម

យកស្រុកគេងជីវជាកំរៃទេ បើសិនណា ស៊ិនគួនត្រឡប់ជាចាញ់គេ យើងក៏នឹងគិតកៃកៃខំដណ្ដើមយកស្រុកកាំងតាំងទុកវិញ ។

ឡៅពីឆ្លើយថាឯគំនិតដែលលោកវិះគិតដូច្នេះ ក៏ឃើញថាត្រូវតែថាបើនរណានឹងមកគេ យើងនោះ ក៏នៅមិនទាន់ឃើញឡើយ កាលឡៅពីកំពុងនិយាយគ្នានឹងខុនបេងមិនទាន់ផុតមាត់ ។ ពាហានរត់ចូលមកប្រាប់ថា ឥឡូវស៊ិនគួនប្រើឡោសុកយកគ្រឿងសែនមកពីស្រុកកាំងតាំង នឹងមកគំនាប់សពឡៅប៉ៀវ ។ ខុនបេងឮហើយក៏ទះដៃអស់សំណើចហើយសួរឡៅគីថា កាលគ្រាស៊ិនកៀនបិតាស៊ិនគួនស្លាប់នោះ អ្នកធ្លាប់បាននាំរបស់ទៅគំនាប់សពដែរឬ ? ។ ឡៅគីឆ្លើយថា ឯស្រុកកាំងតាំងនឹងស្រុកគេងជីវជាហាវនឹងគ្នា ព្រោះបិតាខ្ញុំបាទសម្លាប់បិតាគេនឹងត្រឡប់ទៅគំនាប់សពដូចម្ដេចបាន ។ ខុនបេងឆ្លើយថា បើដូច្នោះដែលឡោសុកមកគ្រានេះ ឃើញថា មិនមែនមកគំនាប់សពដោយសុចរិតទេ ប្រហែលជាមកស៊ើបយកការស្រុកទេសជាប្រាកដ ទើបខុនបេងនិយាយនឹងឡៅពីថា បើឡោសុកមកជួបនឹងលោកនឹងនិយាយការអ្វីដល់ចូចប្រការម្ដេច លោកចូរនិយាយបដិសេធថាមិនដឹងអ្វីសោះ ទោះបើនឹងជជីកសួរតទៅ ត្រូវឆ្លើយដម្រូវថាឲ្យទៅសួរខុនបេងវិញចុះ ។ ឡៅពី, ឡៅគីក៏ឲ្យបំរើទៅទទួលឡោសុកនាំចូលមក ហើយក៏រៀបតុលៀងអាហារឲ្យឡោសុកបរិភោគតាមប្រវេណី ។

កាលឡោសុកកំពុងចិញ្ចឹមគោ ក៏សួរឡៅពីថា ខ្ញុំបានឮដំណឹងថា លោកមានដម្រិះប្រាជ្ញា ទាំងចិត្តក៏ល្អត្រឹមត្រូវណាស់ ជាទីសរសើរដល់មនុស្សទាំងពួង ខ្ញុំនេះជាមនុស្សប្រុសតូច មិនបានជួបប្រទះឃើញលោកឡើយ ទើបមកជួបឃើញមុខក្នុងថ្ងៃនេះ ហើយក៏បានជាបុណ្យក្តីរបស់ខ្ញុំខ្លាំងណាស់ សូមខ្ញុំបាទបានឮដំណឹងមកទៀតថា លោកទីងច្បូងច្បាំងគ្នាជាពន្លឹក តើជាពិតមែនឬ ? ។ ចួច្បនោះទីងមានសេនាពាហនតិចច្រើនប៉ុន្មាន លោកជ្រាបទ្រាកជបានឬទេ ? ។

---

## សាមកុកខ្សែ ៣៨

តាំងពីឡៅសុកទៅសួរឡៅពី ខុងបេងឱ្យដំណឹងកងទ័ពច្បូច តាំខុងរះប៉ិងទៅស្រុកកាំងកាំង ពាក់ពាក្យព្រាននឹងពួកនាម៉ឺនស្រុកកាំងកាំង នឹងស៊ុនគ្វន លុះស៊ុនគ្វនប្រាប់សេចក្តីផង់ម្តាយចុង ។

---

ឡៅពីឆ្លើយថា ឯមនុស្សទាំងពួងកោតសរសើរថា ខ្ញុំមានចិត្តល្អត្រឹមត្រូវនោះក៏មែនហើយ តែថាខ្ញុំមានគំនិតរិះគិតនោះមិនជាប្រមាណទេ ទាំងពេលវេលាតិចណាស់ ដែលត្រេះត្រិះស្ទើរនឹងចួច្បក៏មិនបាន បើសិនណាដឹងថាចួច្បលើកទ័ពមកហើយ ខ្ញុំក៏ត្រូវតែរះគេចរត់យកតែខ្លួនឱ្យរួចទៅ មិនហ៊ានទៅជិតទេ ហើយកម្រដែលទី ដឹងឃើញថា ពាហនចួច្បច្រើនឬតិចប៉ុន្មាន ដែលអ្នកមកសួរដូច្នេះខ្ញុំក៏ពាល់ប្រាប់ណាស់ មិនដឹងឆ្លើយ

ថាម្ដេចទេ ។ ឡោស៊ុកថា ខ្ញុំបានឮដំណឹងថា លោកបានច្បាំងនឹង ចចក ខុនបេងបានប្រើកលឧបាយបញ្ឆោតដុតកងទ័ពចចកខាតដល់ ២ ដង ឯចចកតក់ស្លុតភ័យខ្លាច ហេតុម្ដេចក៏លោកថាមិនដឹង ។ ឡៅពីថា បើអ្នកចង់ដឹងឲ្យជាក់ច្បាស់ ត្រូវទៅសួរខុនបេងចុះ ដែលនឹងសួរយើងនេះក៏ដូចជាសួរទទេ ។ ឡោស៊ុកថា ឥឡូវខុនបេងនៅឯណា ? សូមឲ្យខ្ញុំបានឃើញមុខនឹងសន្ទនាគ្នាបន្តិចផង ។

ឡៅពីក៏អញ្ជើញខុនបេងឲ្យចេញមកជួបនឹងឡោស៊ុក ពាំងសងខាងក៏គំនាប់គ្នាទៅវិញទៅមក ។ ឡោស៊ុកសួរខុនបេងថា ខ្ញុំបានឮពាក្យគេសរសើរដម្រេះប្រាជ្ញាលោកក្រើកអំពើកខ្លាំងណាស់ ដែលខ្ញុំបានមកជួបនឹងលោកថ្ងៃនេះ ជាវាសនានឹងរកទីបំផុតមិនបាន ខ្ញុំនឹងសុំសួរលោកបន្តិច ដែលលោកបានធ្វើការសង្គ្រាមតនឹងចចកគ្រានេះ លោករិះគិតប្រើកលឧបាយដូចម្ដេច ? ។ ខុនបេងឆ្លើយថា ឯចចកនោះប្រកបទៅដោយដម្រេះប្រាជ្ញាទំនិតគិតឃើញច្រើន ខ្លួនខ្ញុំមិនអាចនឹងធ្វើការតទល់នឹងចចកបានទេ ព្រោះកំឡាំងពាហានក៏តិច ឧស្សាហ៍វះគេបរតែមកយកតែខ្លួនឲ្យរួច ។ ឡោស៊ុកថា បើខ្លួនលោកនឹងឡៅពីតស៊ូនឹងចចកមិនបាន នាំគ្នាវះវត់មក នឹងឈប់នៅប៉ុណ្ណេះឬ ។ ឬនឹងរិះគិតនឹកទៅទៀត ? ។

ខុនបេងថា អាវស៊ីវបៅហ្វាយស្រុកសាំងនាំវ ជាមនុស្សពូកគាត់

គ្នាទីងទៀតពីចៅហ្វាយខ្ញុំ ឥឡូវទៀតពី គឺគិតចង់ប្រែប្រួលទៅសុំពំនាក់ អាស្រ័យនៅផង ៗ ឡោសុកថា ឯស្រុកសាំងម៉ាវនោះមនុស្សម្នាទីង ស្បៀងអាហារគឺគិច តែខ្ញុំនអាវស៊ុវនៅរក្សាឲ្យសុខមិនបាន កាលណាទីង អាចហ៊ានការពាររក្សាអ្នកដទៃបានទៀត ៗ ខុងបេងថា ដែលអ្នកមានប្រ-សាសន៍នោះក៏ត្រូវហើយ តែថាឥឡូវទាល់ទីងជ្រក ហើយត្រូវតែទៅពឹង ពាក់អាស្រ័យនៅសិនចាំកាំងខ្ញុំបាន ទើបរិះគិតការតទៅទៀត ៗ ឡោសុកថា លោកទីងទៅទីពឹងពំនាក់ នៅក្នុងស្រុកកាំងកាំងមិនល្អឬ ? ព្រោះស៊ុនគួនចៅហ្វាយខ្ញុំក៏មានចិត្តថ្លៃមល្អត្រឹមត្រូវ រាប់អានខ្ទួរទៅគ្រប់ បណ្ដាក្សត្រដោយស្មើ សឹងតែចូលចិត្តស្រឡាញ់ជាច្រើន ហើយស្រុក នោះក៏បរិបូណ៌ចំណីត្រីសាច់ ទីងស្រូវអង្ករស្បៀងអាហារ សុំលោកឲ្យ បំរើទៅនិយាយនឹងស៊ុនគួនមើលជាផ្លូវល្បងល្បួងលោម ឲ្យបានជាចិត្ត គំនិតមួយ ជួយគ្នារិះគិតកំចាត់ចូចូចេញ ឃើញថាទីងបានសម្រេចដូច សេចក្ដីប្រាថ្នារបស់លោក ៗ

ខុងបេងឆ្លើយថា អ្នកមានប្រសាសន៍នេះត្រូវក្រពេក ខ្ញុំមាន អំណរគុណជាអនេកណាស់ តែថាទៀតពីទីងស៊ុនគួននោះ មិនធ្លាប់រាប់ អានគ្នាមកពីដើម បើទោះបីទីងឲ្យទៅនិយាយក៏ក្រែងថាស៊ុនគួនទីងមិនប្រែ ប្រួល បណ្ដាលចិត្តឲ្យអាណិតអាសូរករុណា ក៏ខឹកព្រួយការទៅទទេ មួយទៀត ទីងរកមនុស្សបេះនិយាយ ឲ្យទៅផ្សំផ្គួសជាភ្នាក់ប្រមុះនោះកំ

កម្រ ៗ ឡោសុកថា សត្វថ្ងៃដូកាត់ក៏ខូចបង់ លោកក៏បានទៅនៅស្រុកកាំង
តាំងជាទីប្រឹក្សាធំរបស់ស៊ិនគួនដែរ ចេះតែបន់ស្រន់ចង់ឲ្យជួបនឹងលោក
ផងដែរ ធុរៈនេះខ្ញុំនឹងសុំទទួលធានានាំលោកទៅឲ្យដល់ស៊ិនគួនបរបា
ឲ្យគ្រាតែបាន ៗ ឡៅពីឮឡោសុកនិយាយដូច្នោះ ក៏ឆ្លើយថា ឯខុង
បេងនេះ ជាអាចារ្យរបស់ខ្ញុំ ប្រៀបដូចថ្លើមប្រមាត់ បើឃ្លាតបាត់ពី
ខ្ញុំតែមួយស្របក់ក៏មិនបាន ធ្វើម្តេចខ្ញុំនឹងហ៊ានឲ្យទៅដល់ស្រុកកាំងតាំង
នោះឡើយ ៗ ឡោសុកក៏អង្វរលន់តួថា សូមឲ្យខុងបេងទៅជួបគ្នានឹង
ចៅហ្វាយខ្ញុំបានម្តងចុះ ៗ ឡៅពីក៏ធ្វើព្រងើយបែបមិនដឹងមិនយល់
ខុងបេងក៏ធ្វើជានិយាយនឹងឡៅពីថា ការគ្រានេះក៏ដូចជាប្រពាល់តួនឹង
ខ្លួនយើងណាស់មកហើយ នឹងស្ងៀមព្រងើយមិនកើតទេ សុំលោកឲ្យខ្ញុំ
ទៅបន្តិចចុះ នឹងបានដឹងការចុះស្រាសគិតកែប្រែរក្សាខ្លួនទៅខាងមុខ ៗ
ឡៅពីថា បើដូច្នោះលោកខុងទៅក៏ទៅចុះ ៗ ឡោសុកឮហើយក៏
ត្រេកអរសាទរ ទើបគំនាប់លាឡៅពី ហើយក៏នាំខុងបេងទៅចុះទូក
ហើយថាៈបើលោកទៅជួបនឹងស៊ិនគួនហើយ កុំប្រាប់ថាចូចមានទាហាន
ច្រើន ត្រូវប្រាប់ជាពាក្យភូតថាមានទាហានតិចទេ ខុងបេងថា ខត្រង់
នេះអ្នកកុំព្រួយឡើយ ទុកជាភ្នាក់ងារខ្ញុំចុះ ៗ

លុះឡោសុកនាំខុងបេងទៅដល់ស្រុកកាំងតាំង ក៏បត់បែងទីសំ
ណាក់ឲ្យខុងបេងនៅជាមួយសមុទ្រ ហើយក៏ចូលទៅជំរាបស៊ិនគួន ៗ

កំសួរថា អ្នកទៅស៊ើបស្តាប់កិច្ចការឯស្រុកកាំងហែនោះ ដំណើរយ៉ាងម្តេចខ្លះ ៗ ឡោសុកឆ្លើយថា ខ្ញុំបាទទៅស៊ើបការនោះក៏បានសេចក្តីមកហើយ តែជាដំកបលោកឥឡូវនេះមិនទាន់ស្រួលទេ ៗ ស៊ុនគួនឮដូច្នោះទើបយកសំបុត្រដែលចូចូឲ្យទៅនោះ ហុចទៅឲ្យឡោសុកមើលតាំងក្រោម ៗ ឡោសុកទទួលហើយក៏ថា ដែលចូចូឲ្យសំបុត្រមកនេះប្រាថ្នានឹងល្បងការរួងលោមឲ្យជាចិត្តមួយ ប្រយោជន៍នឹងបានគិតការតទៅមុខឃើញថាសេចក្តីនេះ មិនមែនមកដោយសុចរិតនឹងយើងទេ និយាយហើយក៏ហែកក្រោមចេញ មើលឲ្យស៊ុនគួនស្តាប់សេចក្តីថា ព្រះចៅហៀនតេឲ្យយើងលើកទ័ព ៨០ ម៉ឺន មកកំចាត់ឡៅបេងចេញ ឥឡូវលើកមកក៏បានស្រុកស៊ិងយ៉ុងនឹងអាណាខេត្រស្រុកកេងជីវហើយ អាណាប្រជានុរាស្ត្រទាំងពួងមានសេចក្តីត្រេកអរជាច្រើន ឯយើងក៏កំពុងប្រមូលទាហានថែមទៀតបានដល់ ១០០ម៉ឺន នាយទាហាន ១០០០ តែមានចិត្តគិតដល់អ្នកនឹងចង់ជួបឃើញមុខគ្នាម្តង សុំឲ្យអ្នកចេញមកដើរលេងព្រៃកងស្រុកកាំងហែ នឹងបានជួបគ្នារិះគិតកំចាត់ឡៅពីចេញ ព្រោះជាសត្រូវផែនដី បើសម្រេចហើយយើងនឹងបែងរំលែកស្រុកកេងជីវឲ្យអ្នកពាក់កណ្តាល ហើយយើងនឹងស្បថស្បែទុកគ្នាជាចិត្តថ្មីមួយតទៅ បើអ្នកឃើញប្រការម្តេច ក៏ឲ្យមានសំបុត្រតបទៅវិញឲ្យដឹងផង ៗ

ឡោសុកមើលសំបុត្របបក៏សួរទៅស៊ុនគួនថា ចិត្តរបស់លោកនឹង

គិតប្រការម្តេចលោក ? ។ ស៊ិនគួនតបថាយើងនៅមិនទាន់បានគិតគូរទេ ។ ទៀវចៀវឆ្លើយថា ឥឡូវច្បូចបានប្រមូលទាហានដល់ ១០០ម៉ឺន យកព្រះអង្គម្រាស់ព្រះចៅហៀនតេមកនិយាយតាំងម៉្លេះ ប្រាថ្នានឹងដើរតំបាត់អាណាខែត្រតាំងអស់ឲ្យនៅក្នុងអំណាចខ្លួនតាំងអស់ ដែលលោកខំនឹងរិះគិតតស៊ូនឹងច្បូចនោះឥតអំពើទេ ទីងអាស្រ័យបានក៏ត្រឹមត្រូវតែក្បែរជាយទន្លេជារបាំង ឥឡូវបើច្បូចបានស្រុកកេងជីវហើយ ទាហានក្នុងស្រុកនោះក៏មិនប្រសប់ក្នុងជើងទឹកដូចគ្នានឹងស្រុកយើង ប្រសិនច្បូចលើកទ័ពប្រទូសរ៉ាយស្រុកយើង ។ ក៏នឹងថ្វសការ សូមឲ្យលោករិះគិតដោយប្រាជ្ញាពេលនគួច្បូចដោយល្អចុះ អាណាប្រជានុរាស្ត្រតាំងពួងក៏នឹងបាន:សចក្តីសុខតទៅ បណ្តាទីប្រឹក្សាទាំងពួងបានឮទៀវចៀវនិយាយដូច្នោះក៏ឆ្លើយឡើងថា ដែលទៀវចៀវនិយាយដូច្នោះ ឃើញត្រឹមត្រូវតាមប្រវេណីប្រាកដ ស៊ិនគួនក៏នៅស្ងៀមមិនឆ្លើយជាប្រការម្តេច ទៀវចៀវក៏ថែមនិយាយឡើងទៀតថា លោកកុំរែកក្រួយឡើយ ចូរខំរិះគិតចេញទៅតំនាប់ច្បូចចុះ ទើបបានសេចក្តីសុខ ។ ស៊ិនគួនក្រវីក្បាលហើយក៏នៅស្ងៀម ១ ស្របក់ ទើបក្រោកឡើងចេញពីទីជំនុំ ហើយដើរចូលទៅខាងក្នុង ។ ឡោសុកក៏ដើរតាមទៅ ស៊ិនគួនចាប់ដៃឡោសុកចូលទៅហើយនិយាយថា ដែលទីប្រឹក្សាតាំងពួងឃើញដូចពាក្យទៀវចៀវដូច្នោះអ្នកនឹងគិតប្រការម្តេច ? ។

ឡោស៊ុកឆ្លើយថា ដែលអស់អ្នកទាំងពួងយល់ឃើញព្រមគ្នាទីងឲ្យលោកទៅគិនាថប៉ូចូ ប្រយោជន៍ឃើញតែសេចក្ដីសុខប៉ុណ្ណោះ ដូចជាឲ្យបានទុក្ខទៅមុខវិញ ខ្ញុំបាទម្នាក់ឯងមិនយល់ឃើញផងទេ សូមកុំឲ្យលោកចេញទៅគិនាប៉ូឡើយ ។ ស៊ុនគួនថា ដែលអ្នកមិនពេញចិត្តទីងឲ្យយើងចេញទៅគិនាថប៉ូចូនោះត្រូវណាស់ តែសេចក្ដីរិះគិតរបស់អ្នកទីងឃើញប្រការម្ដេចខ្លះ ? ។ ឡោស៊ុកឆ្លើយថា ខ្ញុំបាទឃើញថាប៉ូចូឬ ? ទីងចិញ្ចឹមលោកឲ្យធ្វើជាធំ តោះបើទីងទុកបំរុងក៏គ្រាន់តែជាប្រមាណបើប្រសិនឲ្យមានបាវព្រាវដើរតាមក្រោយ យ៉ាងច្រើនណាស់ ក៏ត្រឹមតែ ៤នាក់ប៉ុណ្ណោះ តោះបើទីងឲ្យមានសេះជិះក៏តែ ១, ទីងបានឲ្យដូចលោកនៅជាឯកចិត្តក្នុងស្រុកការទីតាំងតែម្នាក់ឯងក៏ទេ ដែលអ្នកពល់គ្នាយល់ឃើញព្រមលម្មនោះ ក៏ប្រយោជន៍តែឲ្យខ្លួនមានសេចក្ដីសុខប៉ុណ្ណោះឯងទីងបានជួយឈើចាប់ក្នុងចិត្តដូចលោកដូចខ្ញុំបាទក៏មេ ដែលលោកទីងរិះគិតធ្វើការតទីងប៉ូចូនោះ មិនត្រូវជឿស្ដាប់ពាក្យសំដីអស់អ្នកទាំងអម្បាលនោះតទៅឡើយ ចូររិះគិតប្រុងប្រៀបការទីងកែខ្លួនឲ្យមាំមួនចុះ ។

ស៊ុនគួនដកដង្ហើមធំហើយថា ខ្លួនខ្ញុំអភ័ព្វបង់កំឡាំងទីងខំបណ្ដុះបណ្ដាលមនុស្សអស់ទាំងនេះទុក ប្រាថ្នាទីងយកជាទីពឹងគ្រោះឲ្យដឹងការខុសត្រូវធ្ងន់ស្រាលជួយឃើញ្ញាលក៏អសារទេទេសោះ ឃើញតែខ្លួនអ្នក ១ មានគតញ្ញូណ៍ទៀងត្រង់ស្រឡាញ់ខ្ញុំមែន ។ ឥឡូវប៉ូចូក៏បានខំតាហានអ្នកសៀវ.

ទុកជាឈ្លើយច្រើនណាស់រឹតតែមានចិត្តកំរើកឡើង ដែលយើងនឹងគិតធ្វើការតទល់នឹងចួចនោះនឹងកែប្រែយ៉ាងម្ដេចទើបបានល្អ? ។ ឡោសុកថា កាលខ្ញុំបាទទៅស៊ើបស្ដាប់ការឯស្រុកកាំងហៃនោះ ខ្ញុំបាទបាននាំខ្លួនខុងបេងប្អូនប្រុសជូកាត់គិនមកជាមួយ បើលោកចង់ដឹងការកាក់ទាក់ជ្រៅធ្ងន់ក្រោលពិចួចប្រការម្ដេច សូមឲ្យលោកហៅខ្លួនខុងបេងមកសាកសួរមើលចុះ ទើបនឹងជ្រាបច្បាស់ ។ ស៊ុនគួនថា អាចារ្យហុងឡុងមកនៅទីនេះដែរឬ? ។ ឡោសុកថា ខ្ញុំនាំមកបាត់បែងឲ្យសំណាក់នៅខាងក្រៅស្រុក ។ ស៊ុនគួនពួជូហោះត្រេកអរណាស់ ទើបថា ថ្ងៃនេះជួនពេលយប់ទៅហើយ ចាំថ្ងៃស្អែកព្រឹក អ្នកចូរនាំខុងបេងចូលមកជួបនឹងយើង, ស៊ុនគួនក៏ឲ្យរៀបចំទីកន្លែងដែលនឹងទទួលពួកនាម៉ឺនមុខមន្ត្រី ប្រជុំនិយាយការឲ្យជាទីរុងរឿងប្រាថ្នានឹងបង្អួតឲ្យខុងបេងឃើញ ហើយបាត់កំណត់ឲ្យនាម៉ឺនទាំងពួងចូលមកជួបជុំព្រមគ្នាក្នុងវេលាព្រឹកស្អែកឲ្យអស់ ។

លុះវេលាព្រឹកនោះ ឡោសុកក៏ទៅជួបនឹងខុងបេង ជំរាបថា ស៊ុនគួនឲ្យខ្ញុំមកអញ្ជើញលោកចូលទៅ ពាក្យដែលខ្ញុំបាទបរតានឹងលោកកណ្ដាលផ្លូវនោះ លោកកុំបីភ្លេចឡើយ ។ ខុងបេងអស់សំណើចហើយតបថា អ្នកកុំវិតក្កព្រួយឡើយ ។ ឡោសុកក៏នាំខុងបេងចូលទៅកាន់ទីប្រជុំ ដើម្បីនឹងទៅគំនាប់ស៊ុនគួន លុះទៅដល់ទីជាន់ក្រៅ ខុងបេងក្រឡេកឃើញទីប្រឹក្សាសុទ្ធតែនាម៉ឺនកែងខ្លួនពេញយស អង្គុយចុះនៅជួររៀងគ្នាជា

លំដាប់ ក៏ចូលទៅតទាប់តាមប្រវេណី តាំងអស់គ្នា រួចសន្ទនា សាកសួរសុខទុក្ខទៅវិញទៅមក ៗ ខៀវចៀវឃើញខុនបេនរូបពង្សស្អាតបាត តែងខ្លួនរៀបរយសមជាអ្នកមានសំដីចរចាវៀវឆ្លាត ក៏គិតប្រមាថខុនបេនទេះ ប្រហែលជាមកនិយាយបញ្ចុះបញ្ចូលមើលឡែបខាយជាប្រាកដ ត្រូវតែឃើញចរចាសាកសួរតាមបរស្តាប់ កំឡាំងប្រាជ្ញាទាំងជម្រះរិះគិតជាប្រការម្តេច ខៀវចៀវក៏និយាយថា ពីដើមខ្ញុំដឹងថាអាចារ្យហ៊ុនឡុងទៅដំបន់ភ្នំងើឡាំងកាំង ឮគេនិយាយថា ប្រកបទៅដោយសតិបញ្ញាជាច្រើនដូចអាចារ្យខ្ញាន់តុងឆាក់យៃមែនដូច្នោះឬ ? ៗ

ខុនបេនឆ្លើយថា ដែលគេសរសើរខ្ញុំនោះ គ្រាន់តែឃើញបញ្ញាខាងក្រៅ ដែលបានធ្វើការមកនោះក៏ដូចអ្នកទាំងពួងសំគាល់ ព្រោះការនោះមិនជាក្រលំបាកណាស់ណាទេ ទោះបីនរណា ៗ ក៏នឹងធ្វើបាន ឯបញ្ញាខាងក្នុងនោះ នរណានឹងអាចកន្ទុងដឹងឲ្យឃើញប្រាកដនោះគ្មានទេ ៗ ខៀវចៀវថា ខ្ញុំបានឮគេដំណាលថា ឡៅពីស្រាហ៊ាធ្វើសេចក្តីព្យាយាមទៅអញ្ជើញអ្នកដល់ ៣ ដងទើបបានអ្នកមក ឡៅពីមានអំណរដូចត្រីបានទឹក ទើបកំរើកចិត្តគិតទឹកធ្វើការធំទូលាយទៅមុខ បំណងនឹងយកស្រុកកេងជីវឲ្យបានជាប្រាកដ ទុកដូចសន្ទូចទៅកន្លងកណ្តាប់ដៃ វិស័យដូចយកកន្ទេលមកក្រាលអង្គុយក្រាមដោយងាយដូច្នោះ ហេតុម្តេចស្រុកកេងជីវនោះ ក៏ត្រឡប់បានទៅចូចូវិញ តើអ្នករិះគិតប្រការម្តេច ? ៗ

ខុនឆេងឮដូច្នោះក៏គិតថា ទៀវចៀវនេះជាទីប្រឹក្សាធំរបស់ស៊ុនគួន មានប្រាជ្ញាជ្រៅទូលាយណាស់ បើអញមិនតបឆ្លើយឲ្យទាល់នឹងពាក្យប៉ុណ្ណោះ កាលណានឹងចរចាតបនឹងស៊ុនគួនបានតទៅ គិតហើយក៏ឆ្លើយថា ដែលខ្ញុំនឹងគិតធ្វើការយកទីផែនដីដែនស្រុកកេងជីវនោះងាយណាស់ ក៏ដូចជាត្រឡប់បាតដៃជាខ្នងដៃក្ដាម ។ ពោះបើនឹងព្យាយាមធ្វើកាលណា បើនឹងបានសម្រេចកាលណោះ តែហេតុទាំងនេះ ក៏ព្រោះចៅហ្វាយខ្ញុំជាមនុស្សគ្រប់ពិត កាន់សេចក្ដីសុចរិតមិនគិតប្រាជ្ញាដែលនឹងដណ្ដើមយកសម្បត្តិរបស់សែជាមួយគ្នា មិនព្រមធ្វើតាមពាក្យខ្ញុំ ទើបបានសេចក្ដីព្រួយលំបាក មកនឹកតូចចិត្តជ្រួតឡាចងនៅក្នុងចៀមដៃជៀកាន់យកពាក្យសំដីមនុស្សខ្សែបឡូចលបលើកមកស្រុកស៊ិនយ៉ុងទៅប្រគល់ឲ្យចូចូ ចូចូទើបឡើងចិត្តគិតធ្វើការធំពន្ទុកមកដល់ម៉េះ ឯឡៅតិះចៅហ្វាយខ្ញុំនេះក៏មកតាំងនៅស្រុកកាំងហែវិញ ប្រាថ្នានឹងធ្វើការឲ្យបានចំណេញធំតទៅទៀត មិនមែននឹងលាក់មុខដេកនៅស្ងៀមៈទ តែថាដូចយ៉ាងដម្រេះប្រាជ្ញាអ្នកគ្រាន់តែជាការប្រមាណប៉ុណ្ណោះ ពោះបើខ្ញុំនឹងលូកៈកៈប្រាប់ឲ្យយល់ដល់ការរាក់ជ្រៅ ក៏នៅមិនអាចដឹងដល់ស្គាល់បានសោះដូចជាយកកែវធ្លុះទៅបោះជាក់ក្នុងពានដែលងងឹត អាចនឹងបំភ្លឺពាំងស្មុំមិនភ្លឺស្វាងសោះឡើយ ។

ទៀវចៀវថា អ្នកនិយាយយ៉ាងនេះ ខ្ញុំខ្លាចមិនដូចពាក្យថាប្រាកដ គឺជាតែមាត់ក្រៅ មាត់ជាទៅខាងណោះ ជើងដើរទៅខាងណោះឲ្យខុស

តាទៅ ឯខ្លានតុនពីក់យេនោះបានជាទីទបេកជ ប្រកបដោយសតិបញ្ញា អនំអាចដូចកជសីហ៍ ជួយទំនុកបំរុងផែនដីព្រះទៅដីហ្លួនកុនប្រាបសត្រូវ ឲ្យពចពាប ស្រុកទេសក៏ជាសុខក្សេមក្សាន្តមែន ។ គួរមនុស្សតែបុកណា លើកសរសើរថាមានដំរេះប្រាជ្ញានោះពិតណាស់ យ៉ាងដូចខ្ញុំអ្នកនេះ កាលទៅក្នុងទីដោទ្យាំងកាំងនោះ ឮល្បីល្បាញថាមានប្រាជ្ញាទីងគំនិតបេះ រិះគិតប្រាកដណាស់ បីដូចជាដឹងចុះហូតទៅក្នុងផែនដីឬអាកាសទាំងអស់ កាលឡើតមិនទាន់បានអ្នកមកទុកជាទីពិគ្រោះ ក៏រមែងគិតធ្វើការសម្រេចទៅបាន ហើយមានស្រុកទេសតាំងនៅជាសុខតាមរាសនានៃខ្ញុំ ឥឡូវបានអ្នកមកទុកជាទីប្រឹក្សាជាជាមាំមួន ឲ្យជួយទំនុកបំរុងការដែលធំពន្លឹក ក៏នឹកថាបានសម្រេចទៅតាមកំឡាំងដំរេះរិះគិតរបស់អ្នកហើយ ហេតុម្តេចឡើយឡើតតែតែមានសេចក្តីទុក្ខក្តៅនៅមិនបានសុខសោះ ឃើញថាទុក្ខទាំងអស់ទ្វេលើសពីដើមទៅទៀត បេះតែព្រួយបង្អៀតរត់ហោលទឹកន្ទ្រង ដោយចូចូដេញមិនឈប់ មកជ្រកពួននៅដូចកណ្តុររត់ពីអន្ទិប សូម្បីតែផែនដីជាមួយបុ័នស្លឹកពុទ្រាក៏រកនៅជារបស់ខ្ញុំមិនបាននេះហើយឬ ដែលឡើតបានអាស្រ័យសេចក្តីគិតរបស់អ្នកជួយទបតម្កទំនុកបំរុងនោះ មនុស្សទាំងពួងនាំគ្នាមកសរសើរថា អ្នកមានដំរេះប្រាជ្ញាដូចខ្លានតុនពីក់យេនោះមិនសមសោះ ដែលខ្ញុំនិយាយទាំងអស់នេះតាមដោយការពិត អ្នកកុំអាលតូចចិត្តលម្រិះគិតតទៅទៀតចុះ ។

ខ្ញុំនេះឃើញដូច្នោះ ក៏យកដៃបិទមាត់ ហើយគស់សំណើចរួចឆ្លើយ
ថា ធម្មតាអ្នកមានប្រាជ្ញាដែលពិស្តារ ព្រោះបើនឹងគិតការអ្វីក៏ជ្រៅទូលាយ
ដោយកលកិច្ច អ្នកមានប្រាជ្ញាតិចក៏មិនអាចនឹងដឹងហេតុទៅបាន ឧបមា
ដូចស្តេចគ្រុឌដ៏ប្រសើរ ព្រោះបើនឹងហើរទៅកាន់ទិសដំបន់ណា ក៏រមែង
ផ្លោះទៅលើអាកាសដ៏ខ្ពស់បំផុត បាត់ទៅនឹងស្រទាប់មេឃលើ មិនបាន
ហើរទាបដូចសកុណជាតិដទៃ ដែលមានកំឡាំងតិចនោះឡើយ ឯអ្នក
ដែលមានជម្រះប្រាជ្ញាតិចនោះ ឧបមាដូចបក្សាចាំងពួង ដ៏មានកំឡាំង
តិច មិនអាចហើរបានស្មើនឹងស្តេចគ្រុឌនោះឡើយ, ១ទៀត ការដែល
គិតធ្វើអ្វី ១ ដ៏ជាធំពន្លឹក នឹងទុកគិតយកដោយស្រួតរូតឲ្យរហ័សសម្រេច
តាមចិត្តនោះមិនបាន ឧបមាដូចមនុស្សមានជម្ងឺឈឺធ្ងន់ទូរទូក ពេទ្យ
អ្នកព្យាបាលរក្សារោគត្រូវដឹងថា នឹងប្រកបថ្នាំឲ្យចាស់ក្លាលើសអាការ
ជម្ងឺ កំឡាំងមនុស្សដែលឈឺក៏ខ្សោយ នឹងបណ្តោយតាមកំឡាំងថ្នាំពុំ
បាន ត្រូវតែចាំឲ្យជម្ងឺនោះធូរស្រាកស្រាន្តតាមពេលវេលា ព្យាយាម
ថែរក្សាពាល់តែជម្ងឺនោះទទួលអាហារបានច្រើនមានកំឡាំងហើយ ទើប
ពេទ្យប្រកបថ្នាំឲ្យលេបផឹកបំរុងរោគនោះ ឲ្យថយទៅគ្រាតែសះជាស្រឡះ
ដូចយ៉ាងឡៅតីហៅហ្វាយខ្ញុំ ដែលជួសការណាស់ទឹងចូច រត់ចេញមក
ពីស្រុកយីឡាំទៅនៅស្រុកស៊ិនអៀ ទីពឹងឡៅប៉ឿវនោះសោត ក៏
មានពាហានឯកតែ ៣ នាក់គឺ គួនអ៊ូ , ទៀវហ៊ុយ , ជូឡុងប៉ុណ្ណោះ

ទាំងកូនចៅ ហានទៅនោះក៏មិនដល់១ពាន់ ដូចជាមនុស្សមានជម្ងឺឈឺធ្ងន់ដូច្នោះ កាលទៅនៅស្រុកស៊ិនអៀនោះ មិនមែនទាំងប្រាថ្នាតាំងខ្លួនជាធំនៅទីនោះក៏ទេ គ្រាន់តែចាំចិត្តនៅ ព្រោះគេទីអាស្រ័យពុំមានបាន, ១ ទៀត ទីនោះក៏ជាចុងស្រុកជនបទ មានមនុស្សក្រខ្សត់ស្គួចស្ដើងទាំងស្បៀងអាហារក៏តិច បានជាមិនបានតាំងចិត្តនឹងសម្រេចរៀបចំស្រុកភូមិឲ្យរៀបរយ ពោះបើយ៉ាងនោះហើយក្ដី ខ្ញុំក៏បានដុតទ័ពបួចខ្ទបខាតនៅទីវាលកុកបន្ទួន នៅទទេទ្វែរះហាមួន ខ្ញុំក៏បានបង្ហូរទឹកឲ្យលិចទ័ពបួចស្លាប់អស់ជាច្រើន ដែលអ្នកចាំខ្មាន់តុងង៉ាក់យេល្អនោះក៏នៅមិនទាន់ប្រាកដជាបានធ្វើ១បាយកលក្នុងការសង្គ្រាមនៅទីណា ដូចយ៉ាងខ្ញុំ ក៏ឥតអង្គីមាន ពោះបើបួចបានស្រុកស៊ិនយ៉ុងគ្រានេះ ក៏មិនមែនយកបានដោយពលការ បានពិគ្រោះឡៅចង់គប់គិតគ្នានឹងមនុស្សអន្ទពាលលបលើកទៅឲ្យបួច ឯឡៅពីទៅហ្វាយខ្ញុំ ក៏មិនបានដឹងឃើញសោះ វេលានោះ បើទៅហ្វាយខ្ញុំមិនស្រឡាញ់សេចក្ដីសុចរិត ប្រហែលពួកស្រុកកាំងតាំងនោះ ក៏គង់នឹងដណ្ដើមយកទាំងស្រុកកេងជីវជង់បាន ការបេណាទឹងមានលំបាកដល់ទ័ពនេះ ព្រោះតែចិត្តត្រង់សុចរិតដូច្នេះ ទើបមិនបានគិតបៀតបៀនដល់ពួកសែជាមួយគ្នា ស៊ូទ្រាំឲ្យបានសេចក្ដីលំបាកវេទនាដូច្នេះ ហើយថែមទាំងម៉្ញះទៅទៀត គឺចាំសណ្ដានយកអស់ពួកអ្នកស្រុកដែលលើកគ្នាតែតាមទាំងគ្រប់គ្រងដោយស៊ាំស្រឡាញ់ឡៅពី ១ នឹង

ដោះយកតែខ្លួនគឺជាប់ចិត្តអាណិតអាសូរ   បានជាចូលលើកតាមតាន់បាន តយុទ្ធការពារដោយលំបាក   ទើបត្រឡប់ឆកទៅនៅស្រុកកាំងហៃវិញ ដែលពួកតិចអាចតស៊ូនឹងពួកច្រើនបានយ៉ាងនេះ   មានតែចៅហ្វាយខ្ញុំមួយ ទើបហ៊ានធ្វើដូច្នេះ   ក្រៅពីនេះគ្មាននរណាមួយដូចសោះ   ឯការចាញ់ នឹងឈ្នះនៃការសឹកសង្គ្រាមនោះជាធម្មតាប្រវេណីមានមក   មិនមែនថយ ថោកតែត្រឹមចៅហ្វាយខ្ញុំទេ   កាលគ្រាព្រះចៅហាន់កោចោធ្វើសឹកនឹង ព្រះចៅឈ្យាំអងក៏មានចាញ់ជាច្រើនដងណាស់ លុះឯក្រោយចង្អស់ទើប ព្រះចៅហាន់កោចោ មានជ័យជំនះអស្ចារ្យ   ក៏បានជាក្សត្រិយ៍ដ៏ប្រសើរ ឯដំណើររឿងនេះ   អ្នកក៏ល្មមនឹងជ្រាបស្រាប់ហើយ   យ៉ាងដូចអ្នកឯង ប្រហែលចេះតែសំដែងសំដីនិយាយគ្របសង្កត់អ្នកដទៃទេ   ហើយប្រែ លើកដំកើងខ្លួនថាល្អ   បើប្រសិនជាមានការកម្រមកដល់ខ្លួនក៏នឹងខ្លាច មិនអាចនឹងចេះប្រសប់ធ្វើឲ្យដូចពាក្យថា   ការមួយរយ   ក្លាយធ្វើបាន តែមួយ   ក៏ប្រហែលមិនកើតសោះ   អំណឹះទៅមុខ   ក៏នឹងបានសេចក្ដី អប្បយសដល់មនុស្សទាំងពួង ៗ ទៀវចៀវបានស្ដាប់ខុងបេងថាឲ្យដូច្នោះ ក៏ស្ងៀមស្ងាត់នឹងរកពាក្យតែ ១ មាត់ឆ្លើយតទៅទៀតពុំបាន ៗ

ខណៈនោះយីហ្វិនឃើញទៀវចៀវស្ងៀមនៅហើយ   ក៏ឆ្លើយតប ទៅខុងបេងថា   គ្រានេះចូលលើកទាហានមក ១០០ ម៉ឺន   បីដូចរលក សមុទ្របោកជាន់សង្កត់ស្រុកកាំងហៃឲ្យលិចទៅក្នុងបាកសាគរ   អ្នកនឹង

គិតរិះរកប្រាជ្ញាការពារប្រការម្ដេច ? ។ ខុងបេងឆ្លើយតបទៅយីហ៊ួនវិញថា ចូចូលើកទ័ពមកគ្រានេះ អ្នកនឹងខ្លាចណាស់ឬ ? ខ្ញុំគ្មានព្រី ព្រួយវិតក្កអ្វីសោះឡើយ ពោះបើចូចូមានទាហាន ១០០ ម៉ឺនក៏មែន តែជាសុទ្ធតែទាហានគម្ពីនសៀវដែលជាជាតិអ្នកស្រែស្រុកព្រៃលើក្តីចាំងអស់គ្នា ចូចូនឹងប្រើការក៏មិនមែនបានមុតមាំប៉ុន្មាន យើងក៏មិនមានព្រួយបារម្ភសោះ ។ យីហ៊ួនអស់សំណើចហើយថា អ្នកបវរតាយ៉ាងនេះដូចជាលើកខ្លួនណាស់ ដែលបែកទ័ពតែមកចាំងម៉្លេះមិនពីព្រោះទាហានផ្ដេសផ្ដាសនោះទេឬ ? បានជាធ្លាក់ខ្លួនមកនៅស្រុកកាំងហៃ បើអង្វរឲ្យគេជួយនៅចរចាថា មិនខ្លាចទៀត នរណានឹងជឿបាន ?

ខុងបេងថា ដែលខ្ញុំបែកទ័ពមកនោះ គឺព្រោះឡៅពីចៅហ្វាយខ្ញុំមានទាហានតិចតែ ៣ ពាន់ គឺតិចបំផុត ទើបគិតដោយល្បិចតែមកលាក់លៀមនៅស្រុកកាំងហៃសិន មិនមែននឹងខ្លាចថ្វីដែលចូចូតែម្ដងក៏ទេ គង់នៅរិះរកគិតធ្វើការតទល់តទៅទៀត ឯស្រុកកាំងតាំងនេះ មនុស្សបំណុះស្រុកក៏ច្រើន ទាហានក៏កើនលើសលុបប៉ុនប្រសប់ស្មើគ្នា ថែមចាំងស្បៀងអាហារទៀតក៏បរិបូណ៌ ហើយមានទះខ្ទាន់ជាកំណាត់នៅមាំមួនណាស់ ជាដានស្រុកស៊ុនអៀវទៅទៀត ហេតុម្ដេចក៏មកគិតធ្លាក់ធ្លៀត តែនឹងឲ្យចៅហ្វាយរបស់ខ្លួនទៅចុះចូលចូចូតែម្ដង ដូចជាមិនមានសេចក្ដីអៀនខ្មាសសោះ ដែលអ្នកថា ចៅហ្វាយខ្ញុំខ្លាចចូចូនោះ

បើទឹងពិគ្រោះមើលក៏ឃើញបីដូចជាខ្លាចតិចសមគួរ មិនស្មើទឹងពួកអ្នកឯងក្រែងខ្លាចនោះឡើយ ។ យើហ្វិនស្តាប់ហើយក៏ទាល់គំនិតប្រាជ្ញា ទឹងហាមាត់ឆ្លើយទៅទៀតក៏ពុំបាន ។

ចោ៉ៅឃើញយើហ្វិននៅស្ងៀមដូច្នោះ ក៏ឆ្លើយតបទៅខុងបេងថា អ្នកនេះបានរៀនខិយាយមកពីសំណាក់សោជិន, ទៀវយី ឬ ? អ្នកមកពោលពាក្យដូច្នេះ ប្រាជ្ញាទឹងបញ្ចុះបញ្ចូលពួកស្រុកកាំងតាំងឲ្យចុះចិត្ត ឬអ្វី ? ។ ខុងបេងឆ្លើយថា អ្នកដឹងតែថាសោជិន, ទៀវយីនោះ ជាមនុស្សពូកែខាងសំដីណាស់ ឯគ្រឹង់ជម្រះប្រាជ្ញាទឹងគំនិតដែលរិះគិតរបស់សោជិនទឹងទៀវយី ដែលចេះជ្រៅជ្រះប្រការម្តេចនោះ អ្នកឥតដឹងសោះ អ្នកបរិយាយដូច្នេះបីដូចជាមនុស្សពាក់កណ្តាលមនុស្ស ព្រោះជាដឹងមិនរហូត ឯសោជិននោះបានធ្វើជាឧបរាជដល់៨ខេត្រ, ទៀវយីសោតក៏បានជាឧបរាជដល់ ២ ផែនដី អ្នកទាំង ២ នេះមានជម្រះប្រាជ្ញាជ្រៅទូលាយណាស់ ជួយទំនុកបំរុងផែនដីឲ្យរាបទាបផង ១ ទៀតជាអ្នកក្លៀវក្លាក្នុងការសង្គ្រាម ដែលអ្នកមកនិន្ទាថាជាមនុស្សពូកែខាងសំដីមិនគួរសោះ យ៉ាងខ្លួនអ្នកឯងរាល់គ្នា គ្រាន់តែឮដំណឹងថាចូចចុំណោះ ក៏ខ្លាចញ័រខ្លួនទៅណាស់ លួងលោមឲ្យចៅហ្វាយជាម្ចាស់របស់ខ្លួនចេញទៅចំណុះចុះចូលសត្រូវមិនខ្មាសមាត់ទេឬ ? នៅមកតិះដៀលអ្នកដទៃវិញ ចោ៉ៅបានឮខុងបេងថាដូច្នោះ ក៏ទាល់នៅស្ងៀម ។

ស៊ីហានក៏ក្រោកឡើងសួរខុងបេងថា៖ ចូឆូនោះជាមនុស្សយ៉ាងម្តេច អ្នកស្គាល់ឬទេ ? ។ ខុងបេងថា ចូឆូនោះជាសត្រូវនឹងព្រះចៅហៀនតេ នរណាៗក៏អាចស្គាល់បានទាំងអស់ ហេតុម្តេចក៏អ្នកមកសួរដូច្នេះ ។ ស៊ីហានឆ្លើយថា កាលព្រះចៅហានកោចោបានសោយរាជសម្បត្តិជាក្សត្រាធិរាជ ផែនដីក៏អាចបានសេចក្តីសុខមកយូរអង្វែងប្រាកដ ឥឡូវដល់កំណត់ផែនដីនឹងកើតចលាចលហើយ ចូឆូក៏ប្រាប់ប្រាមខេត្រខណ្ឌសីមាឲ្យនៅក្នុងអំណាចរបស់ខ្លួនដល់ ២-៣ ភាគហើយ ទៀតពីចៅហ្វាយអ្នកមិនបានដឹងច្បាស់លក្ខណៈការធ្ងន់ស្រាលគួរឬ មកបណ្តាលចិត្តគិតហ៊ានតស៊ូនឹងចូឆូដោយស្រួលពន់ ដូចយកពងមាន់ទៅជល់នឹងថ្មក៏នឹងអន្តរាយទៅឯង ។ ខុងបេងថា អ្នកនិយាយដូច្នោះមិនត្រូវសោះ ឯទៀតពីចៅហ្វាយខ្ញុំនោះប្រាកដជាមនុស្សសុចរិតកតញ្ញូនឹងផែនដីពិត ដែលខ្ញុំបានចំរិះគិតធ្វើការ ទាំងម៉ោះក៏ឃើញថាជាមនុស្សល្អត្រង់នឹងព្រះចៅហៀនតេជាមហាក្សត្រ ឃើញថាចូឆូជាសត្រូវរាជសម្បត្តិ ទើបបណ្តាលចិត្តឲ្យឈឺក្តៅនៅពុំសុខ ខ្ញុំចំមករងទុក្ខវេទនាដើម្បីនឹងតបស្នងឆ្លងព្រះតេជព្រះគុណម្ចាស់ផែនដី ដូចយ៉ាងខ្លួនអ្នក ក៏ជាមន្ត្រីខ្ញុំផែនដីក្រោមព្រះបាទព្រះចៅហៀនតេដូចគ្នា ហេតុអ្វីក៏មិនមានសេចក្តីស្នេហាកក្តីស្រឡាញ់ម្ចាស់ ក្រឡះឃើញត្រូវខាងសត្រូវផែនដីវិញ គឺជាមនុស្សអកតញ្ញូតាក្រក់ណាស់ ទើបមកផ្ទាស់កាន់យកថា ការផែនដីនឹងសាបសូន្យនោះជាស្រួល ពាក្យ

សំដីរបស់អ្នកពោលដូច្នេះ ខ្ញុំមិនចង់ឮចង់ស្តាប់តទៅទៀយ ។ សុំហាន បានឮដូច្នោះហើយ ក៏អត់ទ្រាំក្នុងចិត្តហាមាត់មិនរួច ។

ឡុកចេកក៏គ្រាកឡើងសួរខុនបេងថា ឯចូច្ចូនោះពោះប័ទនីប្រព្រឹត្តអាក្រក់អែបយកព្រះជម្រាស់ព្រះចៅហៀនគេ ដើរប្រាបប្រាមសក្តិវែខត្រខ័ណ្ឌ តាំងពួនឲ្យផែនដីជាចលាចលក៏មែនចុះ តែព្រោះចូច្ចូនោះជាពូជអម្បូររបស់ចូផាំដែលជាឧបកជតផែនដីមុនមក ឯឡៅតីវិញជាពូជក្សត្រិយ៍វងផ្ទារជំណាពីព្រះចៅហៀនគេ យ៉ាងម្តេចយើងក៏មិនដឹង ដឹងតែជាត្រកូលឡៅតីនោះជាមនុស្សអធាថា ខ្ញុំឡៅតីសោតក៏កេស៊ូត្យាញសំពត់លក់ជារបរតូចតាច គួរឬនឹងមកអង់អាចមិនគិតជៀមខ្លួន ហ៊ានតស៊ូនឹងចូច្ចូនោះយើងមិនឃើញផងសោះ ។

ខុនបេងថា អ្នកនេះឬជាឈ្មោះឡុកចេក កាលនៅក្មេងតូចលួចទំគេយកទៅឲ្យម្តាយ អឌ្ឍយទៅចុះយើងនឹងនិយាយផង ដែលអ្នកពប់អានថាចូច្ចូជាពូជអម្បូរនៃចូផាំក៏មែនហើយ តែចូផាំពោះជាមនុស្សមានកតញ្ញូនឹងម្ចាស់ប្រាកដមកពីដើម ឯចូច្ចូនេះជាមនុស្សបង់ជាតិបង់ត្រកូលមិនបានប្រព្រឹត្តតាមប្រវេណីម៉ែឪដូនតា ធ្វើឲ្យខុសចាកត្រកូលមេបារបស់ខ្លួន ដែលខឹងពប់អានថាល្អសមសួននោះ ក៏តែមនុស្សអន្ធពាលប្រហែលអ្នកឯង ឯឡៅតីចៅហ្វាយយើងនោះ ប្រាកដជាពូជអម្បូររបស់ព្រះចៅហៀនគេ ។ ក៏ទំនុកបំរុងប្រែតានចិណ្ណាសក្តិ ៗ អ្នកឯណា ៗ ក៏ដឹងយល់ស្គាល់តាំងអស់

ហេតុម្តេចអ្នកឯងមកជៀលថាជាមនុស្សអនាថា ទោះបីជាអ្នកត្បាញសំពត់លក់ក្តីណា របរនេះជាធម្មតាប្រវេណីគេតែងធ្វើមក ជាផ្លូវរកចិញ្ចឹមជីវិតមិនជាអ្វីណាស់ ឯព្រះចៅហាន់កោះតានោះសោត ក៏មិនសុទ្ធជាពូជព្រះរាជវង្សមកពីដើម គ្រាន់តែជានាយបន្ទុកឃុំប្រកបទៅដោយសេចក្តីព្យាយាមក៏បានជាក្សត្រិយ៍ដ៏ធំប្រសើរ ទើបមានដំណព្រះរាជវង្ស បានសោយរាជសម្បត្តិតៗមក ដរាបដល់សព្វថ្ងៃនេះ អ្នកឯងមកមើលងាយប្រមាថទៀតពីចៅហ្វាយយើងនោះមិនគួរសោះ ព្រោះខ្លួនអ្នកឯងជាក្មេងនៅមិនទាន់អស់ក្លិនទឹកដោះនៅក្នុងមាត់សោះ ទីងមកអួតបេះដូងជាងមនុស្សចាស់នោះកុំនិយាយតទៅទៀតឡើយ ៗ ខ្សុកចេកឮខុងបេងថាដូច្នោះហើយ ក៏តាល់ប្រាជ្ញាឈប់នៅស្ងៀម ៗ

យៀមជុនបានឮខុងបេងថាដូច្នោះ ក៏ឆ្លើយឡើងថា ខុងបេងនិយាយនេះជាវោហារទេ យើងនឹងចរចាតបជងមិនបាន ត្រូវតែយកពាក្យដែលមានទុកក្នុងច្បាប់មកចរចាផងទើបបាន ៗ ខុងបេងថា ដែលអ្នកឯងនឹងឲ្យស្រាវជ្រាវយកពាក្យបុរាណគាត់តែងទុកនោះពិតពេះមែនហើយ តែបើយកមកចរចាក្នុងសម័យនេះ ក៏គ្មាននរណានឹងកប់កាន គេថាអ្នកនោះលួចយកគាកដម្រាចាស់មកសំដែង ឯអ្នកមានដម្រេះប្រាជ្ញា គេរមែងរិះគិតដោយគំនិតរបស់ខ្លួន ទោះបីនឹងធ្វើការណាសង្គ្រាមយ៉ាងណាក៏ដោយ ក៏ត្រូវតែអាស្រ័យបញ្ញាជាបច្ចុប្បន្ន ទើបនឹងកែខៃយកជ័យជំនះ

បាន ដែលលោកអ្នកមានសតិបញ្ញាពីដើម បានជួយទំនុកបំរុងផែនដីនោះ មិនមែននឹងយកជម្រាមកត្រដាងមើលទេ ឯខ្លួនអ្នកឯងនេះ ក៏ល្អតែមានក្រដាសនឹងពិធទឹកខ្មៅ មកសរសេរតាក់តែងជាពាក្យនិយាយលេងតាមសប្បាយនោះមែន ។

ចៀតុក ក៏ស្រែកឡើងថា ខុងបេងនេះនិយាយខ្លាំងពេកណាស់ យើងក្រែងតែមិនមែនដូចពាក្យថា យូរទៅខាងមុខ នឹងត្រឡប់ឲ្យយើងដែលថាមិនកើតជាអ្វីនោះ នឹងនាំគ្នាសើចចំអកលេងទៀតទេដឹង ។ ខុងបេងថា ឯលក្ខណៈមនុស្សដែលមិនកើតជាការមាន ២ ប្រការគឺៈ មនុស្សមិនកើតជាការតែល្អមែងប្រកបទៅដោយសេចក្ដីព្យាយាម ធ្វើការតបស្នងសងគុណចៅហ្វាយនាយដោយសុចរិតយុត្តិធម៌តាមជម្រះប្រាជ្ញា ហើយក៏មធ្យ័តជៀមខ្លួនមិនបានរំលុបគុណអ្នកដទៃ ដែលយកជាការមិនបានមិនកើតជាអ្វីសោះនោះ គឺមនុស្សជាអ្នកបរបាក្រមាច់ក្ខុកកំផ្លែងឲ្យគេសើចលេង ការអ្វីមួយក៏ធ្វើមិនកើត មនុស្សបំពួកនេះបានឈ្មោះថា អាក្រក់ជួជាតិ ដែលអ្នកឯណៈណាៈថា ត្រូវយកពាក្យបុកណមកបរបាជាមួយនឹងយើងនោះនឹងប្រយោជន៍អ្វីយើងមិនត្រូវការទេ ។ ទីប្រើក្សាំតាំងពួងឃើញខុងបេងឆ្លើយតគបពាក្យសំដីមិនបានក្ដាំងក្ដាត់ នឹងអ្នកឯណាតាំងអស់គ្នាក៏សុំឡុងមើលមុខគ្នាហើយនៅស្ងៀម ។

អ៊ុយឃុតាយស្រែកនិយាយតមកទៀតថា អ្នកតាំងអស់គ្នានេះគ្មាន

អញស្រ័យស្មោះ ចិត្តមកដេញដោលតែនឹងខុនបេង ដែលមានជម្រះប្រាជ្ញា នោះនឹងប្រាជ្ញាប្រយោជន៍អ្វី ចុះលើកកន្លងមកនឹងធ្វើអន្តរាយដល់ស្រុកភូមិហើយ នៅមិនជួយរិះគិតគ្នាការពារភ័យអន្តរាយ ក៏មកនាំពោលនិយាយតែនឹងខុនបេងជាភ្ញៀវមកពីក្រៅជាគួរហើយឬ ? ហើយក៏បែរមុខនិយាយទៅនឹងខុនបេងថា ខ្ញុំក៏ដឹងថាអ្នកមានជម្រះប្រាជ្ញាហើយ ហេតុម្ដេចឡើយអ្នកក៏មិនយកពាក្យរបស់អ្នកទៅបរោទនឹងទៅហ្វាយខ្ញុំ ក៏មកប្រឡុំនិយាយតែនឹងអ្នកទាំងអស់នេះ នឹងជាប្រយោជន៍អ្វី ។ ខុនបេងឆ្លើយថា អ្នកទាំងអស់នេះមិនបានដឹង ស្គាល់យល់លក្ខណៈល្អនឹងអាក្រក់សោះ បានជានាំគ្នាមកស្រុះដេញដោលសួរសោក នឹងចង់ឲ្យខ្ញុំតាល់សំដីនឹងដោះសាមិនរួច នឹងស្ងៀមមិនឆ្លើយក៏មិនបាន ។ ជាឆ្លើយតបទៅវិញខ្លះ ។

ខណៈនោះអ៊ុយកាយនឹងឡាសុក ក៏នាំខុនបេងដើរចេញពីល្វែងក្រៅចូលទៅគេស៊ិនគនដល់ល្វែងជាន់កណ្ដាល ទទួលជួបនឹងជូកាត់កិនជាបង ។ ខុនបេងក៏គំនាប់តាមប្រវេណី ។ ជូកាត់កិនសួរថា ប្អូនមកដល់ស្រុកកាំងតាំងនេះហើយ ហេតុម្ដេចឡើបមិនទៅរកបង ។ ខុនបេងថា ឥឡូវខ្ញុំបានទៅនៅនឹងឡៅពី ដែលមកគ្រានេះជាផ្លូវរាជការត្រាវការយកពតិមានមកជាដំណឹង បើនឹងទៅរកបងក៏ដូចជារលងផ្លូវច្បាប់ទន្ទាប់ សូមកុំឲ្យប្រកាន់ទោសខ្ញុំបាទឡើយ ។

(មានត)

# ផ្នែកកំណត់និងប្រវត្តិការណ៍

## ពត៌មានផ្សេងៗរបស់ក្រសួងធម្មការ

### អំពីការតាំងមន្ត្រីសង្ឃ

-បានតាំងលោកចៅអធិការ កាន់-អុំធោម ជន្មាយុ ៩១ វស្សា ៣០ នៅវត្តអង្គម្រះព្រៅ ជាទីអនុគណស្រុកឈូក ខេត្តកំពត ។

-បានតាំងភិក្ខុ សេខ-លឹម ជន្មាយុ ៣២ វស្សា ១២ នៅវត្តឯកព្រែកតានង់ ជាទីអនុលេខាធិការ អនុគណស្រុកកោះសុទិន (កំពង់ចាម)។

-បានតាំងភិក្ខុ ហាក់ ស៊ឹម ជន្មាយុ ៣៩ វស្សា ១៤ នៅវត្តឯកព្រែកតានង់ ជាទីព្រះគ្រូមង្គលទីបបាល ជាសហការីអនុគណ ស្រុកកោះសុទិន (កំពង់ចាម) ។

-បានតាំងព្រះគ្រូវិមលមុនី សម-យឹម វត្តសង្កែ ជាទីព្រះគ្រូបញ្ញាវិជ្ជោ អនុគណស្រុកសង្កែ (បាត់ដំបង) ។

-បានតាំងលោកចៅអធិការ ឡាត់-យ៉ាំង វត្តបវិល ជាទីព្រះគ្រូសំវរសត្ថា អនុគណដំបន់ល្វា ស្រុកមង្គលបុរី (បាត់ដំបង) ។

-បានតាំងព្រះវិន័យធរគណ ចងឌី - យឹម វត្តពោធិកុង ជាទីព្រះគ្រូសុទ្ធម្មប្បជោត ជាសហការីមេគណខេត្តបាត់ដំបង ។

-បានតាំងព្រះសមុហ៍គណ សួរ-ជិត វត្តគរ ជាទីព្រះបាឡាត់វិមលមុនី បាឡាត់គណ ខេត្របាត់ដំបង ។

-បានតាំងព្រះវិន័យធរអនុគណ ពិន-លឹម វត្តពោធិ៍កុង ជាទីព្រះវិន័យធរគណ ខេត្របាត់ដំបង ។

-បានតាំងព្រះសមុហ៍ រ័-ង៉ា វត្តគំសំពៅ ជាទីព្រះវិន័យធរអនុគណ ស្រុកសង្កែ (បាត់ដំបង) ។

-បានតាំងលោកចៅអធិការ ចាប-ឌី វត្តកែវ ជាទីព្រះសមុហ៍គណ ខេត្របាត់ដំបង ។

-បានតាំងលោកចៅអធិការ កាត-ហុក វត្តពិភិទ្ធារាម ជាទីព្រះសមុហ៍អនុគណ ស្រុកសង្កែ (បាត់ដំបង) ។

---

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(តមក)

## ព្រះមហាប៉ាង-ខាត់ រៀបរៀង

---

អតន្ទ្រី គុ. (ពិណ) ដែលឥតខ្ជិល ។

អតន្ទ្រិត គុ. ដែលអស់កម្លាំងមិនមាន, រឹងប៉ឹង ។ *អតន្ទ្រិន* គុ. ដែលអស់កម្លាំងមិនមាន, រឹងប៉ឹង ។

អតបស គុ. ដែលមានតបៈមិនមាន។

អតប្តតបស គុ. ដែលមានតបៈក្តៅមិនមាន, ដែលមានតបៈតឹងរ៉ឹងមិនមាន។

អតមិស្រ គុ. ដែលមិនងងឹត, ភ្លឺ ។

អតរិត្រ គុ. ដែលមានចង្កូតមិនមាន ។

អតរុប្រាយ គុ. ដែលមានខ្ទប់នៃដើមឈើមិនមាន ។

អតក៌ គុ. ដែលមានត្រិះរិះមិនមាន, ដែលឥតត្រិះរិះ ។ *អតកិ៌ក* គុ. ដែលមានត្រិះរិះមិនមាន ។

អតក៌្យ គុ. ដែលមិនគួរត្រិះរិះ, ដែលយល់មិនបាន ។

អតល នបុំ. ឈ្មោះឋាននរក ។

អតស៑ អវ្យ. ពីខាងនោះ ។ ចាប់តាំងពី, ក្រោយពីនោះ, ព្រោះហេតុដូច្នោះ ។ *អតោ និមិត្តម៑* ព្រោះហេតុនោះបានជា, *អតស្បរម៑* លំដាប់តទៅ, *អតោ, ឰ*, ដរៃ ពីនេះ, *អតោ ថិម*, ព្រោះហេតុនោះ ។